**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

University Royale de Droit et des Science Economies

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣ ដល់ ថ្ងៃទី ៣១ ខែ មេសា ឆ្នាំ ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **ហាក់ ឆាយហ៊ី**

**រស្មី ពេជ្ររ័ត្នន៍**

សាស្ត្រាចារ្យណែនាំ

សាស្ត្រាចារ្យជំនួយ **ម៉ូលី បញ្ញា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៣**

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ហាក់ ឆាយហ៊ី** និង **រស្មី ពេជ្ររ័ត្នន៍** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច **ឆ្នាំ២០១៩-២០២៣** សូមលំឱនកាយវាចាចិត្ត ដើម្បីសម្តែងនូវការដឹងគុណ និង កតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ ៖

**លោកឪពុក ហាក់ ឆាយខួន** **លោកឪពុក សុត រស្មី**

**អ្នកម្តាយ ឆាយ បុប្ផា** **អ្នកម្តាយ ស្រ៊ុន សុភាព**

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតទៅដល់លោកឪពុកអ្នកម្តាយជាទីគោរពដ៏ខ្ពង់ខ្ពស់ ដែលបានផ្តល់កំណើត និង ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីកូនបានកើតរហូតដល់ធំដឹងក្តីជាមួយការអប់រំល្អៗ និង បំពេញបំណងប្រាថ្នារូបកូនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានជួយផ្គត់ផ្គង់ទំនុកបម្រុងលះបង់គ្រប់បែបគ្រប់យ៉ាង មិនថាកម្លាំងកាយ កម្លាំងចិត្ត ផ្នែកស្មារតី ថវិកា ព្រមទាំងផ្នែកសម្ភារៈ ក្នុងគោលបំណងចង់ឃើញកូនៗមានគុណតម្លៃ ទទួលបានការអប់រំដែលល្អ ចាប់តាំងពីថ្នាក់កុមារដ្ឋានរហូតដល់ថ្នាក់ឧត្តមសិក្សា ដើម្បីឲ្យកូនបានក្លាយជាបុគ្គលមានតម្លៃទាំងចំពោះខ្លួនឯង គ្រួសារ និង សង្គមជាតិ ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធិបុរស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាតផ្តល់លទ្ធភាពឱ្យយើងខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ **លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការបង្ហាត់បង្ហាញបង្រៀនយ៉ាងយកចិត្តទុកដាក់ ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹង និង បទពិសោធន៍ ដល់ពួកយើងខ្ញុំក៏ដូចជាសិស្សដទៃទៀតក្នុងអំឡុងពេល៤ឆ្នាំកន្លងមកនេះ ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ អ្នកគ្រូសាស្រ្តាចារ្យ **ប៉ូលី បញ្ញា** ជាសាស្រ្តាចារ្យជំនួយដែលបានដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តមួយនេះ ព្រមទាំងជួយណែនាំ ត្រួតពិនិត្យ កែតម្រូវចំណុចខ្វះខាត ចង្អុលបង្ហាញ ផ្តល់មតិយោបល់ ដំបូន្មានល្អៗ ទាំងផ្នែកស្មារតីនិងផ្តល់ឯកសារជំនួយផ្សេងៗ ជាពិសេសគឺពេលវេលាដ៏មានតម្លៃរបស់អ្នកគ្រូនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះចាប់តាំងពីចំណុចចាប់ផ្តើមរហូតដល់សារណាមួយនេះបានបញ្ចប់ប្រកបដោយភាពជោគជ័យ។

ជាទីចុងបញ្ចប់យើងខ្ញុំទាំងពីរនាក់សូមលើកហត្ថប្រណមបួងសួងដល់បារមីវត្ថុសក្តិសិទ្ធិទេព្តាក្នុងលោក សូមប្រសិទ្ធិពរជ័យសិរីសួស្តីជូនចំពោះ **អ្នកមានគុណទាំងពីររបស់យើងខ្ញុំដែលជាលោកឪពុក និង អ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យ មិត្តភក្តិទាំងអស់ និង អ្នកគ្រូសាស្រ្តាចារ្យដឹកនាំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ប៉ូលី បញ្ញា** សូមជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ ជោគជ័យគ្រប់ភារកិច្ចការងារ ព្រមទាំងជួបពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

# អារម្ភកថា

សៀវភៅសារណាដែលកំពុងតែមានវត្តមាននៅក្នុងដៃរបស់លោកអ្នកនេះគឺត្រូវបានសម្រិតសម្រាំងយ៉ាងខ្លាំងក្នុងការខិតខំស្រាវជ្រាវដោយយកចិត្តទុកដាក់ជាទីបំផុត ដោយដកស្រង់នូវខ្លឹមសារនិងគោលគំនិតប្រកបដោយគុណភាព និង សារៈប្រយោជន៍យ៉ាងចាំបាច់គួរជាទីកត់សម្គាល់បំផុត ដើម្បីយកមកចងក្រងជាសៀវភៅនេះឡើងក្នុងគោលបំណងពង្រីកចំណេះដឹងបន្ថែមអោយកាន់តែស៊ីជម្រៅលើកិច្ចសន្យា ។

នៅក្នុងសង្គមរស់នៅនាពេលបច្ចុប្បន្ន យើងខ្ញុំបានមើលឃើញថា ការទំនាក់ទំនង រវាងបុគ្គលនឹងបុគ្គល រវាងបុគ្គលនឹងនីតិបុគ្គល ពិតជាមានសារៈសំខាន់ខ្លាំង និង មានភាពចាំបាច់សម្រាប់បំពេញតម្រូវការក្នុងការរស់នៅ និង ការវិនិយោគ ។ យ៉ាងណាមិញការទំនាក់ទំនងនេះ ប្រាដកណាស់នឹងនាំមកនូវចំណងគតិយុត្តរវាងគូភាគីទាំងសងខាង ដូចនេះរាល់ទំនាក់ទំនងក្នុងវិស័យជំនួញគឺពិតជាចាំបាច់ណាស់ក្នុងការតម្រូវឲ្យមានកិច្ចសន្យាច្បាស់លាស់។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងផងដែរ នូវប្រភេទនៃកិច្ចសន្យាជាច្រើនដែលមានការប្រើប្រាស់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ដោយនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ គឺប្រជាពលរដ្ឋគាត់តែងតែបង្កើតកិច្ចសន្យានៅក្នុងមុខជំនួញផ្ទាល់ខ្លួនរបស់គាត់ ដើម្បីធ្វើជាភស្តុតាងនៅក្នុងករណីដែលមានវិវាទកើតឡើង ឬ ក៏ភាគីនៃកិច្ចសន្យាមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ដូច្នេះគាត់អាចប្រើប្រាស់វិធីសាស្ត្រសង្គ្រោះកិច្ចសន្យា រួមមានដូចជា ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងនៃការខូចខាត និង ការរំលាយកិច្ចសន្យាជាដើម ប៉ុន្តែដោយមានប្រជាពលរដ្ឋយើងខ្លះទៀតពួកគាត់ពុំទាន់បានយល់ច្បាស់និងសិក្សាឲ្យបានស៊ីជម្រៅនៅឡើយទេ អំពីនីតិវិធីនៃការបង្កើត-ការរំលាយកិច្ចសន្យា និង អានុភាពសំណងការខូចខាតនៃការរំលាយកិច្ចសន្យា ហេតុដូច្នេះហើយទើបយើងខ្ញុំទាំងពីរនាក់បានមូលមតិគ្នាសម្រេចចិត្តចងក្រងសារណាក្រោមប្រធានបទ **របបគតិយុតនៃកិច្ចសន្យា** នេះឡើង ។

ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរក៏សូមខន្តីអភ័យទោសទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និង មិត្តអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គាំឆ្គងដែលកើតមានឡើងដោយអចេតនាណាមួយដែលកើតមានឡើងនៅក្នុងសៀវភៅកិច្ចការស្រាវជ្រាវមួយក្បាលនេះ ពីព្រោះថា នៅក្នុងការសិក្សាស្រាវជ្រាវតែងតែមាននូវចំណុចខ្វះខាតមួយចំនួនជាក់ជាមិនខាន ទាំងអក្ខរាវិរុទ្ធក្តី ទាំងពាក្យពេចន៍ និង ទាំងអត្ថន័យក្តី ។ ដូច្នេះហើយយើងខ្ញុំទាំងពីររូបរងចាំជានិច្ចនូវរាល់មតិរិះគន់ដើម្បីស្ថាបនាដោយក្តីរីករាយ ពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ក៏ដូចជាមិត្តអ្នកអានទាំងអស់ដែលនឹងកំពុងបានអាននូវសារណារបស់យើងខ្ញុំទាំងពីរ។ យើងខ្ញុំសង្ឃឹមថាស្នាដៃនៃការសិក្សាស្រាវជ្រាវសារណាបញ្ចប់ការសិក្សាមួយនេះនឹង ផ្តល់មកនូវជាឯកសារដែលមានអត្ថប្រយោជន៍ និង ចូលរួមបំពេញតម្រូវការ ព្រមទាំងលើកកម្ពស់ជីវភាពនៃការរស់នៅបន្ថែមមួយកម្រិតទៀតចំពោះបុគ្គលគ្រប់រូប ក៏ដូចជាលើកស្ទួយវិស័យយុត្តិធម៌ វិស័យឯកជន វិស័យនានាផ្សេងទៀត និង ជាពិសេសជួយឲ្យនីតិរដ្ឋនៅប្រទេសកម្ពុជាកាន់តែរីកចម្រើនឆ្ពោះទៅមុខ ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមជូនពរទៅដល់មិត្តអ្នកអានទាំងអស់អោយជួបតែពុទ្ធពរទាំង ៤(បួន) គឺ **អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។**

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ....................................................................................... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...................................................................................... ១

៣. គោលបំណងនៃការស្រាវជ្រាវ ........................................................................................ ២

៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ............................................................................. ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ.......................................................................................... ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ............................................................................................. ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................................... ៣


## ជំពូកទី ១

## សញ្ញាណទូទៅនៃកិច្ចសន្យា


**ផ្នែកទី ១ ៖ កិច្ចសន្យា និង ទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរី**.................................................... ៤

**ផ្នែកទី ២ ៖ គោលការណ៍សំខាន់ៗនៅក្នុងនីតិកិច្ចសន្យា**........................................................ ៥

១. គោលការណ៍ស្វ័យភាពខាងឆន្ទៈ ..................................................................................... ៥

២. គោលការណ៍សេរីភាពនៃការចុះកិច្ចសន្យា ........................................................................ ៥

៣. បទប្បញ្ញត្តិតាមស្ម័គ្រចិត្ត  និង បទប្បញ្ញត្តិដោយបង្ខំ ............................................................... ៦

៤.គោលការណ៍សុចរិត  និង ស្មោះត្រង់ ................................................................................ ៦

**ផ្នែកទី ៣ ៖ ចំណាត់ថ្នាក់នៃកិច្ចសន្យា**...................................................................................... ៦

១. កិច្ចសន្យាដែលយកតម្លៃថ្នូរ ...................................................................................... ៦

២. កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ................................................................................. ៧

៣. កិច្ចសន្យាទ្វេភាគី.................................................................................................... ៧

៤. កិច្ចសន្យាឯកតោភាគី............................................................................................... ៧

## ជំពូកទី ២
## ការបង្កើតកិច្ចសន្យា


**ផ្នែកទី ១ ៖ គោលការណ៍នៃការបង្កើតកិច្ចសន្យា**........................................................៨

**កថាភាគទី ១ ៖ ការព្រមព្រៀង**........................................................................................៨

**កថាភាគទី ២ ៖ សំណើ**...................................................................................................៨

១. លក្ខខណ្ឌនៃសំណើ.........................................................................................................៨

១.១. គោលបំណងពិតប្រាកដ.................................................................................................៩

១.២. ភាពច្បាស់លាស់នៃសំណើ...........................................................................................៩

១.៣. ការជូនដំណឹងអំពីសំណើ............................................................................................៩

២. កាលកំណត់នៃសំណើ.......................................................................................................៩

២.១. សំណើដែលមានកំណត់អំឡុងពេល.................................................................................៩

២.២. សំណើដែលគ្មានកំណត់អំឡុងពេល..............................................................................១០

៣. ការបញ្ចប់សំណើ............................................................................................................១១

**កថាភាគទី ៣ ៖ ស្ទីការ**..................................................................................................១១

១. លក្ខខណ្ឌនៃស្ទីការ...........................................................................................................១១

១.១. អ្នកមានសិទ្ធិក្នុងការផ្តល់ស្ទីការ....................................................................................១២

១.២. ការជូនដំណឹងអំពីស្ទីការ.............................................................................................១២

១.៣. ស្ទីការត្រូវតែធ្វើមុនពេលសំណើរលត់..........................................................................១២

**កថាភាគទី ៤ ៖ វិការៈនៃការព្រមព្រៀង**...........................................................................១២

១. ការភ័ន្តច្រឡំ...................................................................................................................១៣

២. ការឆបោក.....................................................................................................................១៣

៣. ព័ត៌មានមិនពិត................................................................................................................១៤

៤. ការរំលោភបំពានលើស្ថានភាព..........................................................................................១៤

៥. អំពើកេងចំណេញហួសហេតុ.............................................................................................១៥

៦. ការគំរាមកំហែង...............................................................................................................១៥

**ផ្នែកទី ២ ៖ កម្មវត្ថុនៃកិច្ចសន្យា** ..................................................................១៦

**កថាភាគទី ១ ៖ ភាពស្របច្បាប់ឬភាពផ្ទុយនឹងការអនុវត្តដោយបង្ខំ**..........................១៦

**កថាភាគទី ២ ៖ ភាពមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទំលាប់ល្អ** ..........១៧

**ផ្នែកទី ៣ ៖ សមត្ថភាពចុះកិច្ចសន្យា** ..................................................................១៨

**កថាភាគទី ១ ៖ ជនដែលអាចចុះកិច្ចសន្យា**..........................................................១៨

១. នីតិជន..................................................................................................១៨

២. អនីតិជនដែលមានអត្តាធីនភាព..........................................................................១៩

៣. អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ..................................................១៩

**កថាភាគទី ២ ៖ ជនដែលមិនអាចចុះកិច្ចសន្យា**.....................................................២០

១. អនីតិជននៅក្រោមអំណាចមេបា...........................................................................២០

២. ជនដែលនៅក្រោមហិតូបត្ថម្ភ ..............................................................................២០

៣. ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ................................................................២១

**ផ្នែកទី ៤ ៖ លក្ខខណ្ឌទម្រង់កិច្ចសន្យា** ..................................................................២១

១.កិច្ចសន្យាធ្វើដោយផ្ទាល់មាត់..................................................................................២២

២.កិច្ចសន្យាធ្វើជាលាយល័ក្ខណ៍អក្សរ...........................................................................២២

២.១. លិខិតយថាភូត..........................................................................................២២

២.២. លិខិតឯកជន ............................................................................................២២

## ជំពូកទី ៣

## អានុភាពនៃកិច្ចសន្យា

**ផ្នែកទី ១ ៖ អានុភាពនៃកិច្ចសន្យាចំពោះគូភាគី**......................................................២៤

១. អានុភាពបង្កើតសិទ្ធិទូទៅចំពោះភាគី......................................................................២៤

២. អានុភាពចាប់បង្ខំនូវករណីកិច្ចទូទៅចំពោះភាគី ........................................................២៥

២.១. កិច្ចសន្យាត្រូវតែអនុវត្ត ...............................................................................២៥

២.២. ការអនុវត្តត្រូវតែគោរពគោលការណ៍សុចរិត និង ស្មោះត្រង់ ....................................២៧

៣.អានុភាពបង្កើតជាច្បាប់របស់ភាគី..........................................................................................២៩
៣.១. ភាពមិនអាចកែប្រែបាននៃកិច្ចសន្យា ..................................................................................២៩
៣.២. ភាពមិនអាចបំពានបាននៃកិច្ចសន្យា...................................................................................៣០
**ផ្នែកទី ២ ៖ អានុភាពនៃកិច្ចសន្យាចំពោះតតិយជន** ......................................................................៣១
១. កិច្ចសន្យាដែលបង្កើតស្ថានភាពគតិយុត្តចំពោះតតិយជន..........................................................៣១

## ជំពូកទី ៤

## ការរំលាយកិច្ចសន្យា

**ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃការរំលាយកិច្ចសន្យា**.......................................................................៣៥
**កថាភាគទី ១ ៖ និយមន័យនៃការរំលាយកិច្ចសន្យា** ......................................................................៣៥
**កថាភាគទី ២ ៖ គោលបំណងនៃការរំលាយកិច្ចសន្យា**....................................................................៣៥
**កថាភាគទី ៣ ៖ ប្រភេទនៃការរំលាយកិច្ចសន្យា**...........................................................................៣៥
១. ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់..........................................................................៣៥
២. ការរំលាយកិច្ចសន្យាដែលកំណត់នៅក្នុងកិច្ចសន្យា....................................................................៣៦
៣. ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេស....................................................................៣៦
៤. ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង .........................................................................៣៦
**ផ្នែកទី ២ ៖ មូលហេតុនៃការរំលាយកិច្ចសន្យា**.............................................................................៣៧
**កថាភាគទី ១ ៖ កិច្ចសន្យាឯកតោភាគី**........................................................................................៣៧
**កថាភាគទី ២ ៖ កិច្ចសន្យាអញ្ញមញ្ញ** ..........................................................................................៣៧
**កថាភាគទី ៣ ៖ ការបំពានកិច្ចសន្យាធ្ងន់ធ្ងរដោយភាគីម្ខាងនៃកិច្ចសន្យា** .......................................៣៨
១. ការរំលាយកិច្ចសន្យាដោយការដាស់តឿនភាគីមិនអនុវត្តកាតព្វកិច្ច ..............................................៣៨
២. ការរំលាយកិច្ចសន្យាដោយមូលហេតុយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ..........................................៣៨
៣. ការរំលាយកិច្ចសន្យាដោយមូលហេតុអលទ្ធភាពក្នុងការផ្តល់នូវតាវកាលិកចម្បង...............................៣៩
៤. ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់ជំនឿចិត្តរវាងគូភាគី ....................................................៣៩

**ផ្នែកទី ៣ ៖ វិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា**........................................៤០

**កថាភាគទី ១ ៖ ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ**......................៤០

១. ការរំលាយតាមកិច្ចសន្យា ..................................................................................៤១

២. ការរំលាយតាមការព្រមព្រៀងគូភាគី .....................................................................៤២

៣. ការរំលាយតាមសន្ទានកម្ម.................................................................................៤៣

៤. ការរំលាយតាមមជ្ឈត្តការ ..................................................................................៤៣

**កថាភាគទី ២ ៖ ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការ** .....................៤៤

**កថាភាគទី ៣ ៖ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអាចដកបាន**..........................៤៥

**កថាភាគទី ៤ ៖ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់លក្ខខណ្ឌបង្អង់** ...........៤៥

**កថាភាគទី ៥ ៖ ការរំលាយកិច្ចសន្យាដោយភាគីម្ខាងមានគ្នាច្រើននាក់**...................៤៦

**ផ្នែកទី ៤ ៖ ការរំលត់សិទ្ធិនៃការរំលាយកិច្ចសន្យា**.........................................................៤៦

**កថាភាគទី ១ ៖ ពេលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត**.........................................៤៦

**កថាភាគទី ២ ៖ ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារអាជ្ញាយុកាល**.......................៤៨

**កថាភាគទី ៣ ៖ ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយការអនុវត្តកាតព្វកិច្ចគូភាគី** ......៤៨

**ផ្នែកទី ៥ ៖ អានុភាពនៃការរំលាយកិច្ចសន្យា**...............................................................៤៨

**កថាភាគទី ១ ៖ អានុភាពនៃការរំលាយកិច្ចសន្យាចំពោះគូភាគី**...............................៥២

**កថាភាគទី ២ ៖ អានុភាពនៃការរំលាយកិច្ចសន្យាចំពោះតតិយជន** .........................៥៤

**កថាភាគទី ៣ ៖ ករណីយកិច្ចសងសំណងនៃការខូចខាត** ..............................................៥៧

**សេចក្តីសន្និដ្ឋាន** .....................................................................................................៦២

**អនុសាសន៍**............................................................................................................៦៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងជីវភាពរស់នៅក្នុងសង្គមមនុស្ស គេរមែងតែងជួបប្រទះនឹងកិច្ចសន្យា គ្រាន់តែបុគ្គលខ្លះមិនបានចាប់អារម្មណ៍យកចិត្តទុកដាក់ទៅនឹងបញ្ហានេះ ។ កិច្ចសន្យាមានសារៈសំខាន់ណាស់ សំរាប់ទំនាក់ទំនងរវាងបុគ្គលសាមញ្ញ ក៏ដូចជាបុគ្គលវិជ្ជាជីវៈរហូតដល់ទំនាក់ទំនងពីសញ្ជាតិមួយទៅសញ្ជាតិមួយ និង ពីប្រទេសមួយទៅប្រទេសមួយទៀត ។ទន្ទឹមនឹងនោះ ដើម្បីសំរេចនូវការងារនីមួយៗឲ្យទទួលបានលទ្ធផលល្អសមប្រកបតាមការប្រាថ្នាចង់បាន គឺចាំបាច់ណាស់ដែលមនុស្សត្រូវបង្កើតកិច្ចសន្យាក្នុងការគ្រប់គ្រង និង ការពារអត្ថប្រយោជន៍របស់គូភាគីទាំងសងខាង។ លើសពីនេះទៅទៀត ការបង្កើតកិច្ចសន្យា គឺស្ថិតក្នុងគោលបំណងបង្កើតឲ្យមានភាពច្បាស់លាស់រវាងគ្នានឹងគ្នា ភាពស្មោះត្រង់ ក៏ដូចជាភាពជឿទុកចិត្តបាន ដែលមិនបណ្តាលឲ្យមានការបាត់បង់ ឬខូចខាតនូវផលប្រយោជន៍ចំពោះគ្នាទៅវិញទៅមកផងដែរ។ នៅក្នុងករណីដែលកិច្ចសន្យាត្រូវបានបំពានដោយភាគីម្ខាងនៃកិច្ចសន្យា ហើយធ្វើអោយខូចផលប្រយោជន៍ និងបាត់បង់ទំនុកចិត្ត នោះភាគីម្ខាងទៀតអាចសង្គ្រោះកិច្ចសន្យាបានដោយការរំលាយកិច្ចសន្យា ។ ការរំលាយកិច្ចសន្យា គឺត្រូវបានគេយកទៅអនុវត្តជាច្រើន ដោយវាជាវិធីសង្គ្រោះមួយនៅពេលដែលភាគីម្ខាងមិនបានអនុវត្តកាតព្វកិច្ចពេញលេញ ឬ ក៏បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ដោយត្រូវរំលាយកិច្ចសន្យាចោលហើយត្រូវសងមកវិញនូវសំណងខូចខាតនិងការធ្វើបដិទានដោយផ្អែកទៅលើបញ្ញត្តិនៃការរំលាយកិច្ចសន្យាក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

តើរបបគតិយុត្តនៃកិច្ចសន្យាមានលក្ខណៈបែបណា ? តើការបង្កើតកិច្ចសន្យា និង ការរំលាយកិច្ចសន្យាកើតឡើង ដោយសារមានមូលហេតុអ្វីខ្លះ ? តើការបង្កើតកិច្ចសន្យាមាននីតិវិធីបែបណាខ្លះ ទើបអាចនាំឲ្យកិច្ចសន្យាដែលបង្កើតឡើងប្រព្រឹត្តទៅដោយមានអានុភាព ហើយមាននីតិវិធីបែបណាខ្លះ ដែលនាំឲ្យការរំលាយកិច្ចសន្យាអាចអនុវត្តទៅបានដោយមានសុពលភាព ? តើការរំលាយកិច្ចសន្យានឹងមានអានុភាពបែបណាទៅលើភាគីពាក់ព័ន្ធនៃកិច្ចសន្យា? តើត្រូវមានទឡ្ហីករណ៍ និង ភស្តុតាងអ្វីខ្លះ ដើម្បីអាចធ្វើឲ្យភាគីជាប់បន្ទុករួចផុតពីករណីយកិច្ចក្នុងការសងសំណងខូចខាតនៃកិច្ចសន្យាបាន ?

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវប្រធានបទ **របបគតិយុត្តនៃកិច្ចសន្យា** នេះគឺ យើងខ្ញុំទាំងពីររូបមានបំណងចង់ស្វែងយល់ឲ្យកាន់តែច្បាស់ជាក់លាក់ ឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ក៏ដូចជាចង់ចែករំលែកលទ្ធផលនៃការខិតខំសិក្សាស្រាវជ្រាវអំពីរបបគតិយុត្តនៃកិច្ចសន្យា ដែលពួកយើងបានសិក្សាយល់ដឹងទៅកាន់មនុស្សគ្រប់គ្នាដែលបានអានវណ្ណកម្មស្នាដៃរបស់ពួកយើងទាំងពីររូប ។ ដោយមូលហេតុយើងបានសង្កេតឃើញថា ប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្នមានសន្តិភាព មានការអភិវឌ្ឍន៍ឈានទៅមុខជារៀងរាល់ថ្ងៃឥតឈប់ឥតឈរ ហើយជីវភាពរស់នៅប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋខ្មែរ ក៏មានភាពអភិវឌ្ឍនាការស្របទៅជាមួយសង្គមជាតិផងដែរនោះគឺជាកត្តាសំខាន់ណាស់ដែលយើងត្រូវការស្វែងយល់លម្អិតបន្ថែមអំពីកិច្ចសន្យាឲ្យកាន់តែច្បាស់លាស់ ទើបយើងខ្ញុំទាំងពីររូបមូលមតិគ្នា ធ្វើការសម្រេចចិត្តសិក្សាស្រាវជ្រាវចងក្រងនូវសិក្ខាប័ននេះឡើង ទុកគ្រាន់ជាឯកសារជំនួយស្មារតី សម្រាប់សិស្សនិស្សិតជំនាន់ក្រោយៗ និង មិត្តអ្នកដែលស្រឡាញ់ចូលចិត្តការអាន សិក្សាស្វែងយល់បន្ថែមប្រកបដោយពុទ្ធិចំណេះដឹង និង រក្សាទុកជាបទពិសោធន៍ផ្ទាល់ខ្លួនក្នុងវិស័យគតិយុត្តទាក់ទិននឹងកិច្ចសន្យានៃការរស់នៅក្នុងនីតិរដ្ឋ ។

## ៤.ទំហំ និង ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ចំពោះសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកនីតិសាស្ត្រមួយនេះ គឺសិក្សាទៅលើលក្ខណៈសំខាន់ៗទូទៅជុំវិញពីកិច្ចសន្យាតែប៉ុណ្ណោះ គឺមិនបានបកស្រាយលម្អិតអំពីការបង្កើតកិច្ចសន្យានិងការរំលាយកិច្ចសន្យាសំខាន់ៗនីមួយៗម្តងមួយៗនោះទេ ។ បន្ថែមពីលើនេះ ការសិក្សាស្រាវជ្រាវនៃប្រធានបទនេះគឺផ្អែកសំខាន់តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា( ឆ្នាំ២០០៧ ) ដែលជាឯកសារគោលសំខាន់ ក៏ដូចជាបានដកស្រង់ចេញពីសៀវភៅដែលមានខ្លឹមសារល្អៗរបស់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មួយចំនួន និង បាឋកថាអ្នកមានចំណេះដឹងផ្នែកច្បាប់នានាដែលបានធ្វើការបង្ហាញបកស្រាយ មានការទាក់ទងទៅនឹងប្រធានបទរបស់យើងខ្ញុំទាំងពីរត្រូវសិក្សាស្រាវជ្រាវនេះ ។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះគឺ ចង់ឱ្យសិស្សនិស្សិត ប្អូនៗជំនាន់ក្រោយ និង មិត្តអ្នកដែលបានអានសិក្ខាប័ននេះនៅគ្រប់ទីមជ្ឈដ្ឋាន ជាពិសេសអ្នកដែលស្រឡាញ់ចូលចិត្តផ្នែកនីតិសាស្ត្រ ក៏ដូចជាអ្នកដែលកំពុងសិក្សារៀនសូត្រផ្នែកនីតិសាស្ត្រ រួមទាំងយើងខ្ញុំបាទទាំងពីរនាក់ដែលជាអ្នកតាក់តែងចងក្រងនូវសារណានេះ ទុកគ្រាន់ជាឯកសារជំនួយប្រាជ្ញាស្មារតី អាចសិក្សាស្វែងយល់បង្កើនចំណេះដឹងផ្ទាល់ខ្លួនបន្ថែម និង ធ្វើឱ្យមានភាពកាន់តែច្បាស់លាស់បន្ថែមអំពីរបបគតិយុត្តនៃកិច្ចសន្យា ដែលជាការចូលរួមចំណែកលើកស្ទួយឲ្យកើតជាសារប្រយោជន៍ក្នុងវិស័យគតិយុត្ត ។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំទទួលបានតាមរយៈការស្រាវជ្រាវប្រមូលទិន្នន័យព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីធ្វើអោយសារណាមួយនេះមានភាពត្រឹមត្រូវ និង ទទួលបានប្រសិទ្ធិភាពខ្ពស់។ នៅក្នុងខ្លឹមសារអត្ថបទសិក្សាស្រាវជ្រាវនៃសារណានេះ គឺយើងខ្ញុំទាំងពីរនាក់បានដកស្រង់ចេញមកនូវគោលគំនិតពីក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ , សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី , សេចក្តីពន្យល់ពីក្រមប្បវេណី និង ឯកសារផ្សេងទៀត ក៏ដូចជាសៀវភៅរបស់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកមានចំណេះដឹងផ្នែកច្បាប់ជាច្រើនរូបទៀតជាគោលផងដែរ ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារអត្ថបទសិក្សាស្រាវជ្រាវនៃសារណាប្រធានបទ របបគតិយុត្តនៃកិច្ចសន្យា នេះ យើងនឹងបានសិក្សាចំនួន ៤ ជំពូក សំខាន់គឺ ៖

- **ជំពូកទី១ ៖ សញ្ញាណទូទៅនៃកិច្ចសន្យា**
- **ជំពូកទី២ ៖ ការបង្កើតកិច្ចសន្យា**
- **ជំពូកទី៣ ៖ អានុភាពនៃកិច្ចសន្យា**
- **ជំពូកទី៤ ៖ ការរំលាយកិច្ចសន្យា**

# ជំពូកទី ១

## សញ្ញាណទូទៅនៃកិច្ចសន្យា

# ជំពូកទី ១

# សញ្ញាណទូទៅនៃកិច្ចសន្យា

## ផ្នែកទី ១ ៖ កិច្ចសន្យា និង ទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរី

កិច្ចសន្យា ជាការសម្តែងឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬ ច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ចមួយ ឬ ច្រើនដែលទាក់ទងនឹងខ្លួន ។ ក្នុងអត្ថន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល។[1] ការសម្តែងឆន្ទៈមានន័យថាជាការប្រាប់ចេតនារបស់យើងទៅអ្នកដទៃ ឬ ដៃគូ ដើម្បីបង្កើតចំណងផ្លូវច្បាប់ក្នុងកម្រិតមួយដែលស្របទាំងស្រុងទៅតាមឆន្ទៈដែលត្រូវបានបង្កើតឡើងនោះ ។ សូមកុំគិតថាការប្រាប់នូវអ្វីៗដែលខ្លួនយល់ឃើញទៅដៃគូទាំងប៉ុន្មានសុទ្ធតែជាការសម្តែងឆន្ទៈនោះអោយសោះ ។ តាមច្បាប់គ្រប់ការសម្តែងឆន្ទៈមិនមែនសុទ្ធតែបង្កើតអោយមានអានុភាពគតិយុត្តនោះទេ ។

តាមក្រមរដ្ឋប្បវេណីសង្គមចាស់ មាត្រា ៧៩១ កិច្ចសន្យា ជាកិរិយាដែលជនពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ចមួយ ឬច្រើនដែលជាបន្ទុកលើខ្លួនម្នាក់ៗ ។ កិច្ចសន្យានោះអាចចែងពីកាតព្វកិច្ចពិសេសដែលជាបន្ទុកលើភាគីតែម្នាក់ ឬ ច្រើននាក់ ឱ្យបំពេញក៏បាន ឬ អាចចែងពីកាតព្វកិច្ចទៅវិញទៅមកដែលជាបន្ទុកលើភាគីទាំងសងខាង ឱ្យបំពេញទៅវិញទៅមកក៏បាន ។

យោងតាមមាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ ) " កិច្ចសន្យា គឺជាកិរិយាដែល បុគ្គលពីរនាក់ រឺ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ រឺ រំលត់ នូវកាតព្វកិច្ច " ។

យោងតាមមាត្រា ១១០១ នៃក្រមរដ្ឋប្បវេណីបារាំង បានចែងថា " កិច្ចសន្យា គឺជាអនុសញ្ញាមួយដែលតាមរយៈនេះ ភាគីមួយ រឺ ច្រើន បានសន្យាចំពោះ ភាគីម្ខាងទៀត រឺ ច្រើន ដើម្បី អោយធ្វើ រឺ មិនធ្វើអ្វីមួយ " ។

***Art 1101:*** *A contract is an agreement by which one or several persons bind themselves, towards one or several others, to transfer, to do or not to do somethings.*

ដូចនេះកិច្ចសន្យាកើតមានដូចជាអនុសញ្ញាមួយ ដែលតាមរយៈនេះយ៉ាងហោចណាស់ត្រូវមានបុគ្គលពីររូបចូលរួមដែលយើងហៅថាគូភាគីនៃកិច្ចសន្យា ។ កិច្ចសន្យានេះធ្វើអោយកើតនូវកាតព្វកិច្ចមួយចំនួន គឺ ការបង្កើតសិទ្ធិ ការផ្ទេរសិទ្ធិ រឺ ការរំលត់សិទ្ធិ ដែលនេះគឺជាគតិយុត្តមួយ ។

[1] មាត្រា ១ នៃក្រឹត្យ-ច្បាប់លេខ ៣៨

កិច្ចសន្យាគឺឈរលើគោលការណ៍គ្រឹះសេរីភាពក្នុងការចុះកិច្ចសន្យា ។ គោលការណ៍គ្រឹះក្នុងការចុះកិច្ចសន្យា គឺជាទ្រឹស្តីស្វ័យភាពនៃឆន្ទៈសេរី និង ជាសារវន្តគោលការណ៍ដែលទាក់ទងនឹងសេរីភាពក្នុងការចុះកិច្ចសន្យា រឺ មិនចុះកិច្ចសន្យា ប៉ុន្តែ ការប្រើសេរីភាពក៏ត្រូវមានវិសាលភាពកំណត់ដោយនីតិវត្ថុវិស័យផងដែរ ពោលគឺសេរីភាពមានដែនកំណត់ ។

## ផ្នែកទី ២ ៖ គោលការណ៍សំខាន់ៗនៅក្នុងនីតិកិច្ចសន្យា

### ១.គោលការណ៍ស្វ័យភាពខាងឆន្ទៈ

តាមរយៈគោលការណ៍នេះគឺផ្តោតធ្ងន់ទៅលើឆន្ទៈរបស់បុគ្គលម្នាក់ៗដែលជាភាគីនៅក្នុងរឿងរដ្ឋប្បវេណី ។ ពោលគឺ បុគ្គលម្នាក់ៗដែលជាពលរដ្ឋមិនមែនរស់ដោយគោរពតាមវិធានដែលអ្នកដទៃកំណត់ឱ្យនោះទេ មានន័យថា នៅរាល់ទំនាក់ទំនងជីវភាពរវាងបុគ្គលនិងបុគ្គល គេបានបង្កើតវិធានទៅតាមឆន្ទៈរបស់ខ្លួន ហើយគ្រប់គ្រងជីវភាពរបស់ខ្លួនដោយខ្លួនឯងដែរ ។ នេះគេហៅថា គោលការណ៍ស្វ័យភាពខាងឆន្ទៈ ឬ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។[2] តាមរយៈគោលការណ៍នេះ ឆន្ទៈរបស់គូភាគីត្រូវបានយកមកធ្វើជាវិធានច្បាប់ សម្រាប់ធ្វើការគ្រប់គ្រងទំនាក់ទំនងគតិយុត្ត ដោយធ្វើការបដិសេធចោលវិធានច្បាប់ ។

### ២.គោលការណ៍សេរីភាពនៃការចុះកិច្ចសន្យា

តាមរយៈគោលការណ៍នេះ គូភាគីអាចធ្វើកិច្ចសន្យាដោយសេរីតាមឆន្ទៈព្រមព្រៀងដោយសេរី និង ពិតប្រាកដ មានន័យថាការព្រមព្រៀងដោយគ្មានវិការៈ ។ ពោលគឺគូភាគី អាចបង្កើតកិច្ចសន្យាដោយសេរីកុំឱ្យតែប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់នៅក្នុងសង្គម ។ ស្ថិតក្នុងន័យនេះ គូភាគីនៃកិច្ចសន្យាមានសេរីភាពពេញលេញក្នុងការជ្រើសរើសភាគីនៃកិច្ចសន្យារបស់ខ្លួននៅពេលដែលខ្លួនចុះកិច្ចសន្យា ទោះបីជាកិច្ចសន្យានោះ ជាកិច្ចសន្យាប្រភេទណាក៏ដោយ កុំឱ្យតែកិច្ចសន្យានោះផ្ទុយនិងច្បាប់ ។

តាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ ) មាត្រា ៣៤៥ អ្នកដែលបង្ហាញឆន្ទៈដោយមានវិការៈ អាចលុបកិច្ចសន្យាចោលបាន ។ ការព្រមព្រៀងដែលមានវិការៈសំដៅទៅលើការព្រមព្រៀងដែលកើតឡើងដោយមានការភ័ន្តច្រឡំ ដោយមានហិង្សា ឬ ដោយការបន្លំបោកប្រាស់ ។[3]

---

[2] មាត្រា ៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

[3] មាត្រា ៧ ក្រឹត្យ-ច្បាប់លេខ ៣៨

### ៣.បទប្បញ្ញត្តិតាមការស្ម័គ្រចិត្ត និង បទប្បញ្ញត្តិដោយបង្ខំ

បើគូភាគីបានកំណត់នូវវិធានអ្វីមួយហើយនោះ វិធាននោះនិងត្រូវយកមកអនុវត្ត ប៉ុន្តែចំពោះចំណុចណាដែលមិនបានកំណត់នោះគឺ ត្រូវយកបទប្បញ្ញត្តិនៃច្បាប់រដ្ឋប្បវេណីមកអនុវត្ត ដើម្បីបំពេញចន្លោះខ្វះខាត។

បទប្បញ្ញត្តិ ដែលអនុញ្ញាតឱ្យការព្រមព្រៀងរបស់ភាគីមានអាទិភាពជាងសេចក្តីដែលចែងនៅក្នុងមាត្រានៃច្បាប់រដ្ឋប្បវេណីនេះគេហៅថា បទប្បញ្ញត្តិតាមការស្ម័គ្រចិត្ត ។

ចំពោះបទប្បញ្ញត្តិ ដែលពុំអាចប្តូរសារន័យនៅក្នុងមាត្រានៃច្បាប់បានជាដាច់ខាតទេនោះ គេហៅថា បទប្បញ្ញត្តិដោយបង្ខំ ។

តាមក្រមរដ្ឋប្បវេណីបានចែងអំពីប្រភេទនៃសិទ្ធិប្រត្យក្សជាដើមដែលជាសិទ្ធិផ្តាច់មុខអនុញ្ញាតិឱ្យគេអាចប្រកាសនូវសិទ្ធិគ្រប់គ្រងដាច់ខាត តតាំងនឹងគ្រប់តតិយជន ។ ដូច្នេះយើងម្នាក់ៗមិនអាចចេះតែបង្កើតវិធានណាដែលខុសពីមាត្រាចែងក្នុងច្បាប់បានតាមចិត្តបានឡើយ (គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់) ។[4]

### ៤.គោលការណ៍សុចរិត និង ស្មោះត្រង់

តាមគោលការណ៍នេះ គូភាគីនៃកិច្ចសន្យាត្រូវតែគោរពនៅអ្វីដែលខ្លួនបានសំដែងឆន្ទៈមកខាងក្រៅដោយស្មោះត្រង់ ពោលគឺអនុវត្តដោយគ្មានកលល្បិចឡើយ ។ តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ ) មាត្រា ៥ បានចែងថា ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិតផ្អែកតាមភាពស្មោះត្រង់ ។

## ផ្នែកទី ៣ ៖ ចំណាត់ថ្នាក់នៃកិច្ចសន្យា

### ១.កិច្ចសន្យាដែលយកតម្លៃថ្នូរ

កិច្ចសន្យាដែលយកតម្លៃថ្នូរ គឺជាកិច្ចសន្យាដែលភាគីទាំងពីរមានកាតព្វកិច្ចផ្តល់នូវកម្រៃទៅវិញទៅមកដែលមានតម្លៃស្មើគ្នា។[5]

**ឧទាហរណ៍៖** កិច្ចសន្យាលក់ទិញភាគីអ្នកលក់មានកាតព្វកិច្ចប្រគល់វត្ថុរីឯអ្នកទិញមានកាតព្វកិច្ចប្រគល់ប្រាក់។

---

[4] មាត្រា ១៣១ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

[5] កិច្ចសន្យាពិសេស សាស្ត្រាចារ្យ ឆាយ ហុង ទំព័រ ៥

### ២.កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ

កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ គឺជាកិច្ចសន្យាដែលមានតែភាគីម្ខាងផ្តល់នូវកម្រៃ ចំណែកឯភាគីម្ខាងទៀត មិនមានកាតព្វកិច្ច ឬ មានបន្ទុកដែលមិនសមមូល។

**ឧទាហរណ៍៖** កិច្ចសន្យានេះ គឺភាគច្រើនជាប្រទានកម្ម។

ទាក់ទងនឹងកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ នៅក្នុងករណីនៃប្រទានកម្មគឺវាមានលក្ខណៈបន្ធូរបន្ថយចំពោះកាតព្វកិច្ចរបស់ទាយក មានន័យថា ជាគោលការណ៍ទាយកមិនចាំបាច់ទទួលខុសត្រូវចំពោះវិការៈដែលបានកើតមានឡើងដោយសារកិច្ចសន្យានេះទេ ។[6]

### ៣.កិច្ចសន្យាទ្វេភាគី

កិច្ចសន្យាទ្វេភាគី គឺជាកិច្ចសន្យាដែលភាគីទាំងពីរមានកាតព្វកិច្ចអនុវត្តកិច្ចសន្យាដែលមានតម្លៃសមមូលគ្នា។

**ឧទាហរណ៍៖** លោក ក បានផ្ញើពាក្យសន្យាមួយទៅឲ្យមិត្តភក្តិម្នាក់ឈ្មោះ ខ ថានឹងលក់ផ្ទះឲ្យទៅឈ្មោះ ខ ក្នុងតម្លៃ ២០០,០០០$USD (ម្ភៃម៉ឺនដុល្លារអាមេរិក)។ ឈ្មោះ ខ ផ្ញើពាក្យសន្យាប្រាប់ លោក ក ថាខ្លួនយល់ព្រមវិញ។

### ៤.កិច្ចសន្យាឯកតោភាគី

កិច្ចសន្យាឯកតោភាគី គឺជាកិច្ចសន្យាដែលមានតែភាគីម្ខាងមានកាតព្វកិច្ច ចំណែកភាគីម្ខាងមិនមានកាតព្វកិច្ច ឬ គ្រាន់តែមានបន្ទុកតែមានតម្លៃមិនសមមូល។ ប្រសិនបើភាគីម្ខាងទៀតមានបន្ទុក ក៏ប៉ុន្តែមានតម្លៃមិនសមមូល ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានមានចែងនូវមាត្រាដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគីដែរ ដូចជា : ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ការតវ៉ាអោយអនុវត្តព្រមគ្នា ការរំលាយកិច្ចសន្យា ។

**ឧទាហរណ៍៖** លោក ក បានដាក់ចុះផ្សាយក្នុងកាសែតថា លោកនឹងផ្តល់រង្វាន់ជាទឹកប្រាក់ចំនួន១លានដុល្លារដល់ ខ ក្នុងការដែលបានរកបកគំហើញថ្មីផ្នែកវិទ្យាសាស្ត្រ ដើម្បីអភិវឌ្ឍក្រុមហ៊ុនឲ្យបានរីកចម្រើនឈានដល់កម្រិតកំពូល។

---

[6] មាត្រា ៥៧៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

# ជំពូកទី ២

# ការបង្កើតកិច្ចសន្យា

# ជំពូកទី ២

# ការបង្កើតកិច្ចសន្យា

## ផ្នែកទី ១ ៖ គោលការណ៍នៃការបង្កើតកិច្ចសន្យា

### កថាភាគទី ១ ៖ ការព្រមព្រៀង

ការព្រមព្រៀង គឺជាឆន្ទៈរបស់ភាគីចុះកិច្ចសន្យា ដើម្បីបង្កើត និង ភ្ជាប់នូវកាតព្វកិច្ចផ្សេងៗរវាងគូភាគី ។ ក្នុងនោះផងដែលធាតុផ្សំដើម្បីបង្កើតការព្រមព្រៀងមាន ចំនួន២ធំៗគឺ ៖ សំណើ និង ស្វីការ ។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ ) មាត្រា ៣៣៦ កថាខណ្ឌទី១ បានចែងថាកិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា។

### កថាភាគទី ២ ៖ សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[7] សំណើត្រូវមានអានុភាព នៅពេលសំណើនោះបានដល់ភាគីម្ខាងទៀត ។[8]

ពាក្យថា បានទៅដល់ មានន័យថា វាមិនមានភាពចាំបាច់ដែលអ្នកទទួលសំណើ បានទទួលសំណើ ឬ បានបើកអានសំណើនោះទេ អ្វីដែលសំខាន់គឺ អោយតែបានទៅដល់ ។

#### ១.លក្ខខ័ណ្ឌនៃសំណើ

ក្នុងការបង្កើតសំណើមួយឲ្យមានសុពលភាព អ្នកដែលផ្តល់សំណើត្រូវបង្ហាញឆន្ទៈរបស់ខ្លួនឲ្យបានពិតប្រាកដ និង ជាក់លាក់ ថាខ្លួនពិតជាចង់បង្កើតសំណើនោះមែន។ លើសពីនេះទៅទៀត ខ្លឹមសារនៃសំណើក៏ត្រូវមានភាពជាក់លាក់ និងច្បាស់លាស់ផងដែរដូចជា៖ ការកំណត់នូវអត្តសញ្ញាណនៃគូភាគី តាវកាលិក និងពេលវេលាកំណត់ជាដើម។ សំណើអាចធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ឬ ដោយតណ្ហិភាព។

---

[7] មាត្រា ៣៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

[8] មាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

### ១.១.គោលបំណងពិតប្រាកដ

គោលបំណងពិតប្រាកដ ត្រូវកំណត់តាមពាក្យសំដី ឬ អំពើរបស់ភាគី ដែលជាមនុស្សប្រកបដោយគតិមានហេតុផលត្រឹមត្រូវ។ ប្រសិនបើអ្នកស្នើធ្វើសំណើ មានការភ័យខ្លាច ខឹង លេងសើចបញ្ចើចបញ្ចើ ញុះញង់សំណើបែបនេះ គឺគ្មានគោលបំណងច្បាស់លាស់ទេ ដែលជាហេតុមិនអាចចាត់ទុកជាសំណើមានប្រសិទ្ធភាពនោះទេ។[9]

### ១.២.ភាពច្បាស់លាស់នៃសំណើ

សំណើត្រូវតែមានខ្លឹមសារជាក់លាក់ច្បាស់លាស់និងសមហេតុផល នោះមានន័យថា សំណើត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រភេទនៃវត្ថុ បរិមាណ តម្លៃ គុណភាព ពេលវេលា ទីកន្លែង ជាដើម ។[10]

### ១.៣.ការជូនដំណឹងអំពីសំណើ

សំណើត្រូវមានអានុភាព នៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ដូច្នេះអ្នកធ្វើសំណើត្រូវតែបញ្ជូនសំណើឱ្យដល់អ្នកទទួលសំណើ តាមមធ្យោបាយដែលអ្នកធ្វើសំណើអាចធ្វើទៅបាន ។ នៅពេលដែលអ្នកទទួលសំណើមិនបានទទួលសំណើទេ នោះអ្នកទទួលសំណើក៏គ្មានសិទ្ធិដើម្បីធ្វើស្វីការតបនឹងសំណើនោះដែរ ដូច្នេះមានន័យថាគ្មានកិច្ចសន្យារវាងអ្នកធ្វើសំណើ និង អ្នកទទួលសំណើ ។

### ២. កាលកំណត់នៃសំណើ

សំណើអាចបង្កើតឡើងជា២ប្រភេទគឺ ៖ សំណើដែលមានកំណត់អំឡុងពេល និង សំណើដែលគ្មានកំណត់អំឡុងពេល។

### ២.១.សំណើដែលមានកំណត់អំឡុងពេល

សំណើ អាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ធ្វើការ ។ អំឡុងពេលសម្រាប់ធ្វើការត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ ។ សំណើ ដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសំរាប់ធ្វើការមិនអាចដកបានវិញទេ។

[9] កិច្ចសន្យាពិសេស មេធាវី ជ្រា ឈុនឡេង ទំព័រ ៤ ឆ្នាំ ២០១៨

[10] កិច្ចសន្យាពិសេស មេធាវី ជ្រា ឈុនឡេង ទំព័រ ៥ ឆ្នាំ ២០១៨

ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការក្នុងអំឡុងពេលដែលបានកំណត់សម្រាប់ស្វីការទេនោះ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ធ្វើការ ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ធ្វើការនោះ សំណើនោះក៏បាត់បង់អានុភាពដែរ។

**ឧទាហរណ៍៖** ក្រុមហ៊ុន លោក ក បានប្រកាសជ្រើសរើសបុគ្គលិកចំនួន ១៥ ថ្ងៃ។ ដូចនេះប្រសិនបើមិនទាន់ផុតរយៈពេល ១៥ ថ្ងៃនោះទេ ក្រុមហ៊ុនរបស់លោក ក មិនអាចដកសំណើរបស់ខ្លួនបានទេ។

### ២.២.សំណើដែលគ្មានកំណត់អំឡុងពេល

ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការវាងគូភាគីដែលកំពុងនិយាយគ្នានៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព។

**ឧទាហរណ៍៖** លោក ក បាននិយាយទៅកាន់ លោក ខ ថាចង់លក់ម៉ូតូ ១ គ្រឿង ក្នុងតម្លៃ ៣,០០០ ដុល្លារ តែលោក ខ មិនបានឆ្លើយតបទេ។

ចំពោះសំណើដែលធ្វើឡើងរវាងគូភាគីដែលមិននិយាយគ្នាដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។ ចំពោះអំឡុងពេលសមរម្យដែលកំណត់នៅក្នុងចំណុចនេះ យើងអាចវិនិច្ឆ័យទៅតាមខ្លឹមសារ និង ប្រភេទនៃកិច្ចសន្យា។

**ឧទាហរណ៍៖** ប្រសិនបើចំនួនទឹកប្រាក់ក្នុងកិច្ចសន្យាមានចំនួនច្រើន ឬ ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាគឺជាវត្ថុមានតម្លៃដូចជាអចលនវត្ថុ អំឡុងពេលសមរម្យនោះប្រហែលជាមានរយៈពេលវែង។ ប្រសិនបើជាកិច្ចសន្យាសាមញ្ញធម្មតា អំឡុងពេលនោះអាចមានរយៈពេលខ្លី។

ការដកសំណើត្រូវមានអានុភាព លុះត្រាតែជូនដំណឹងអំពីការដកសំណើនោះបានទៅដល់ភាគីម្ខាងទៀតមុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ ។

### ៣.ការបញ្ចប់សំណើ

សំណើអាចនឹងត្រូវបានបញ្ចប់ ដោយសារមូលហេតុខាងក្រោម ៖

- ការដកសំណើ ឬ ការលុបសំណើ
- ការបដិសេធសំណើដោយអ្នកទទួលសំណើ
- ហួសរយៈពេលកំណត់នៃសំណើ
- ម្ចាស់ដែលធ្វើសំណើទទួលមរណភាព
- កម្មវត្ថុនៃកិច្ចសន្យាត្រូវបានបំផ្លាញ ឬ ខូចខាត

## កថាភាគទី ៣ ៖ ស្វីការ

ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[11] ការធ្វើស្វីការនេះមានគោលបំណងក្នុងការភ្ជាប់ខ្លួនជាមួយអ្នកផ្តល់សំណើ នូវការទទួលយកនូវកាតព្វកិច្ចមួយចំនួនតាមផ្លូវច្បាប់ ។

**ឧទាហរណ៍៖** លោក ក យល់ព្រមលក់នូវទូរស័ព្ទមួយគ្រឿង ក្នុងតម្លៃ ៦០០,០០០៛ ឲ្យទៅលោក ខ ដែលបានស្នើទិញទូរស័ព្ទនោះ។ នៅពេល លោក ក ធ្វើការឆ្លើយតបដោយបង្កើតនូវស្វីការនេះឡើង មានន័យថា កិច្ចសន្យារវាងអ្នកទាំងពីរបានចាប់ផ្តើមនៅពេល លោក ខ បានទទួលនូវស្វីការនោះ។

### ១. លក្ខខណ្ឌនៃស្វីការ

ស្វីការមួយមានអានុភាព នៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកស្វីការនោះវិញបានទៅដល់អ្នកស្នើនៅពេលព្រមគ្នានឹងពេលដែលស្វីការបានទៅដល់ ឬ មុនពេលស្វីការបានទៅដល់ នោះអានុភាពនៃស្វីការមិនត្រូវបានកើតឡើងឡើយ។[12] ជាធម្មតា អ្នកធ្វើស្វីការត្រូវយល់ព្រមទាំងស្រុងនូវរាល់ចំណុចដែលមានកំណត់នៅក្នុងសំណើ។ ស្វីការត្រូវធ្វើឡើងឲ្យទាន់ពេលមុនសំណើរលត់ ស្វីការត្រូវតែបញ្ជូនឲ្យដល់អ្នកធ្វើសំណើ ឬ ឲ្យបានដល់អ្នកស្នើ ។ លើសពីនេះទៅទៀតដូចទៅនឹងសំណើដែរ ស្វីការអាចធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ឬ ដោយតណ្ហីភាព។

[11] មាត្រា ៣៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

[12] មាត្រា ៣៣៧ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

### ១.១.អ្នកមានសិទ្ធិក្នុងការផ្តល់ស្វីការ

មានតែអ្នកទទួលសំណើតែប៉ុណ្ណោះ ទើបអាចធ្វើស្វីការចំពោះសំណើនោះ ក្នុងគោលបំណងបង្កើត កិច្ចសន្យាមួយបាន។ លើកលែងតែការតំណាង ឬ ជនដែលត្រូវបានកម្រិតសមត្ថភាព។[13]

### ១.២.ការជូនដំណឹងអំពីស្វីការ

ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ កិច្ចសន្យាកើតឡើងនៅពេលដែលសំណើជួបនឹងស្វីការ។ ដូច្នេះប្រសិនបើអ្នកទទួលសំណើចង់បង្កើតកិច្ចសន្យានោះគាត់ត្រូវធ្វើយ៉ាងណាបញ្ជូនស្វីការរបស់គាត់ឱ្យបានទៅដល់ភាគីអ្នកធ្វើសំណើ។

### ១.៣.ស្វីការត្រូវតែធ្វើមុនពេលសំណើរំលត់

ប្រសិនបើសំណើត្រូវបានគេរំលត់មុនពេលស្វីការកើតឡើងនោះគ្មានកិច្ចសន្យាដែលមានសុពលភាពកើតឡើងទេ ដោយហេតុថាកិច្ចសន្យាដែលមានសុពលភាពត្រូវកើតឡើងដោយសារការជួបគ្នារវាងសំណើដែលមានសុពលភាពនឹងស្វីការការដែលមានសុពលភាព។ ប្រសិនបើគូភាគីកំពុងតែនិយាយទល់មុខគ្នា នោះនឹងមានភាពងាយស្រួលកំណត់ថា ពេលណាសំណើនឹងត្រូវរំលត់តែប្រសិនបើភាគីបានធ្វើទំនាក់ទំនងជាមួយគ្នាពីចម្ងាយនោះវានឹងមានភាពពិបាកក្នុងការកំណត់ថាពេលណាសំណើនឹងត្រូវរំលត់។ អ្នកស្នើអាចចាត់ទុកថាស្វីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្វីការគឺជាសំណើថ្មី ។[14]

## កថាភាគទី ៤ ៖ វិការៈនៃការព្រមព្រៀង

ជាគោលការណ៍កិច្ចសន្យាមួយអាចមានសុពលភាពតាមផ្លូវច្បាប់លុះត្រាតែកិច្ចសន្យាមួយនោះត្រូវបានកើតឡើងដោយមានការព្រមព្រៀងនិងឆន្ទៈពិតប្រាកដរវាងភាគីទាំងពីរនៃកិច្ចសន្យាដោយហេតុថាដំណាក់កាលនៃការបង្កើតកិច្ចសន្យា ភាគីទាំងសងខាងដែលធ្វើសំណើ និង ស្វីការ ត្រូវបានបញ្ជាក់ថាធ្វើដោយតណ្ហីភាព គឺសំដៅដល់ឆន្ទៈច្បាស់លាស់ និង ស្មៀមស្ងាត់ ។ ប្រសិនបើកិច្ចសន្យាមួយមានវិការៈនៃការព្រមព្រៀង ភាគីអាចលុបចោលកិច្ចសន្យានោះបាន ។ វិការៈនៃការព្រមព្រៀងមានដូចជា ការភ័ន្តច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព អំពើកេងចំណេញហួសហេតុ និង ការគម្រាមកំហែង ។

---

[13] កិច្ចសន្យាពិសេស មេធាវី ជ្រា ឈុនឡេង ទំព័រ ១៣ ឆ្នាំ ២០១៨

[14] មាត្រា ៣៤២ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧)

### ១.ការភ័ន្តច្រឡំ

ការភ័ន្តច្រឡំនៃការព្រមព្រៀងរបស់កិច្ចសន្យា គឺជាការព្រមព្រៀងមិនពិតប្រាកដ បើមិនមានការភ័ន្តច្រឡំនោះទេ ភាគីដែលភ័ន្តច្រឡំប្រាកដជាមិនចុះកិច្ចសន្យាឡើយ។ ចំពោះការភ័ន្តច្រឡំនេះដែរបើសិនជាការភ័ន្តច្រឡំនោះមិនបានចាត់ទុកថាជាចំណុចសំខាន់ក្នុងកិច្ចសន្យានោះទេ គេមិនអាចបដិសេធអានុភាពនៃកិច្ចសន្យាឡើយ។

**ឧទាហរណ៍ ៖** ក្នុងករណីការបញ្ជាទិញទំនិញតាមប្រព័ន្ធអនឡាញ នៅពេលភាគីលក់ទំនិញទទួលបានប្រាក់ដែលភាគីទិញបានផ្ញើជូនហើយ ក៏បានថានឹងផ្ញើទំនិញតាមក្រុមហ៊ុនដឹកជញ្ជូន ក តែនៅពេលដែលអ្នកលក់ដឹកទំនិញចេញពីហាងទៅដាក់ផ្ញើ ក៏បានយកទំនិញទៅដាក់ផ្ញើតាមរយៈក្រុមហ៊ុន ខ ទៅវិញ។ ប៉ុន្តែក្នុងរយៈពេលដែលបានបញ្ជាក់ដោយអ្នកលក់ ភាគីអ្នកទិញ ក៏បានទទួលទំនិញដោយគ្មានការខូចខាតទាំងអស់ ដូចនេះភាគីទាំងសងខាងមិនអាចបដិសេធអានុភាពនៃកិច្ចសន្យាបាននោះឡើយ ដោយហេតុថាគ្រាន់តែមានការភ័ន្តច្រឡំតែបន្តិចប៉ុណ្ណោះ។ ទាល់តែក្នុងករណី ដែលភាគីមានការភ័ន្តច្រឡំអំពីចំណុចសំខាន់ៗក្នុងកិច្ចសន្យា ដែលអាចមានការប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ ទើបគេអាចទទួលស្គាល់ការលុបចោលកិច្ចសន្យា ដោយមូលហេតុនៃភ័ន្តច្រឡំបាន។

**ឧទាហរណ៍ ៖** ក្នុងកិច្ចសន្យាលក់-ទិញ នូវរថយន្តមួយគ្រឿង ករណីដែលភាគីអ្នកទិញច្រឡំនិយាយថា ទិញក្នុងតម្លៃ ១០០,០០០ ដុល្លារ តែឆន្ទៈពិតប្រាកដ គឺគាត់ចង់ទិញត្រឹមតម្លៃ ១០,០០០ ដុល្លារប៉ុណ្ណោះ។

### ២.ការឆបោក

ការឆបោក គឺជាអំពើមួយដែលភាគីម្ខាងនៃកិច្ចសន្យា ជំរុញអោយភាគីម្ខាងទៀត សំដែងឆន្ទៈព្រមព្រៀងចុះកិច្ចសន្យា ដោយមានការភូតភរ រឺ ប្រើប្រាស់ឧបាយកលផ្សេងៗ ឬ ការបញ្ឆោត ។ ឥទ្ធិពលនៃកិច្ចកលទាំងនោះនាំអោយភាគីរងគ្រោះផ្តល់ការយល់ព្រម ព្រមព្រៀងលើកិច្ចសន្យាដោយមិនដឹងខ្លួន ។[15]

**ឧទាហរណ៍៖** ម្ចាស់យានដ្ឋានលក់រថយន្តបានលួចបង្វិលប្តូរលេខកុងទ័រនៃរថយន្តអោយនៅតិច ដោយធ្វើអោយអតិថិជនរបស់គាត់ជឿថារថយន្តនោះប្រើប្រាស់បានតិច ព្រមព្រៀងទិញយកទៅប្រើប្រាស់ ។

[15] នីតិកិច្ចសន្យា ជិន វណ្ណារ៉ា ទំព័រ ៧៦-៧៧

### ៣.ព័ត៌មានមិនពិត

ព័ត៌មានមិនពិត គឺសំដៅទៅលើករណីដែលភាគីនៃកិច្ចសន្យាបានលើកឡើងនូវចំណុចដែលជាមូលដ្ឋានគ្រឹះនៃការបង្កើតកិច្ចសន្យាមានលក្ខណៈខុសពីការពិត ។ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈព្រមព្រៀងដោយជឿជាក់ថាហេតុទាំងនោះជាការពិត ។ ប៉ុន្តែប្រសិនបើភាគីនោះបានដឹងថាហេតុនោះមិនមែនជាការពិតខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។ នៅក្នុងករណីនៃព័ត៌មានមិនពិត គេតម្រូវឲ្យភាគីម្ខាងទៀតមិនបានដឹងថាហេតុដែលគាត់លើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើគាត់ដឹងហើយថាហេតុនោះខុសពីការពិតតែគាត់ព្យាយាមកុហកលាក់បាំង គេត្រូវបានចាត់ទុកថាជាការឆបោក ។

**ឧទាហរណ៍៖** លោក ក បានលក់រថយន្តមួយគ្រឿង ក្នុងតម្លៃ ៥០,០០០$ (ប្រាំម៉ឺនដុល្លារ) ទៅ ឲ្យលោក ខ ដោយបានប្រាប់ថារថយន្តនេះ នាំចូលមកពីសហរដ្ឋអាមេរិក ក៏ប៉ុន្តែ ប្រភពនៃរថយន្តនេះពិតប្រាកដ គឺនាំចូលមកពីប្រទេសអារ៉ាប់។ បន្ទាប់ពី លោក ខ បានដឹងអំពីព័ត៌មាននេះ គាត់ក៏បានលុបចោលកិច្ចសន្យា ដោយផ្អែកទៅលើព័ត៌មានរបស់លោ ក ជាព័ត៌មានមិនពិត។ លោក ក ក៏មិនបានដឹងច្បាស់ពិតប្រាកដដែរថា រថយន្តនេះមានប្រភពមកពីប្រទេសអារ៉ាប់ដែលមិនមែនមកពីសហរដ្ឋអាមេរិក។ នៅក្នុងករណីនេះគេអាចនិយាយថាព័ត៌មានដែលលោកក៏បានប្រាប់នោះគឺជាព័ត៌មានមិនពិត ប៉ុន្តែបើសិនជានៅក្នុងករណីដែលលោក ក បានដឹងពីដំបូងហើយថារថយន្តមួយនោះមានប្រភពមកពីប្រទេសអារ៉ាប់ទេ តែគាត់នៅតែប្រាប់លោក ខ ថាមកពីសហរដ្ឋអាមេរិកទៀតនោះ ក្នុងករណីនេះគេចាត់ទុកថាជាការឆបោក។

### ៤.ការរំលោភបំពានលើស្ថានភាព

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើភាពមិនត្រឹមត្រូវនៃឋានៈខ្លួនដែលមានអាទិភាពជាង ភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងៗទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបតបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[16]

[16] មាត្រា ៣៤៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧)

### ៥.អំពើកេងចំណេញហួសហេតុ

អំពើកេងចំណេញហួសហេតុ សំដៅទៅលើករណីដែលភាគីម្ខាង បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាក ខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះការពិសោធន៍ ហើយ បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[17]

### ៦.ការគំរាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគំរាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់ តតិយជន អាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[18] ចំពោះការគំរាម កំហែង គឺអាចជាការគំរាមកំហែងខាងផ្លូវកាយ ផ្លូវចិត្តទៅលើភាគីណាមួយ ប្តី ឬ ប្រពន្ធ បុព្វញាតិ ឬ បច្ឆាញាតិ របស់ភាគីណាមួយ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាទិញលក់អចលនទ្រព្យមួយកន្លែង លោក ក ដែលជាអ្នកមានបំណង ចង់ទិញដី នោះពីលោក ខ គាត់បានប្រើប្រាស់នូវសកម្មភាពដែលមានលក្ខណៈគំរាមកំហែងទៅលើលោក ខ ដោយសម្លុត ថានឹងតាមធ្វើបាបក្រុមគ្រួសារ លោក ខ ប្រសិនបើ លោក ខ មិនលក់អចលនទ្រព្យមួយនោះឲ្យទៅខ្លួនក្នុងតម្លៃ ទាបមួយដែលខ្លួនចង់បាន ។ នៅក្នុងករណីនេះលោក ខ ដែលជាម្ចាស់អចលនទ្រព្យនោះ បានបង្ហាញឆន្ទៈ របស់ខ្លួនខុសពីឆន្ទៈពិតប្រាកដ លោក ខ អាចលុបចោលនូវកិច្ចសន្យានោះបានដោយហេតុថាគាត់ត្រូវបាន គំរាមកំហែងពីលោក ក ដែលជាអ្នកចង់ទិញ ។

---

[17] មាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧)

[18] មាត្រា ៣៥០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧)

## ផ្នែកទី ២ ៖ កម្មវត្ថុនៃកិច្ចសន្យា

កិច្ចសន្យាមួយនឹងមានសុពលភាពនៅពេលដែលកាតព្វកិច្ចបានកើតឡើងពីកិច្ចសន្យានោះជាកម្មវត្ថុមួយជាក់លាក់អាចធ្វើកើតនិងស្របច្បាប់ មានរបៀបរៀបរយសាធារណៈ ឬ ទំនៀមទម្លាប់ល្អរបស់ប្រពៃណី។ កម្មវត្ថុនៃកិច្ចសន្យាគឺជាកាតព្វកិច្ច ឯកម្មវត្ថុនៃកាតព្វកិច្ចគឺជាតាវកាលិក (អំពើ ឬ វត្ថុ) ។ ក្នុងនោះផងដែរកម្មវត្ថុនៃកិច្ចសន្យាត្រូវតែជាក់លាក់ មានន័យថាភាគីកិច្ចសន្យាត្រូវតែយល់ច្បាស់ពីអ្វីដែលខ្លួនបានសន្យាចំពោះកិច្ចសន្យា ដែលមានកម្មវត្ថុជាតាវកាលិកចេញពីអំពើរបស់មនុស្ស។ កម្មវត្ថុជាក់លាក់ ក៏មានន័យថាជាកម្មវត្ថុត្រូវតែមាននៅពេលបច្ចុប្បន្នដែរ ដូច្នេះប្រសិនបើកម្មវត្ថុមិនមាននៅពេលចុះកិច្ចសន្យាដោយសារវត្ថុនោះបានបាត់បង់ កិច្ចសន្យានឹងពុំមានសុពលភាពឡើយ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាមួយដែលកម្មវត្ថុនៃកិច្ចសន្យា គឺតម្រូវឲ្យភាគីនៃកិច្ចសន្យា ធ្វើការដឹកជញ្ជូនទំនិញក្នុងចំងាយដី ១,០០០ គីឡូម៉ែត្រ ដោយប្រើរយៈពេល ១០ នាទី។ ត្រង់ចំណុចនេះនឹងអាចឃើញថា កម្មវត្ថុនៃកិច្ចសន្យាគឺមិនអាចសំរេចទៅបានទេ ដោយវាមានលក្ខណៈហួសឆ្ងាយខ្លាំងធៀបទៅនឹងការពិត ដែលគ្មាននរណាម្នាក់អាចសំរេចបានឡើយ។

### កថាភាគទី ១ ៖ ភាពស្របច្បាប់ ឬ ភាពមិនផ្ទុយនឹងការអនុវត្តដោយបង្ខំ

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ នោះវាត្រូវបានចាត់ទុកជាមោឃៈ។[19] បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺសំដៅទៅលើបញ្ញត្តិដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិនេះ។

**ឧទាហរណ៍៖** នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា ភាគីម្ខាងនៃកិច្ចសន្យា មិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់បានបង្ហាញឆន្ទៈដោយសារការភ័ន្តច្រឡំក៏ដោយ ។ ការព្រមព្រៀងបែបនេះត្រូវបានចាត់ទុកជាមោឃៈ ព្រោះវាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

[19] មាត្រា ៣៥៤ កថាខណ្ឌទី ១ ចំណុច ក នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ( ឆ្នាំ ២០០៧ )

## កថាភាគទី ២ ៖ ភាពមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ

លក្ខខណ្ឌនេះសំដៅទៅលើភាពមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទំលាប់ល្អ ដែលវាចាំបាច់តម្រូវឲ្យកម្មវត្ថុនោះស្របទៅនឹងស្ថានភាពសង្គម មានន័យថា ទោះជាការបង្ហាញឆន្ទៈរបស់គូភាគីគ្មានវិការៈក៏ដោយក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈដែរ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម និង ទំនៀមទំលាប់ល្អ។

**ឧទាហរណ៍៖** ប្រសិនបើបុរសម្នាក់ដែលមានប្រពន្ធហើយ បានចុះកិច្ចសន្យាជាមួយនារីម្នាក់ទៀត ដើម្បីបានរួមភេទជាមួយនាង និងបង់ប្រាក់កម្រៃឲ្យនាងនោះ កិច្ចសន្យានេះត្រូវបានចាត់ទុកជាមោឃៈ ដោយសារអត្ថន័យនៃកិច្ចសន្យានេះផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ទោះបីជាគ្មានច្បាប់ហាមឃាត់កិច្ចសន្យាបែបនេះក៏ដោយ។

## ផ្នែកទី ៣ ៖ សមត្ថភាពចុះកិច្ចសន្យា

សមត្ថភាពគឺជាសម្បទារបស់បុគ្គលម្នាក់ៗដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការធ្វើអ្វីមួយដែលច្បាប់តម្រូវឲ្យធ្វើ ឬ ទទួលស្គាល់ថាអាចមានគុណសម្បត្តិនិងធ្វើបាន។ នៅក្រោមប្រព័ន្ធច្បាប់ Common law និង ប្រព័ន្ធច្បាប់ Civil law ភាគីនានានៃកិច្ចសន្យាសុពលភាពមួយត្រូវមានសមត្ថភាពតាមផ្លូវច្បាប់ដើម្បីចុះកិច្ចសន្យា ។ គោលបំណងនៃការកំណត់សមត្ថភាពនេះ គឺការពារជនដែលគ្មានសមត្ថភាព កុំឲ្យគេកេងយកនូវប្រយោជន៍ ដោយសារតែមានស្មារតីមិនពេញលេញ ដោយសារអាយុ ឬ ដោយសារពិការបញ្ញាស្មារតី។

### កថាភាគទី១៖ ជនដែលអាចចុះកិច្ចសន្យា

ជាទូទៅ បុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់អាចនឹងធ្វើកិច្ចសន្យាសុពលភាពមួយបាន កាលណាបុគ្គលនោះមានសមត្ថភាពអាចយល់ដឹងអំពីលក្ខណៈនៃការធ្វើកិច្ចសន្យា ហើយអាចគ្រប់គ្រងលើសកម្មភាពនានារបស់ខ្លួនក្នុងការធ្វើកិច្ចសន្យានោះ ហើយអាចដឹងមុនពីលទ្ធផលនៃអំពើ បន្ថែមពីលើនោះទៅទៀតច្បាប់ក៏អនុញ្ញាតឲ្យគេអាចបង្កើតសិទ្ធិ និង កាតព្វកិច្ចផងដែរ។

#### ១.នីតិជន

តាមន័យទូទៅនីតិជន គឺជាបុគ្គលដែលមានអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។[20] ដោយឡែកបើផ្អែកទៅលើក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ នីតិជនមានន័យថាជនដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ ។ ក្នុងការបង្កើតកិច្ចសន្យា នីតិជនត្រូវបានកំណត់ថាជាជនដែលមានសមត្ថភាពពេញលេញទាំងស្រុងក្នុងការសំរេចចិត្ត និងធ្វើការបង្ហាញឆន្ទៈចុះកិច្ចសន្យាមួយបាន។ ជាទូទៅប្រភេទនៃមនុស្សមួយចំនួន មិនអាចមានសមត្ថភាពពេញលេញក្នុងការធ្វើកិច្ចសន្យាបានទេ ប៉ុន្តែមានករណីមួយចំនួនទៀត ដែលច្បាប់អនុញ្ញាតឲ្យជនដែលមិនមានសមត្ថភាពទាំងនោះ ដូចជា អនីតិជន ឬ អសមត្ថជន អាចមានសិទ្ធិចុះកិច្ចសន្យាបានគឺមានដូចជា៖

[20] សទ្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២. អនីតិជនដែលមានអត្តាធីនភាព

អនីតិជនដែលមានអត្តាធីនភាព មានន័យថាជាអនីតិជនដែលមានអាយុដល់ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពរបស់ខ្លួនដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមរយៈពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថាអត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះតុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។[21] ក្រៅពីនេះទៀតគឺ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយទទួលអត្តាធីនភាពដោយមិនចាំបាច់មានសេចក្តីប្រកាសពីតុលាការទេ ។ ចំពោះអានុភាពនៃអត្តាធីនភាពគឺ អនីតិជនដែលទទួលនូវអត្តាធីនភាពត្រូវចាត់ទុកថាបានដល់នីតិភាព។[22] តាមការបកស្រាយខាងលើ អនីតិជនដែលមានអត្តាធីនភាពអាចចុះកិច្ចសន្យាបាន។

### ៣. អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

អនីតិជនដែលបានទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជនចំពោះមុខជំនួញនោះ។ ដូចនេះក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាមានលក្ខណៈទាក់ទងទៅនឹងមុខជំនាញរបស់អនីតិជននោះ ហើយអនីតិជនម្នាក់នោះមានសមត្ថភាពគ្រប់គ្រាន់ដើម្បីអនុវត្តកាតព្វកិច្ចតាមការកំណត់ក្នុងកិច្ចសន្យាបាន នោះគេអាចចុះកិច្ចសន្យា ឬ បង្កើតកិច្ចសន្យានោះបាន ។ ប្រសិនបើបានដឹងច្បាស់ថាអនីតិជននោះមិនអាចបំពេញភារៈកិច្ច ឬ កិច្ចការអាជីវកម្មនោះបានទេ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ អាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន។

[21] មាត្រា ២១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[22] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## កថាភាគទី២៖ ជនដែលមិនអាចចុះកិច្ចសន្យា

ចំពោះបុគ្គលដែលខ្វះប្រការណាមួយនៃបញ្ញាស្មារតី ឬ អាយុ ជាបុគ្គលដែលអសមត្ថភាពក្នុងការធ្វើកិច្ចសន្យា តាមកំណត់ច្បាប់បុគ្គលនោះមិនអាចធ្វើការចុះកិច្ចសន្យាសុពលភាពមួយបានទេ។ ជនទាំងនោះត្រូវបានចាត់ទុកថាជាអសមត្ថជនក្នុងការចុះកិច្ចសន្យា។ អសមត្ថជន គឺជាជនដែលគ្មានសមត្ថភាពក្នុងការធ្វើអ្វីមួយដែលច្បាប់ហាមឃាត់ បានន័យថា អសមត្ថជននោះ ទោះបីជាមានអាយុលើ ១៨ឆ្នាំ ក៏ដោយ ក៏មិនអាចចុះកិច្ចសន្យា បង្កើតសិទ្ធិ និង ករណីយកិច្ចបានឡើយ ដោយហេតុថាសិទ្ធិតាមផ្លូវច្បាប់របស់ជននោះត្រូវបានកំណត់ដូចជា ៖ អនីតិជននៅក្រោមអំណាចមេបា ជននៅក្រោមហិតូបត្ថម្ភ និង ជនដែលនៅក្រោមអាណាព្យាបាលទូទៅ

### ១.អនីតិជននៅក្រោមអំណាចមេបា

ជនដែលត្រូវបានកម្រិតសមត្ថភាពទីមួយគឺ អនីតិជន។ អនីតិជនសំដៅទៅលើជនដែលមិនទាន់ដល់នីតិភាព ពោលគឺមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ។ ជាគោលការណ៍អនីតិជនមិនអាចធ្វើសកម្មភាពគតិយុត្តិដោយឯករាជ្យបានទេ ជារួមសកម្មភាពដែលបានធ្វើឡើងដោយឯករាជ្យអាចត្រូវបានលុបចោល។ ដើម្បីឲ្យអនីតិជនអាចធ្វើសកម្មភាពបាន ចាំបាច់ត្រូវធ្វើសកម្មភាពតាមរយៈអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន ឬ អនីតិជនខ្លួនឯងអាចធ្វើសកម្មភាពគតិយុត្តបានក្រោយទទួលការយល់ពីអ្នកតំណាងដែលច្បាប់បានកំណត់ ប៉ុន្តែជាករណីលើកលែងអនីតិជនត្រូវបានទទួលស្គាល់ឲ្យធ្វើសកម្មភាពឯករាជ្យចំពោះសកម្មភាពទាំងឡាយណាដែលមិនសូវសំខាន់។

**ឧទាហរណ៍៖** ការទិញនំចំណីអាហារធម្មតា។

### ២.ជននៅក្រោមហិតូបត្ថម្ភ

ជាទូទៅជននៅក្រោមហិតូបត្ថម្ភសំដៅទៅលើជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ក្នុងករណីជនដែលមានលក្ខខណ្ឌដូចបានរៀបរាប់ខាងលើ អាចធ្វើការដាក់ពាក្យសុំទៅតុលាការតាមរយៈ សាមីខ្លួន សហព័ទ្ធ ឬ ញាតិដែលស្ថិតក្នុង(៤) បួនថ្នាក់ ឬ អាណាព្យាបាលជាដើម ដើម្បីឲ្យចាប់ផ្តើមប្រកាសហិតូបត្ថម្ភនោះបាន ។ តាមន័យនេះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភមិនអាចធ្វើកិច្ចសន្យាសុពលភាពបានទេ ដោយមូលហេតុគឺការខ្វះសមត្ថភាពយល់ដឹងអំពីអំពើរបស់ខ្លួនដូចដែលមានបញ្ជាក់នៅក្នុងមាត្រា ២៨ នៃក្រមរដ្ឋវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

### ៣.ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ តុលាការអាចប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមរយៈពេលសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុងបួនថ្នាក់ អាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ ឆ្នាំ (ដប់ប្រាំឆ្នាំ) នៅពេលដែលមានពាក្យសុំ ។

**ឧទាហរណ៍** ៖ ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងរៀងរាល់ថ្ងៃទាក់ទងនឹងចំណុចដូចជា ឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួននៅជាដើម ឬ ក៏ជាជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ ( ជនដែលមានបញ្ហាស្លាប់ខួរក្បាលជាដើម ) ។ ជនទាំងនេះ គឺសុទ្ធតែជាជននៅក្រោមអាណាព្យាបាលទូទៅ ។ ដោយសារតែជនប្រភេទនេះមិនមានសមត្ថភាពគ្រប់គ្រាន់ផ្នែកស្មារតី ទើបច្បាប់កំណត់ឲ្យជននេះមិនអាចចុះកិច្ចសន្យាសុពលភាពបាននោះទេ។

## ផ្នែកទី ៤ ៖ លក្ខខណ្ឌទម្រង់កិច្ចសន្យា

ជាទូទៅកិច្ចសន្យាទាំងឡាយអាចត្រូវដាក់ឲ្យប្រតិបត្តិតាមបាន ទោះបីកិច្ចសន្យានោះជាទម្រង់យថាភូត (ការសរសេរ ឬ ជាពាក្យពេចន៍) ឬ (ចេញពីអំពើ) ក៏ដោយក៏កិច្ចសន្យានោះនៅតែអាចដាក់ឲ្យប្រតិបត្តិបានដែរ។ កិច្ចសន្យាយថាភូតអាចជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ ។ យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ កិច្ចសន្យាមានអានុភាពដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករបស់ភាគីទាំងពីរតែប៉ុណ្ណោះ ពីព្រោះថាជាគោលការណ៍ការព្រមព្រៀងគ្នាទៅវិញទៅមកគឺជាកត្តាចាំបាច់សម្រាប់ការបង្កើតកិច្ចសន្យា ហើយក្រៅពីការព្រមព្រៀងនោះ ច្បាប់មិនតម្រូវឲ្យមានលក្ខខណ្ឌផ្សេងទៀតទេ។

ទោះបីជាយ៉ាងនេះក៏ដោយក៏ច្បាប់តម្រូវឲ្យមានលក្ខខណ្ឌបន្ថែម ចំពោះការបង្កើតកិច្ចសន្យាមួយចំនួន ដូចជា កិច្ចសន្យាប្រគល់វត្ថុ (កិច្ចសន្យាដែលត្រូវបានបង្កើតដោយការប្រគល់វត្ថុ) ឬ ការរៀបចំលិខិតដែលជាលក្ខខណ្ឌចាំបាច់បន្ថែមលើការព្រមព្រៀងគ្នាទៅវិញទៅមក ។ តាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៣៣៦ កថាខណ្ឌទី២ កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននៃកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុនោះនឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។

### ១.កិច្ចសន្យាធ្វើដោយផ្ទាល់មាត់

កិច្ចសន្យាផ្ទាល់មាត់ជាទូទៅ អាចដាក់ឲ្យប្រតិបត្តិបានដូចគ្នានឹងកិច្ចសន្យាលាយលក្ខណ៍អក្សរដែរ ហើយកិច្ចសន្យាទាំងនោះអនុវត្តច្រើនជាងគេសម្រាប់បញ្ហាសាមញ្ញតូចៗក្នុងការរស់នៅប្រចាំថ្ងៃ។

**ឧទាហរណ៍៖** កិច្ចសន្យាទិញទឹកបរិសុទ្ធមួយដបក្នុងតម្លៃ ១,០០០ រៀល គឺសុទ្ធតែធ្វើឡើងដោយផ្ទាល់មាត់ ។

### ២.កិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ

ទោះបីជាការបង្កើតកិច្ចសន្យា អាចធ្វើឡើងដោយផ្ទាល់មាត់យ៉ាងណាក៏ដោយ តែបណ្ដាយុត្តាធិការជាច្រើនពិតជាតម្រូវឲ្យប្រភេទនៃកិច្ចសន្យាសំខាន់ៗមួយចំនួន ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ទើបអាចដាក់ឲ្យប្រតិបត្តិបាន។ លើសពីនេះទៅទៀតភាគីទាំងឡាយនៃកិច្ចសន្យា គួរតែធ្វើកិច្ចសន្យាសំខាន់ៗទាំងអស់ជាលាយលក្ខណ៍អក្សរ ទោះបីមិនមានច្បាប់តម្រូវក៏ដោយ ព្រោះការសរសេរនោះនាំឲ្យមានការលើកទឹកចិត្តដល់គូភាគីនៃកិច្ចសន្យាឲ្យមានភាពច្បាស់លាស់ពេញលេញឡើងថែមទៀតក្នុងការធ្វើកិច្ចសន្យារបស់ពួកគេ និង ផ្ដល់ភស្តុតាងយ៉ាងមុតមាំ ដើម្បីការពារផលប្រយោជន៍របស់ពួកគេនៅក្នុងការបង្កើតកិច្ចសន្យា។ ជាទូទៅកិច្ចសន្យាអាចធ្វើជា លិខិតយថាភូត និង លិខិតឯកជន ជាលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា។

#### ២.១.លិខិតយថាភូត

លិខិតយថាភូត ជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ ឬ តាមន័យចង្អៀតលិខិតទាំងឡាយដែលរៀបចំឡើងដោយសាការី។[23]

#### ២.២.លិខិតឯកជន

លិខិតឯកជន ជាលិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជនដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃ។[24]

[23] សទ្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[24] សទ្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

# ជំពូកទី ៣
# អានុភាពនៃកិច្ចសន្យា

# ជំពូកទី ៣

## អានុភាពនៃកិច្ចសន្យា

ដោយផ្អែកលើមូលដ្ឋាននៃការព្រមព្រៀងគ្នារវាងភាគីទាំងសងខាង អានុភាពនៃកិច្ចសន្យា បង្កើតឱ្យមានចំណងកាតព្វកិច្ចរវាងភាគី (ត្រូវតែអនុវត្តតាមកិច្ចសន្យា) ។[25] ដូច្នេះនៅពេលដែលភាគីម្ខាងមិនអនុវត្តតាមកិច្ចសន្យា ភាគីម្ខាងទៀតអាចប្ដឹងទៅតុលាការបង្ខំឱ្យអនុវត្តតាម ឬ មួយក៏តម្រូវឱ្យបង់សំណងចំពោះការខូចខាតជំនួសឱ្យការធ្វើសកម្មភាពដែលបានសន្យាពីដំបូងទី (លើកលែងតែនៅក្នុងកិច្ចសន្យានោះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាពិសេសថាគ្មានការបង្ខិតបង្ខំឱ្យអនុវត្តតាមទេនោះ)។ ការកកើតកិច្ចសន្យាមួយឡើងបានបង្កើតឱ្យមាននូវអានុភាពនៃចំណង ដែលចងភ្ជាប់ទំនាក់ទំនងគតិយុត្តរវាងភាគីនៃកិច្ចសន្យា ហើយនៅក្នុងទំនាក់ទំនងគតិយុត្តនៃកិច្ចសន្យានោះ ក៏បានបង្កប់នូវសិទ្ធិនិងករណីកិច្ចមួយចំនួនចំពោះគូភាគីផងដែរ ។ ជាក់ស្ដែងក្នុងមាត្រា ២២ នៃក្រឹត្យច្បាប់លេខ ៣៨ ក៏បានបញ្ជាក់ពី អានុភាពនៃកិច្ចសន្យាថា កិច្ចសន្យាមួយអាចមានអានុភាពតែទៅលើភាគីនៃកិច្ចសន្យាប៉ុណ្ណោះ។ ក៏ប៉ុន្តែជាគោលការណ៍អានុភាពនៃកិច្ចសន្យាគឺជាអានុភាពដោយធៀបដែលមិនត្រឹមចងតែភាគីក្នុងកិច្ចសន្យាតែប៉ុណ្ណោះទេ ផ្ទុយទៅវិញកិច្ចសន្យាក៏អាចមានអានុភាពចំពោះតតិយជនផងដែរ បើយោងតាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។ គេក៏អាចធ្វើកិច្ចសន្យាដោយផ្ដល់ផលប្រយោជន៍ទៅជនទី ៣ បាន ដែរ ។

**ឧទាហរណ៍ ៖** នៅក្នុងការលក់ទិញរវាងឈ្មោះ ក និង ឈ្មោះ ខ ដោយក្នុងកិច្ចសន្យានោះមានបន្ថែមអំពីការព្រមព្រៀងគ្នាថា ប្រាក់ថ្លៃទំនិញនោះត្រូវបង់ផ្ទាល់ទៅជនទី ៣ ឈ្មោះ គ (កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជននឹងមានអធិប្បាយនៅខាងក្រោយ។ ចាប់ពីមាត្រា ៥៣៧តទៅ ក៏ប៉ុន្តែនេះមិនមែនមានន័យថាជាការព្រមព្រៀងគ្នាដាក់ករណីយកិច្ចលើជនទី៣នោះឡើយ ។)

ចំពោះកិច្ចសន្យាឧបតោភាគី ច្បាប់បានកំណត់ឱ្យមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាដោយផ្អែកលើអានុភាពនៃវត្តមានរបស់កិច្ចសន្យា។[26]

**ឧទាហរណ៍ ៖** ក្នុងការទិញលក់ជាដើមអ្នកទិញអាចតវ៉ា ( ធ្វើការអះអាងតទល់នឹងការទាមទាររបស់ភាគីម្ខាងទៀត ) លុះណាតែអ្នកលក់ប្រគល់ទំនិញឱ្យខ្លួនទើបខ្លួនព្រមបង់ថ្លៃឱ្យ ហើយផ្ទុយទៅវិញអ្នកលក់អាចតវ៉ាបានថា

[25] សិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស

[26] សិទ្ធិលើបំណុល និង សិទ្ធិប្រត្យក្ស

លុះណាតែអ្នកទិញបង់ថ្លៃឱ្យខ្លួនទើបខ្លួនប្រគល់ទំនិញឱ្យ ។[27] ការតវ៉ានេះអាចអនុវត្តបានរហូតដល់ពេលដែលភាគីម្ខាងទៀតបានផ្តល់ការអនុវត្តកាតព្វកិច្ចរបស់គេ ពោលគឺជាការបង់ថ្លៃជាដើម) ។

ដូច្នេះសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នានៃភាគីទាំងសងខាងនេះជាការជំរុញឱ្យមានការអនុវត្តកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកហើយជាលទ្ធផលចុងក្រោយធ្វើឱ្យមានការផ្តល់តាវកាលិកទៅវិញទៅមកបាន ។ ជាធម្មតាទេប្រសិនបើភាគីទាំងសងខាងបានកំណត់ជាមួយគ្នា ដោយមូលហេតុមួយថានឹងបង់ប្រាក់ជាមុន មូលហេតុនោះត្រូវក្លាយទៅជាវិធានដែលភាគីទាំងសងខាងបានព្រមព្រៀង ហើយគេមិនអាចប្រើសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នាបានទេ ។

អានុភាពនៃកិច្ចសន្យា សំដៅទៅលើការបង្កឱ្យមានផលវិបាកគតិយុត្តដែលកើតចេញពីកិច្ចសន្យាមួយដូចជាការបង្កើតឱ្យមានសិទ្ធិ និង ករណីកិច្ចជាដើម ហើយភាគីដែលមានសិទ្ធិ និង ករណីកិច្ចនោះ គឺមានម្ចាស់បំណុល និង កូនបំណុលដែលទទួលបានឋានៈពីកិច្ចសន្យា ។ រាល់សិទ្ធិនិងករណីកិច្ចរបស់ភាគីក្នុងកិច្ចសន្យាគឺមានភាពខុសៗគ្នាអាស្រ័យទៅតាមប្រភេទនៃកិច្ចសន្យានីមួយៗ។

## ផ្នែកទី ១ ៖ អានុភាពនៃកិច្ចសន្យាចំពោះគូភាគី

### ១.អានុភាពបង្កើតសិទ្ធិទូទៅចំពោះភាគី

រាល់បណ្តាកិច្ចសន្យាដែលមានសុពលភាពគឺតែងតែតម្រូវឱ្យភាគីនីមួយៗត្រូវធ្វើនូវអ្វីមួយ ឬ ក៏មិនធ្វើអ្វីមួយ។[28] ពោលគឺជាទូទៅភាគីនីមួយៗនៃកិច្ចសន្យាមានសិទ្ធិ និង កាតព្វកិច្ច ដើម្បីបំពេញទៅតាមកិច្ចសន្យានោះ។ ជាធម្មតារាល់កិច្ចសន្យាទាំងអស់ដែលបានបង្កើតឡើងដោយគូភាគី គឺគូភាគីមានហេតុផលដើម្បីបង្កើតកិច្ចសន្យាមួយឡើង ។ តួយ៉ាងកិច្ចសន្យាអញ្ញមញ្ញ គូភាគីតែងតែទាមទារឱ្យបំពេញនូវករណីកិច្ចចំពោះគ្នាទៅវិញទៅមក ។ ដូច្នេះការដែលភាគីណាម្ខាងចង់ឱ្យភាគីម្ខាងទៀត បំពេញនូវករណីកិច្ចណាមួយនោះ លុះត្រាតែខ្លួនមានសិទ្ធិ ឬ បានបង្កើតនូវសិទ្ធិតាមរយៈការព្រមព្រៀងនៅក្នុងកិច្ចសន្យា ហើយសិទ្ធិនោះត្រូវស្របទៅនឹងករណីកិច្ចរបស់ភាគីម្ខាងទៀតផងដែរ។

---

[27] ផ្អែកតាមខ្លឹមសារនៃ មាត្រា ៥៣៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[28] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

## ២.អានុភាពចាប់បង្ខំនូវករណីកិច្ចទូទៅចំពោះភាគី

បណ្តាកិច្ចសន្យាដែលអាចដាក់ឱ្យប្រតិបត្តិបាន ភាគច្រើនតម្រូវឱ្យភាគីត្រូវតែប្រតិបត្តិកិច្ចសន្យានោះ។[29] ការប្រតិបត្តិតាមកិច្ចសន្យា គឺជាការអនុវត្តនូវរាល់អំពើរបស់ភាគីចុះកិច្ចសន្យា ដែលមានកាតព្វកិច្ចត្រូវតែប្រព្រឹត្ត សំដៅពីការបំពេញតម្រូវការចំពោះសិទ្ធិវដ្តប្បវេណីរបស់ភាគីម្ខាងទៀតដែលត្រូវទទួលបានត្រូវគ្នាជាមួយនឹង កាតព្វកិច្ចនោះ។[30] ម្យ៉ាងវិញទៀតនៅពេលដែលចុះកិច្ចសន្យានោះភាគីនីមួយៗសុទ្ធតែមានវត្ថុបំណងរបស់ខ្លួន យ៉ាងពិតប្រាកដ ប៉ុន្តែគោលបំណងរបស់ខ្លួនដែលមានលទ្ធផលចេញពីកិច្ចសន្យានោះអាចសម្រេចបាន ឬ អត់ គឺអាស្រ័យដោយភាគីប្រតិបត្តិកាតព្វកិច្ចបានត្រឹមត្រូវពេញលេញទៅតាមការសន្យានោះឬយ៉ាងណា[31] ជារួម មានន័យថាកិច្ចសន្យាដែលដាក់ឱ្យប្រតិបត្តិទៅបាន លុះត្រាតែកិច្ចសន្យានោះមានសុពលភាព ហើយដោយ ហេតុផលសុពលភាពនៃកិច្ចសន្យានោះហើយទើបបានធ្វើឱ្យកិច្ចសន្យាមួយមានអានុភាព ។ ដូច្នេះអានុភាពនៃ កិច្ចសន្យាក៏បានបង្កើតឱ្យមានផងដែរនូវលក្ខណៈចាប់បង្ខំចំពោះគូភាគីឱ្យមាននូវករណីកិច្ចទូទៅមួយចំនួនជា កំហិត។

### ២.១.កិច្ចសន្យាត្រូវតែអនុវត្ត

ក្រោយពីការកកើតនូវកិច្ចសន្យាហើយមក អានុភាពនៃកិច្ចសន្យាបានចាប់បង្ខំគូភាគីកិច្ចសន្យាឱ្យត្រូវតែ អនុវត្តកិច្ចសន្យាដែលបង្កើតឡើងនោះ ដូចដែលបានបញ្ជាក់ពីខាងដើមរួចមកហើយថាហេតុផលដែលភាគីធ្វើ កិច្ចសន្យាមួយឡើងតាមធម្មតាគឺ ភាគីនៃកិច្ចសន្យាចង់ប្រាកដថាភាគីម្ខាងទៀតនៃកិច្ចសន្យានឹងបំពេញ កាតព្វកិច្ចដែលខ្លួនចង់ឱ្យបំពេញ។ ដូច្នេះដើម្បីឱ្យគោលបំណងរបស់ភាគីនៃកិច្ចសន្យាអាចសម្រេចបាននោះគឺ ភាគីចាំបាច់ត្រូវតែអនុវត្តកាតព្វកិច្ចបំពេញទៅតាមកិច្ចសន្យា។ បើយោងតាមមាត្រា ២៩ នៃក្រឹត្យច្បាប់លេខ ៣៨ បានកំណត់ថា កាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងកិច្ចសន្យាត្រូវតែអនុវត្តយ៉ាងទៀងទាត់ និងត្រឹមត្រូវជា ពិសេសអំពី បរិមាណ គុណភាព ទីកន្លែង និងរយៈពេលកំណត់ មានន័យថា ក្នុងការអនុវត្តកិច្ចសន្យា ភាគីនៃ កិច្ចសន្យាត្រូវតែអនុវត្តកិច្ចសន្យាឱ្យស្របទៅតាមខ្លឹមសារ និងការកំណត់ផ្សេងទៀត ដែលបានកំណត់តាមការ ព្រមព្រៀងក្នុងកិច្ចសន្យានោះ។ និយាយដោយខ្លីទៅគឺថា គូភាគីនៃកិច្ចសន្យាត្រូវធ្វើតាមអ្វីដែលមានចែងក្នុង កិច្ចសន្យាឱ្យបាន ១០០ភាគរយ ពីព្រោះថាកិច្ចសន្យាគឺជាច្បាប់របស់គូភាគី។

---

[29] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

[30] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

[31] ច្បាប់កិច្ចសន្យាផ្សារសេរី ឆ្នាំ ១៩៩៧

ដូច្នេះគូភាគីចាំបាច់ត្រូវតែគោរពទៅតាមច្បាប់នោះជាដាច់ខាត ល្គឹកណាដែលភាគីមិនអនុវត្តតាមច្បាប់ដែលជាកិច្ចសន្យានោះ ទោះបីជាទាំងស្រុងក្តី ឬពាក់កណ្តាលក្តីនឹងនាំឱ្យមានទណ្ឌកម្មតាមផ្លូវច្បាប់គឺ ៖

- ការរំលាយកិច្ចសន្យា និង សំណងជំងឺចិត្តជាដើមប្រសិនបើមាន។

ជាងនេះទៀត ការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យានោះ គឺវាមានលក្ខណៈជាកាតព្វកិច្ចជាច្រើនប្រភេទខុសៗគ្នាទៅតាមបណ្តាកិច្ចសន្យានីមួយៗ ជាក់ស្តែងប្រភេទនៃកាតព្វកិច្ចនៅក្នុងក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ត្រូវបានគេបែងចែកចេញជា៣ ដូចជា ៖ កាតព្វកិច្ចផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬប្រាក់ និង កាតព្វកិច្ចដែលមានគោលបំណងធ្វើ ឬ មិនធ្វើសកម្មភាពណាមួយ។[32] ដូច្នេះទើបការអនុវត្តកាតព្វកិច្ចនីមួយៗមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមប្រភេទនៃកាតព្វកិច្ចក្នុងកិច្ចសន្យានីមួយៗ ។ បើករណីដែលកិច្ចសន្យាបង្កើតអានុភាពឱ្យមានកាតព្វកិច្ចណាមួយហើយនោះ ភាគីនៃកិច្ចសន្យាត្រូវប្រតិបត្តិបំពេញទៅតាមប្រភេទកាតព្វកិច្ចនោះ។

ជាក់ស្តែងចំពោះកាតព្វកិច្ចផ្ទេរកម្មសិទ្ធិ សិទ្ធិកាន់កាប់វត្ថុ ឬ ប្រាក់ ក្នុងការអនុវត្តកិច្ចសន្យាភាគីត្រូវបំពេញនូវករណីកិច្ចមួយចំនួនដូចជា ៖ ភាគីដែលមានកាតព្វកិច្ចត្រូវធ្វើការផ្ទេរសិទ្ធិ ព្រមទាំងមានការប្រគល់វត្ថុជាក់លាក់អ្វីមួយនោះ មានករណីកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ

**ឧទាហរណ៍ ៖** កិច្ចសន្យាលក់-ទិញរូបគំនូរ១ផ្ទាំងដ៏ល្បីរបស់កុមារីម្នាក់ដែលបានស្លាប់ទៅហើយ។ លើសពីនេះទៅទៀត ក្នុងករណីដែលកិច្ចសន្យាពាក់ព័ន្ធនឹងសិទ្ធិប្រាតិភោគ ភាគីដែលជាម្ចាស់បំណុលបានកាន់កាប់នូវវត្ថុរបស់កូនបំណុលក្នុងដៃរបស់ខ្លួនដើម្បីធានាសិទ្ធិលើបំណុលនោះ ក្នុងនាមជាម្ចាស់បំណុលដែលបានកាន់កាប់វត្ថុរបស់កូនបំណុលក្នុងដៃរបស់ខ្លួនក៏ត្រូវមានករណីកិច្ចថែរក្សាវត្ថុដែលបានដាក់ប្រាតិភោគឱ្យបានសមរម្យ និងគង់វង្សបានល្អដោយអនុវត្តឱ្យដូចជាម្ចាស់នៃវត្ថុនោះអញ្ចឹងដែរ ។

**ឧទាហរណ៍ ៖** កិច្ចសន្យាបញ្ចាំ ។

[32] មាត្រា ៣១៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ករណីបើសិនកម្មវត្ថុដែលត្រូវផ្តល់មានគុណភាពច្រើនយ៉ាង កូនបំណុលមានករណីកិច្ចផ្តល់វត្ថុដែលមានគុណភាពដូចដែលគូភាគីបានកំណត់ក្នុងកិច្ចសន្យា ។

**ឧទាហរណ៍ ៖** កិច្ចសន្យាលក់-ទិញខ្ទះឆាអគ្គីសនីទំនើបមួយគ្រឿង ដែលក្នុងកិច្ចសន្យានោះបានកំណត់អំពីប្រភេទម៉ាក និង ទំហំគុណភាពរបស់វា។ ដូច្នេះបើទោះបីជាខ្ទះឆាអគ្គីសនីរបស់អ្នកលក់មានច្រើនប្រភេទ ឬច្រើនម៉ាក និង មានគុណភាពផ្សេងៗពីគ្នាជាច្រើនយ៉ាងណាក៏ដោយក្តី ក៏អ្នកលក់ចាំបាច់ត្រូវតែផ្តល់នូវវត្ថុដែលមានគុណភាពស្របទៅតាមខ្លឹមសារនៃកិច្ចសន្យាជាកំហិត ។

ម្យ៉ាងទៀត ភាគីដែលទទួលបន្ទុកក្នុងទំនាក់ទំនងគតិយុត្តដែលទាក់ទងទៅនឹងកម្មវត្ថុនៃការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ត្រូវមានករណីកិច្ចពន្យល់ឱ្យបានច្បាស់លាស់អំពីសិទ្ធិ ឬ ការប្រើប្រាស់ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃកិច្ចសន្យានោះ

**ឧទាហរណ៍ ៖** កិច្ចសន្យាលក់-ទិញអចលនវត្ថុ អ្នកលក់ត្រូវតែពន្យល់អំពីការប្រើប្រាស់ និងទំហំនៃអចលនវត្ថុនោះជាដើម ហើយភាគីដែលមានបន្ទុកកាតព្វកិច្ចក្នុងប្រភេទកិច្ចសន្យានេះត្រូវមានករណីកិច្ចផ្តល់វត្ថុ ឬ សិទ្ធិផ្សេងទៀត ដែលជាកម្មវត្ថុនៃកិច្ចសន្យាដោយគ្មានវិការៈ។

## ២.២.ការអនុវត្តត្រូវតែគោរពគោលការណ៍សុចរិតនិងស្មោះត្រង់

នៅរាល់បណ្តាច្បាប់ជាតិរបស់សង្គមជាតិនីមួយៗ និង ច្បាប់អន្តរជាតិនៃសហគមន៍ប្រជាជាតិផងដែរនោះ យើងបានសង្កេតឃើញថាមានគោលការណ៍ដ៏សំខាន់មួយដែលមានការទទួលស្គាល់ជាទូទៅមួយភាគធំតាមរយៈការអនុវត្តដោយបណ្តាប្រទេសជាច្រើនក្នុងសកលលោកនោះគឺជាគោលការណ៍នៃភាពសុចរិត និងស្មោះត្រង់ ។[33] នៅក្នុងសង្គមអន្តរជាតិគោលការណ៍នេះឃើញមានការប្រើប្រាស់ជាញឹកញាប់នៅក្នុងការអនុវត្តសន្ធិសញ្ញានិងកិច្ចព្រមព្រៀងនានា សម្រាប់ការធានាបាននូវការអនុវត្តមួយដែលត្រឹមត្រូវនិងសមស្របប្រកបដោយសមធម៌ល្អប្រពៃ។ ជាក់ស្តែងនៅកម្ពុជាក្នុងច្បាប់កិច្ចសន្យាក៏បានធានាឱ្យគោរពនូវគោលការណ៍នេះផងដែរក្នុងការអនុវត្ត។ នៅក្នុងមាត្រា២ នៃក្រឹត្យច្បាប់លេខ ៣៨ របស់កម្ពុជាបានចែងថា "កិច្ចសន្យាទាំងឡាយត្រូវរួមចំណែកក្នុងការផ្សាភ្ជាប់ផលប្រយោជន៍បុគ្គលនិងផលប្រយោជន៍សង្គម។ ភាគីនៃកិច្ចសន្យាត្រូវសហការគ្នាក្នុងបរិយាកាសទុកចិត្តស្មោះត្រង់នឹងគ្នា អនុវត្តសមស្របនឹងគោលការណ៍សីលធម៌សង្គម ហើយពិសេសកម្ចាត់ចោលនូវគំនិតមនុស្សជិះជាន់មនុស្ស។" បន្ថែមពីលើមាត្រានេះ មាត្រា ២២ កថាខណ្ឌទី ២

[33] អនុសញ្ញាទីក្រុងវីយែន ឆ្នាំ ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញា

នៃក្រឹត្យច្បាប់លេខ ៣៨ ដដែលក៏បានចែងដែរថា"កិច្ចសន្យាត្រូវយកទៅអនុវត្តដោយសុចរិត និង ស្មោះត្រង់ ។" ដោយយោងតាមរយៈមាត្រាទាំងពីរនេះ វាបានឆ្លុះបង្ហាញឱ្យឃើញពីគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ ក្នុងការអនុវត្តកិច្ចសន្យា ។ លើសពីនេះទៅទៀត នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា៣៨៤ ក៏បានទទួលស្គាល់នូវគោលការណ៍នេះផងដែរ។ នៅក្នុងមាត្រា ៣៨៤ កថាខណ្ឌទី១ នោះបាន បញ្ញត្តិថា ៖ កូនបំណុលត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍ នៃភាពសុចរិត និង ភាពស្មោះត្រង់។ ការប្រតិបត្តិដោយសុចរិត និង ស្មោះត្រង់នៅទីនេះមានន័យថាភាគីម្ខាងៗ នៃកិច្ចសន្យាមិនត្រូវធ្វើអ្វីឱ្យល្អក់កករដល់ការប្រតិបត្តិកាតព្វកិច្ចរបស់ភាគីម្ខាងទៀតឡើយ ។ និយាយជារួមគឺថា ភាគីម្នាក់ៗ ត្រូវតែប្រកាន់ភ្ជាប់យកនូវឥរិយាបទសមស្របត្រឹមត្រូវជៀសវាងធ្វើអ្វីដែលនាំឱ្យភាគីម្ខាងទៀតពិបាក ឬពុំអាចបំពេញកាតព្វកិច្ចបាន ពោលគឺភាគីម្ខាងត្រូវសម្រួលដល់ការសម្រេចបានក្នុងការអនុវត្តកាតព្វកិច្ចរបស់ ភាគីម្ខាងទៀត។ យោងតាមមាត្រា៣២៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់ថា ប្រសិនបើភាគីម្ខាងដែលត្រូវបានខូចប្រយោជន៍ដោយសារលក្ខខណ្ឌត្រូវបានបំពេញ ហើយភាគីម្ខាងទៀតនោះ បានរារាំងមិនឱ្យបំពេញលក្ខខណ្ឌដោយចេតនាភាគីម្ខាងទៀតអាចចាត់ទុកថាលក្ខខណ្ឌនោះត្រូវបានបំពេញរួច ហើយ។

**ឧទាហរណ៍ ៖** កិច្ចសន្យាប្រទានកម្មដែលមានបង្អង់លក្ខខណ្ឌមួយបានកំណត់ បើសិនជាឈ្មោះ ក រៀប អាពាហ៍ពិពាហ៍ជាមួយនឹងកូនរបស់ឈ្មោះ ខ នោះ ឈ្មោះ ខ នឹងប្រគល់ឱ្យនូវដីឡូត៍មួយកន្លែងឱ្យឈ្មោះ ក ប៉ុន្តែក្រោយមកដោយសារតែដីនោះបានកើនតម្លៃកាន់តែខ្ពស់ខ្លាំងពេលនោះ ឈ្មោះ ខ ក៏បានផ្លាស់ប្តូរចិត្តមិន ចង់ប្រគល់ដីនោះទៅឱ្យ ឈ្មោះ ក ។ ដូច្នេះឈ្មោះ ខ ក៏បានព្យាយាមរារាំង ឈ្មោះ ក មិនឱ្យអនុវត្តសម្រេចបាន នូវលក្ខខណ្ឌបង្អង់នោះ ជាដំណោះស្រាយយោងតាមមាត្រា ៣២៨ ខាងលើដោយ ឈ្មោះ ខ បាន រារាំងមិនឱ្យ លក្ខខណ្ឌត្រូវបានបំពេញដោយចេតនាបែបនេះនាំឱ្យ ឈ្មោះ ក អាចចាត់ទុកថាលក្ខខណ្ឌនោះត្រូវបានបំពេញ រួចហើយ យើងអាចនិយាយបានថាដោយផ្អែកតាមស្មារតីនៃភាពសុចរិត និង ស្មោះត្រង់នៃបទប្បញ្ញត្តិខាងលើ នេះ គូភាគីមានកាតព្វកិច្ចមួយក្នុងការសហការគ្នាក្នុងការប្រតិបត្តិកាតព្វកិច្ចរៀងខ្លួនៗឱ្យបានល្អ និង មិនគេង ចំណេញខុសពីច្បាប់ឡើយ។

## ៣.អានុភាពបង្កើតជាច្បាប់របស់ភាគី

កិច្ចសន្យាដែលបង្កើតឡើងតាមរយៈការព្រមព្រៀងរបស់ភាគីបានបង្កឱ្យមាននូវអានុភាពនៃការជៀបទៅលើកិច្ចសន្យានោះឱ្យទៅជាច្បាប់របស់គូភាគី ។[34] កិច្ចសន្យាដែលជាច្បាប់របស់ភាគី គឺជាវិធានគតិយុត្តទាំងឡាយណាដែលគ្រប់គ្រងរាល់ទំនាក់ទំនងរបស់ភាគីនៅក្នុងកិច្ចសន្យា ។ ការបង្កើតកិច្ចសន្យាឡើងភាគីនីមួយៗនៃកិច្ចសន្យាបានរួបរួមគ្នាយ៉ាងសកម្មក្នុងការព្រមព្រៀងអនុម័តសម្រេចនូវវិធានទាំងឡាយដែលបានកំណត់ក្នុងកិច្ចសន្យារបស់ពួកគេ។ ដូច្នេះជាគោលការណ៍ទូទៅ កិច្ចសន្យាមិនអាចត្រូវបានធ្វើការកែប្រែទៅតាមទំនើងចិត្ត ឬ ជាសកម្មភាពឯកតោភាគីដោយឯកឯងបាននោះឡើយ។ លើសពីនេះទៅទៀតនោះគឺភាពមិនអាចបំពានបាននៃកិច្ចសន្យាដោយផ្អែកលើវិធានដែលគ្រប់គ្រងលើកិច្ចសន្យា ប្រសិនមានករណីនៃការបំពារបំពានលើកិច្ចសន្យានោះ វានឹងមានអានុភាពអាចឈានដល់ការដាក់ទណ្ឌកម្ម (ការរំលាយកិច្ចសន្យា ឬ សំណងការខូចខាតជាដើម) ។

### ៣.១.ភាពមិនអាចកែប្រែបាននៃកិច្ចសន្យា

ជាគោលការណ៍ទូទៅ កិច្ចសន្យាមិនត្រូវបានអនុញ្ញាតឱ្យធ្វើការកែប្រែបានឡើយ ប៉ុន្តែក៏មានករណីអញ្ញាត្រកម្មមួយចំនួនទៅលើគោលការណ៍នេះផងដែរ ។ ដូច្នេះប្រសិនបើមានអញ្ញត្រកម្មអនុញ្ញាតឱ្យកិច្ចសន្យា អាចធ្វើការកែប្រែបាននោះ ការកែប្រែអាចស្តែងឡើងក្រោមរូបភាពពីរផ្សេងៗគ្នាគឺ ៖

១.ការកែប្រែចំណុចមួយចំនួននៃកិច្ចសន្យា

២.ការកែប្រែទាំងស្រុងនៃកិច្ចសន្យា ពោលគឺ ការកាត់ផ្តាច់ចំណងកិច្ចសន្យាចោល។

ជាក់ស្តែងនៅក្នុងមាត្រា ២២ នៃក្រឹត្យច្បាប់លេខ ៣៨ បានបញ្ញត្តិថា៖

កិច្ចសន្យាគឺជាច្បាប់របស់ភាគី ។ កិច្ចសន្យានឹងអាចកែប្រែបាន លុះត្រាតែមានការយល់ព្រមរបស់គូភាគីទាំងសងខាង ។ យោងតាមរយៈមាត្រានេះគឺ អាចធ្វើឱ្យយើងដឹងថាកិច្ចសន្យាគឺ មិនអាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែប្រែតាមទំនើងចិត្តជាឯកតោភាគីបានឡើយ មានន័យថាច្បាប់កើតចេញពីឆន្ទៈទូទៅរបស់ភាគីនៃកិច្ចសន្យា ហើយកិច្ចសន្យាមិនអនុញ្ញាតអោយធ្វើការកែប្រែតាមទំនើងចិត្តជាឯកតោភាគីបានឡើយ។

[34] ច្បាប់រដ្ឋប្បវេណី ( ករណីនៅប្រទេសជប៉ុន )

### ៣.២.ភាពមិនអាចបំពានបាននៃកិច្ចសន្យា

ការបំពានកិច្ចសន្យា គឺជាការខកខានពុំបានបំពេញកាតព្វកិច្ចទៅតាមការសន្យាណាមួយដែលភាគីបានធ្វើឡើងនៅក្នុងកិច្ចសន្យា ។ នៅពេលដែលការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាបានមកដល់កាលកំណត់ត្រូវបំពេញ ឬ អាចនិយាយឱ្យខ្លីហៅថាការមិនអនុវត្តកាតព្វកិច្ច ការមិនអនុវត្តកាតព្វកិច្ចនេះ បានធ្វើការបែងចែកចេញជា ៣ផ្សេងៗទៀត ដូចជា ការអនុវត្តយឺតយ៉ាវ អលទ្ធភាពក្នុងការអនុវត្ត ការអនុវត្តមិនពេញលេញ និងករណីផ្សេងទៀតដែលមិនអនុវត្ត ។ យ៉ាងណាមិញ អានុភាពតាមផ្លូវច្បាប់ស្តីពីការបំពានកិច្ចសន្យានេះ គឺបានកំណត់ផ្សេងៗពីគ្នា ដោយផ្អែកទៅលើស្ថានភាពនិងខ្លឹមសារនៃការបំពាននោះ ដោយជាក់លាក់អានុភាពទៅតាមផ្លូវច្បាប់នោះគឺអាស្រ័យលើថា តើការបំពានមួយនោះជាខ្លឹមសារសំខាន់ ឬ ក៏តូចតាច?

ជាក់ស្តែង នៅក្នុងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានកំណត់ពីការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។ ក្រោយពីយើងបានយល់ដឹងពីខ្លឹមសារនៃការបំពានកិច្ចសន្យាហើយមក គឺអាចធ្វើឱ្យយើងបានដឹងថាការបំពានកិច្ចសន្យា មិនមែនជារឿងដ៏ល្អឡើយ សម្រាប់សម្រេចបាននូវគោលបំណងនៃកិច្ចសន្យាទេ មានន័យថា បើសិនជាមានការបំពានកិច្ចសន្យាកើតឡើង គោលបំណងនៃកិច្ចសន្យាគឺប្រាកដណាស់ពិតជាមិនអាចសម្រេចបាននោះទេ ។ ដូច្នេះនៅពេលដែលកិច្ចសន្យាមួយត្រូវបានបង្កើតឡើងដោយមានសុពលភាពតាមផ្លូវច្បាប់ហើយ គូភាគីត្រូវតែគោរពឱ្យបានម៉ត់ចត់។ នេះជាអ្វីដែលហៅថា អានុភាពដាច់ខាតនៃកិច្ចសន្យា។ ប្រសិនបើភាគីម្ខាងទៀតមិនគោរពហើយមិនអនុវត្តកិច្ចសន្យាទេ ជាការពិតណាស់, យើងអាចទៅពឹងពាក់តុលាការបង្ខំឱ្យភាគីម្ខាងទៀតគោរពតាមកិច្ចសន្យា (ការអនុវត្តដោយបង្ខំ) ក៏បានដែរ។ បន្ថែមពីនេះដើម្បីឱ្យអានុភាពនៃកិច្ចសន្យាមានអត្ថន័យពេញលេញនោះការបំពានយ៉ាងធ្ងន់ធ្ងរទៅលើកិច្ចសន្យាត្រូវតែដាក់ទណ្ឌកម្ម។

នៅក្នុងក្រមរដ្ឋប្បវេណីវិធីសង្គ្រោះចំពោះការបំពានកិច្ចសន្យាយើងមានមធ្យោបាយ ២ បែបៈ

**ទី១** គឺរំលាយកិច្ចសន្យាដោយហេតុថាភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ច។

**ទី២** គឺទាមទាមឱ្យភាគីសងសំណងនៃការខូចខាត ដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ច។ នៅក្នុងក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យជ្រើសរើសការរំលាយកិច្ចសន្យាក៏បាន ឬរើសយកការទាមទារសំណងក៏បាន ឬ ក៏អាចរើសយកទាំង ២ក៏បានដែរក្នុងទំហំដែលមិនផ្ទុយគ្នា។ សំណងនៃការខូចខាតត្រូវបានចែកចេញជា២ប្រភេទដូចជាសំណងខូចខាតជំនួស (ករណីអលទ្ធភាព) និង សំណងខូចខាតចំពោះការយឺតយ៉ាវ។ ការបែងចែកនេះមានន័យថា ដើម្បីឱ្យយើងដឹងពីវិសមតិភាពរវាងសំណងខូចខាតជំនួស និង ការទាមទារឱ្យអនុវត្តកាតព្វកិច្ច។

ការដាក់ទណ្ឌកម្មចំពោះការបំពានកិច្ចសន្យាអាចធ្វើទៅបាន លុះត្រាតែយើងត្រូវសិក្សាទៅលើការទទួលខុសត្រូវក្នុងកិច្ចសន្យាជាមុនសិន ។

## ផ្នែកទី ២ ៖ អានុភាពនៃកិច្ចសន្យាចំពោះតតិយជន

កិច្ចសន្យា ដែលបង្កើតឡើងដោយឆន្ទៈព្រមព្រៀងរបស់ភាគីត្រូវចាត់ទុកថាជាច្បាប់របស់ភាគី ដូច្នេះវាបង្កើតឱ្យមានអានុភាពត្រឹមតែចំពោះភាគីតែប៉ុណ្ណោះ។ តាមរយៈនេះកិច្ចសន្យាមិនមានចំណងគតិយុត្តជាមួយតតិយជនឡើយ ព្រោះថាតតិយជនជាជនទាំងឡាយណាដែលស្ថិតនៅក្រៅកិច្ចសន្យា។ ដូច្នេះជាទូទៅអានុភាពនៃកិច្ចសន្យាមិនមានអានុភាពចំពោះតតិយជននោះទេ។ ជាអញ្ញាត្រកម្មច្បាប់ក៏មានចែងនូវបទប្បញ្ញត្តិពិសេសមួយចំនួន ដែលកំណត់អំពីអានុភាពនៃកិច្ចសន្យាបានជះឥទ្ធិពលទៅលើតតិយជនផងដែរ។

ជាក់ស្តែងគោលការណ៍ និង បទប្បញ្ញត្តិរបស់ច្បាប់មួយចំនួន ក៏បានចែងពីអានុភាពនៃកិច្ចសន្យាចំពោះតតិយជនក្នុងករណីមួយចំនួនផងដែរ។ ជាទូទៅតតិយជនអាចមានច្រើនប្រភេទហើយតតិយជនមួយចំនួនអាចក្លាយជាភាគីនៃកិច្ចសន្យាថែមទៀតផងក្នុងនោះមានដូចជា៖

- ប្រតិសិទ្ធិសាកល និង ប្រតិសិទ្ធិមានកំណត់
- អ្នកទទួលផលប្រយោជន៍
- អ្នកតំណាងគ្មានសិទ្ធិ
- តតិយជនដាច់ខាតពិត

### ១.កិច្ចសន្យាដែលបង្កើតស្ថានភាពគតិយុត្តចំពោះតតិយជន

កិច្ចសន្យាមួយចំនួន បង្កើតជាស្ថានភាពគតិយុត្តចំពោះតតិយជនដែលយើងអាចចាត់ទុកបានថាជាព្រឹត្តការណ៍គតិយុត្តសម្រាប់តតិយជន។

**ឧទាហរណ៍ ៖** ការសន្យាបន្ថែមនៅក្នុងការទិញ-លក់រវាងឈ្មោះ ក និងឈ្មោះ ខ ដែលកំណត់ថានឹងបង់ប្រាក់ថ្លៃទំនិញឱ្យទៅឈ្មោះ គ ផ្ទាល់ជាដើម ។ កិច្ចសន្យាដែលផ្តល់ផលប្រយោជន៍ទៅតតិយជនក្រៅពីភាគីនៃកិច្ចសន្យានេះគេហៅថា កិច្ចសន្យាដែលធ្វើឡើងសម្រាប់តតិយជន ។ នេះជាកិច្ចសន្យាមួយក៏ប៉ុន្តែកិច្ចសន្យានេះមិនអាចកើតមានឡើងដោយឯកឯងទេ តែតោងភ្ជាប់ទៅនឹងកិច្ចសន្យាណាមួយទៀតហើយមានឈ្មោះជាកិច្ចសន្យាពិសេស ឬ ក៏ជាកថាលក្ខន្តិកៈបន្ទាប់បន្សំ។ ដោយហេតុថាវាញ៉ាំងឱ្យ កិច្ចសន្យាមានអានុភាពចងចំពោះជន

ផ្សេងក្រៅពីភាគីនៃកិច្ចសន្យានោះ គេចាត់ទុកថាជាករណីលើកលែង ដែលខុសពីការយល់ដឹងជាទូទៅចំពោះអានុភាពនៃកិច្ចសន្យា (មិនជះឥទ្ធិពលទៅលើជនណាក្រៅពីគូនាទីទេ) ប៉ុន្តែក្នុងករណីនេះក៏មានការកំណត់ពីទំហំព្រំដែនដូចតទៅ:

១.អាចធ្វើកិច្ចសន្យាបានដោយឱ្យផលប្រយោជន៍ដល់តតិយជន គ តែមិនអាចធ្វើការព្រមព្រៀងគ្នាបង្កឱ្យតតិយជន គ ទទួលរងនូវផលវិបាកដោយត្រូវបំពេញកាតព្វកិច្ចជាអវិជ្ជមានណាមួយឡើយ ។

២.តតិយជន គ ដែលជាអ្នកទទួលផលនោះមិនអាចនឹងទទួលផលប្រយោជន៍ដែលកើតឡើង តាមរយៈការព្រមព្រៀងគ្នារវាងឈ្មោះ ក និង ឈ្មោះ ខ ដោយស្វ័យប្រវត្តិបានទេ ពោលគឺតតិយជន គ ចាំបាច់ត្រូវតែបង្ហាញឆន្ទៈព្រមទទួលផលផងដែរ (ការបង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍) ។

៣.បើតតិយជន គ បង្ហាញឆន្ទៈក្នុងការទទួលផលប្រយោជន៍ហើយ ភាគី ក និង ភាគី ខ មិនអាចដកការព្រមព្រៀងនេះចេញបានទេ តែបើមិនទាន់មានការបង្ហាញឆន្ទៈទទួលផលពីតតិយជន គ នៅឡើយទេ ការព្រមព្រៀងអាចដកចេញវិញបាន។

អាស្រ័យហេតុនេះ តតិយជនអាចលើកសំអាងហេតុពីកិច្ចសន្យាទុកដូចជាភស្តុតាងសម្រាប់អះអាង ឬបញ្ជាក់នូវសិទ្ធិណាមួយរបស់ខ្លួន ឬ សម្រាប់ដោះបន្ទុករបស់ខ្លួន។

ម្យ៉ាងទៀតបន្ទាប់ពីបានបង្ហាញឆន្ទៈទទួលផលហើយ តតិយជនដែលជាអ្នកទទួលផលអាចទាមទារឱ្យកូនបំណុលផ្តល់តាវកាលិកមកខ្លួនដោយចំពោះបាន នៅក្នុងករណីនេះកូនបំណុលអាចអះអាងនូវគ្រប់សិទ្ធិទាំងអស់ដូចដែលខ្លួនមានទៅលើម្ចាស់បំណុលនោះបានដែរ ។

**ឧទាហរណ៍ ៖** ក្នុងករណីអ្នកលក់ ក និង អ្នកទិញ ខ បានធ្វើកិច្ចសន្យាលក់ជាមួយគ្នាហើយ បានធ្វើកិច្ចសន្យាសម្រាប់តតិយជនដោយកំណត់ថា ត្រូវប្រគល់ប្រាក់ថ្លៃទំនិញទៅឱ្យឈ្មោះ គ ផ្ទាល់ថែមទៀតផង។ ក្រោយពីឈ្មោះ គ បានបង្ហាញឆន្ទៈថាសុខចិត្តទទួលផលប្រយោជន៍ហើយ ឈ្មោះ គ ទៅទារប្រាក់ថ្លៃទំនិញពី ខ ។ បើសិនជា ខ នៅមិនទាន់បានទទួលទំនិញពី ក នៅឡើយទេ ខ មានសិទ្ធិតវ៉ាជាមួយ ក ទាមទារឱ្យអនុវត្តព្រមគ្នានោះ ខ ក៏អាចប្រើសិទ្ធិតវ៉ានេះចំពោះ គ បានដូចគ្នាផងដែរ ។

កិច្ចសន្យាដែលបង្កើតស្ថានភាពគតិយុត្តចំពោះតតិយជនបែបនេះ តតិយជនទាំងនោះច្រើនតែជាប្រតិសិទ្ធិសាកល និង ប្រតិសិទ្ធិមានកំណត់។

**ក.ប្រតិសិទ្ធិសាកល**

ប្រតិសិទ្ធិសាកល គឺជាអ្នកទទួលសិទ្ធិបន្តពីគេ ដើម្បីប្រកបការរបស់ខ្លួនផងនិងជំនួសគេផង ដែលទទួលបានសិទ្ធិបេតិកភណ្ឌមួយភាគ ឬ ទាំងអស់ដែលរួមមានសិទ្ធិផង និង កាតព្វកិច្ចផង ពោលគឺ ទ្រព្យសកម្មផង និង អសកម្មផង។

**ឧទាហរណ៍ ៖** សន្តតិជនដែលមានអត្ថិភាពព្រមទទួលទាំងអស់នូវទ្រព្យសម្បត្តិរបស់មតកជន ។ ដូច្នេះនៅពេលមតកជនស្លាប់ទៅ សន្តតិជន (ប្រតិសិទ្ធិសាកល) នឹងទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយចេញពីកិច្ចសន្យាដែលធ្វើដោយមតកជនមុនពេលស្លាប់ ។

**ខ.ប្រតិសិទ្ធិមានកំណត់**

ប្រតិសិទ្ធិមានកំណត់ គឺជាបុគ្គលដែលទទួលបាននូវសិទ្ធិ និង កាតព្វកិច្ចមួយ ឬ ច្រើនជាកំណត់ច្បាស់លាស់លើបេតិកភណ្ឌរបស់ម្ចាស់សិទ្ធិ ។

**ឧទាហរណ៍ ៖** អច្ច័យទានមានកំណត់អ្នកទិញ ឬ អ្នកទទួលអំណោយជាដើម ពេលខ្លះប្រតិសិទ្ធិនេះក៏មានការពាក់ព័ន្ធនឹងកិច្ចសន្យាដែលធ្វើឡើងដោយម្ចាស់សិទ្ធិដើម។ ចំពោះប្រតិសិទ្ធិមានកំណត់នេះ យើងត្រូវសិក្សាលើការផ្ទេរកិច្ចសន្យាទាក់ទងនឹងសិទ្ធិបាតិបុគ្គលនិងកិច្ចសន្យាទាក់ទងនឹងសិទ្ធិប្រត្យក្ស។

**១.សិទ្ធិបាតិបុគ្គល**

ជាគោលការណ៍មិនអនុញ្ញាតឱ្យមានការផ្ទេរសិទ្ធិបាតិបុគ្គលបានទេ គេមិនអាចផ្ទេរទាំងសិទ្ធិ និង ទាំងកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យារបស់ម្ចាស់បំណុលបានទេ។

**ឧទាហរណ៍ ៖** លោក ក បានលក់រថយន្តមកឱ្យលោក ខ ប៉ុន្តែលោក ក បានជំពាក់ប្រាក់ថ្លៃជួសជុលរថយន្តជាមួយលោក គ ។ ដូច្នេះសិទ្ធិបាតិបុគ្គលដែលលោក ក ជំពាក់លោក គ នេះ មិននាំឱ្យលោក ខ ត្រូវបន្តទទួលខុសត្រូវថ្លៃជួសជុលលើរថយន្តនេះទេ។

ផ្ទុយទៅវិញ បើសិនជាលោក ខ បានដឹងពីការជួសជុលនោះ ហើយបានយល់ព្រមទទួលយកកាតព្វកិច្ចនៃការសងជំនួសដោយសារការបន្ថយតម្លៃពិតប្រាកដលើរថយន្តដែលជាកម្មវត្ថុនៃការលក់-ទិញ ដូច្នេះករណីនេះលោក ខ នឹងត្រូវទទួលខុសត្រូវបន្តលើកាតព្វកិច្ចនៃថ្លៃជួសជុលរថយន្តនោះ។

**ឧទាហរណ៍ ៖** បន្ទាប់ពី ក ដែលជាម្ចាស់ផ្ទះបានចុះកិច្ចសន្យាផលុបភោគជាមួយនឹង ខ រួចមក ក បានលក់ផ្ទះនោះទៅឱ្យ គ ។ គ ជាប្រតិសិទ្ធិមានកំណត់របស់ ក ដែលជាម្ចាស់សិទ្ធិដើម ។ ចំពោះកិច្ចសន្យារវាង ក និង ខ , គ ជាតតិយជនដែលពុំមានអ្វីជាប់ទាក់ទងនឹងកិច្ចសន្យានោះឡើយ ។ ប៉ុន្តែបើតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ការលក់អចលនវត្ថុដែលកំពុងជាប់ផលុបភោគដោយសារកម្មសិទ្ធិករ មិនបានធ្វើឱ្យមានការផ្លាស់ប្តូរណាមួយចំពោះផលុបភោគដែលកំពុងបន្តប្រើប្រាស់សិទ្ធិរបស់ខ្លួននោះទេ ។[35] ហេតុដូចនេះ គ ត្រូវតែទទួលស្គាល់អត្ថិភាពនៃសិទ្ធិផលុបភោគដែលមានស្រាប់នៅលើទ្រព្យដែលខ្លួនទិញ ។

លើសពីនេះក៏មានករណីមួយចំនួនទៀតផងដែរដូចជា៖

- ភតិសន្យា អ្នកទិញអចលនវត្ថុដែលបានជួល ត្រូវបន្តគោរពកិច្ចសន្យាជួល។[36]
- កិច្ចសន្យាការងារ អ្នកទិញរោងចក្រសហគ្រាស ត្រូវបន្តគោរពកិច្ចសន្យាការងាររវាងកម្មករនិយោជិកនឹងម្ចាស់សហគ្រាសចាស់។[37]

[35] មាត្រា ១៣៦ នៃច្បាប់ភូមិបាល ២០០១

[36] មាត្រា ៥៨៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[37] មាត្រា ៨៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

# ជំពូកទី ៤

# ការរំលាយកិច្ចសន្យា

# ជំពូកទី ៤

# ការរំលាយកិច្ចសន្យា

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការរំលាយកិច្ចសន្យា

### កថាភាគទី១ ៖ និយមន័យនៃការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យា សំដៅទៅលើសកម្មភាពឯកតោភាគីដែលធ្វើឲ្យភាគីទាំងសងខាងរួចផុតពីករណីយកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត។[38] ការរំលាយកិច្ចសន្យាធ្វើឲ្យមានអានុភាពជាឯកតោភាគី ហើយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ពីព្រោះវាគឺជាសកម្មភាពឯកតោភាគី។[39]

### កថាភាគទី២ ៖ គោលបំណងនៃការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យាគឺបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។ ការបញ្ញត្តិនេះ គឺមានគោលបំណងក្នុងការផ្តល់សិទ្ធិទៅដល់គូភាគីនៃកិច្ចសន្យា ដើម្បីឲ្យភាគីអាចមានសិទ្ធិរំលាយកិច្ចសន្យាមួយចោលក្នុងការទប់ស្កាត់នូវហានិភ័យ ឬ ក៏បញ្ហាទាំងឡាយណាដែលអាចនឹងកើតមានឡើងនៅពេលអនាគត និង ជាការជួសជុលព្យសនកម្មដែលបានកើតឡើងដោយសារការបំពានកិច្ចសន្យាធ្ងន់ធ្ងររបស់ភាគីម្ខាងទៀត ។ ស្ថិតក្នុងន័យនេះគេចង់បញ្ជាក់ថា ការផ្តល់ឲ្យភាគីមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាមិនមែនជាការដាក់ទណ្ឌកម្មទៅលើភាគីណាមួយនៃកិច្ចសន្យានោះទេ ប៉ុន្តែវាគឺជាប្រព័ន្ធដែលផ្តាច់ចំណងកាតព្វកិច្ចនៃកិច្ចសន្យានៅពេលដែលគោលបំណងនៃកិច្ចសន្យានោះ មិនបានសម្រេចដោយសារតែមានការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងណាមួយ។

### កថាភាគទី៣ ៖ ប្រភេទនៃការរំលាយកិច្ចសន្យា

#### ១.ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់

ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ គឺជាការរំលាយកិច្ចសន្យាដោយផ្អែកតាមមូលហេតុណាមួយដែលមានកំណត់ក្នុងច្បាប់ ហេតុនេះក្នុងករណីមានមូលហេតុណាមួយដែលមានបញ្ញត្តិក្នុងច្បាប់ត្រូវបាន

[38] មាត្រា ៤១១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[39] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

បំពាន ភាគីនោះអាចរំលាយកិច្ចសន្យាបាន។ ចំពោះសិទ្ធិរំលាយកិច្ចសន្យាដែលកំណត់ក្នុងច្បាប់ត្រូវបានបញ្ញត្តិឡើង ចាប់ពី **មាត្រា៤០៧ ដល់ ៤១៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧**។

**ឧទាហរណ៍ ៖** ភាគី ក មិនបានប្រគល់នូវកម្មវត្ថុនៅក្នុងអំឡុងពេលសមរម្យទៅតាមកាលបរិច្ឆេទទេ ទោះបីជាមានការដាស់តឿនរបស់ភាគី ខ ក្តី នោះភាគី ខ អាចលើកឡើងអំពីពីការរំលាយកិច្ចសន្យាបាន ។ នៅក្នុងករណីនេះការរំលាយកិច្ចសន្យារបស់ភាគី ខ ត្រូវបានអនុវត្តដោយផ្អែកលើ**មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧**។

### ២.ការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា

ការរំលាយកិច្ចសន្យាដែលមានកំណត់ក្នុងកិច្ចសន្យា គឺជាការរំលាយដោយមូលហេតុដែលភាគីបានកំណត់ជាមុននៅក្នុងកិច្ចសន្យា មានន័យថាភាគីម្ខាង ឬ ភាគីទាំងសងខាងអាចរំលាយកិច្ចសន្យាបានដោយផ្អែកលើកិច្ចសន្យានោះតែម្តង។

**ឧទាហរណ៍ ៖** ប្រសិនបើភាគីនៃកិច្ចសន្យាបានធ្វើការព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាជាមុនថា អ្នកទិញ អាចធ្វើការរំលាយកិច្ចសន្យាជាឯកតោភាគី នៅពេលណាក៏បានក្នុងរយៈពេលមួយសប្តាហ៍មុនពេលប្រគល់នូវកម្មវត្ថុ ដូច្នេះអ្នកទិញអាចរំលាយកិច្ចសន្យាបានតាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យានោះផ្ទាល់តែម្តង។

### ៣.ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេស

ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេសត្រូវបានកំណត់ ទៅតាមកិច្ចសន្យាសំខាន់នីមួយៗដាច់ដោយឡែកពីគ្នា ដូចជា៖ កិច្ចសន្យាលក់-ទិញ កិច្ចសន្យាជួល (ភតិសន្យា) និង កិច្ចសន្យាម៉ៅការជាដើម។
**ឧទាហរណ៍ ៖** នៅក្នុងមាត្រា ៦៦៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានបញ្ញត្តិថាម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ ។ នេះគឺជាសិទ្ធិរំលាយកិច្ចសន្យារបស់ម្ចាស់ការនៅក្នុងកិច្ចសន្យាម៉ៅការ។

### ៤.ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង

ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង គឺជាការរំលាយកិច្ចសន្យាដោយផ្អែកទៅលើឆន្ទៈរបស់គូភាគីដែលបានព្រមព្រៀងគ្នាជាថ្មី ដែលភាគីទាំងសងខាងមិនបានចែងអំពីការរំលាយនេះនៅក្នុងកិច្ចសន្យារបស់ខ្លួននៅពេលបង្កើតនោះទេ។

**ឧទាហរណ៍ ៖** លោក ក បានជួលដីមួយកន្លែងឲ្យលោក ខ ក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ។ មិនទាន់ដល់រយៈពេល ៥ (ប្រាំ) ឆ្នាំផងលោក ក ក៏ចង់បានដីនោះមកប្រើប្រាស់វិញ ក្នុងគោលបំណងរបស់ខ្លួនហើយ លោក ក បានដាក់សំណើទៅលោក ខ អំពីការរំលាយកិច្ចសន្យាជួលនោះ ដោយយល់ព្រមបង់សំណងខូចខាតទៅកាន់លោក ខ ហើយលោក ខ ក៏បានយល់ព្រម។ ដូចនេះភាគីទាំងពីរបានព្រមព្រៀងគ្នារំលាយកិច្ចសន្យា ដូចនេះការរំលាយកិច្ចសន្យាអាចប្រព្រឹត្តទៅបានដោយមានការព្រមព្រៀងថ្មីរបស់គូភាគីទាំងសងខាង។

ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀងមានលក្ខណៈខុសគ្នាបន្តិច ពីការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ និង ការរំលាយកិច្ចសន្យាដែលកំណត់នៅក្នុងកិច្ចសន្យា ដោយហេតុថាការរំលាយកិច្ចសន្យាតាមការព្រមព្រៀងតម្រូវឲ្យមានឆន្ទៈរបស់ភាគីទាំងសងខាង ដោយឡែកការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ និង ការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យាអាចធ្វើឡើងដោយឯកតោភាគីបាន។

## ផ្នែកទី២ ៖ មូលហេតុនៃការរំលាយកិច្ចសន្យា

### កថាភាគទី១ ៖ កិច្ចសន្យាឯកតោភាគី

កិច្ចសន្យាឯកតោភាគី គឺជាកិច្ចសន្យាដែលបង្កើតកាតព្វកិច្ចចំពោះតែភាគីតែម្ខាងនៃកិច្ចសន្យា។ **ឧទាហរណ៍ ៖** ប្រទានកម្ម ដែលមានចែងនៅក្នុងមាត្រា ៥៦៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ។

កិច្ចសន្យាឯកតោភាគីនេះ គឺមិនចាំបាច់ទទួលស្គាល់ការរំលាយទេ ដោយហេតុថាមានតែភាគីតែម្ខាងទេនៃកិច្ចសន្យាដែលទទួលរ៉ាប់រងកាតព្វកិច្ច ។

### កថាភាគទី២ ៖ កិច្ចសន្យាអញ្ញមញ្ញ

កិច្ចសន្យាអញ្ញមញ្ញ គឺជាកិច្ចសន្យាដែលភាគីទាំងសងខាងនៃកិច្ចសន្យាមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមកដូចជា ៖ កិច្ចសន្យាម៉ៅការ កិច្ចសន្យាជួល (ភតិសន្យា) ឬ កិច្ចសន្យាលក់ទំនិញជាដើម។ ជាទូទៅកិច្ចសន្យាអញ្ញមញ្ញ គឺជាកិច្ចសន្យាដែលបង្កើតឲ្យមានកាតព្វកិច្ចទៅវិញទៅមក (កាតព្វកិច្ចបដិការ) រវាងភាគីទាំងសងខាងនៃកិច្ចសន្យា ពោលគឺភាគីទាំងសងខាងជាម្ចាស់បំណុលផង និង ជាកូនបំណុលផង ។ នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ការសន្យារបស់ភាគីនៃកិច្ចសន្យាទាំងពីរគឺចំណុះគ្នាទៅវិញទៅមក ។ ប្រសិនបើអ្នកលក់ត្រូវបានសន្យាថានឹងប្រគល់ទំនិញនេះ គឺថាអ្នកលក់ត្រូវទទួលបាននូវតម្លៃដែលបានព្រមព្រៀងគ្នា ។ ដូចគ្នានេះដែរអ្នកទិញត្រូវតែទូទាត់តម្លៃដែលជាថ្នូរនៃការសន្យានៃការប្រគល់ទំនិញ។ ដូច្នេះវាកើតមាននូវចំណងគតិយុត្តរវាង

កាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យាអញ្ញមញ្ញ។ ចំពោះការរំលាយកិច្ចសន្យាអាចធ្វើទៅបានចំពោះតែកិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះ ដោយសារតែការរំលាយកិច្ចសន្យា គឺជាប្រព័ន្ធដែលភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ដោយយកការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុដើម្បីសុំរំលាយកិច្ចសន្យា ។

## កថាភាគទី៣ ៖ ការបំពានកិច្ចសន្យាធ្ងន់ធ្ងរដោយភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ

ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។[40] ចំពោះករណីដែលត្រូវបានចាត់ទុកថាមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរមានលក្ខណៈដូចខាងក្រោម៖

### ១.ការរំលាយកិច្ចសន្យាដោយការដាស់តឿនភាគីម្ខាងមិនអនុវត្តកាតព្វកិច្ច

យោងតាមមាត្រា៤០៨ កថាខណ្ឌទី១ ចំណុច ក នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យ ដើម្បីឲ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តនៅក្នុងអំឡុងពេលនោះ។

**ឧទាហរណ៍ ៖** នៅក្នុងកិច្ចសន្យាលក់-ទិញវត្ថុមួយ ភាគីអ្នកទិញមិនបានបង់ប្រាក់ថ្លៃទិញនៅក្នុងកាលបរិច្ឆេទកំណត់ទេ នោះភាគីអ្នកលក់ត្រូវដាស់តឿនឱ្យភាគីអ្នកទិញអនុវត្តកាតព្វកិច្ចដោយកំណត់អំឡុងពេលសមរម្យមួយ នៅក្នុងករណីដែលអ្នកទិញនៅតែមិនអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលសមរម្យតាមដែលបានដាស់តឿននោះទេ ភាគីអ្នកលក់អាចរំលាយកិច្ចសន្យានោះបាន។

### ២.ការរំលាយកិច្ចសន្យាដោយមូលហេតុយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

យោងតាមមាត្រា៤០៨ កថាខណ្ឌទី១ ចំណុច ខ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។

**ឧទាហរណ៍ ៖** នៅក្នុងកិច្ចសន្យាលក់ទិញមួយ លោក ក ជាអ្នកទិញ និង លោក ខ ជាអ្នកលក់ហើយ កម្មវត្ថុនៃការលក់ទិញនោះគឺ កុំព្យូទ័រមួយគ្រឿង ក្នុងករណីដែលលោក ក បានបញ្ជាទិញកុំព្យូទ័រនោះពីលោក ខ ក្នុងគោលបំណងយកមកបំពេញការងាររបស់គាត់ ដែលគាត់បានកំណត់ពេលវេលាជាក់លាក់មួយចំពោះលោក ខ

[40] មាត្រា ៤០៨ ចំណុចទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

តែដល់ថ្ងៃដែលបានកំណត់ កុំព្យូទ័រនោះមិនបានប្រគល់ជូនលោក ក ទេ រហូតដល់ដប់ថ្ងៃបន្ទាប់ទើបបានប្រគល់ជូនលោក ក ។ ក្នុងករណីនេះហៅថាមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ហើយលោក ក អាចរំលាយកិច្ចសន្យាបានភ្លាមៗ ។

## ៣.ការរំលាយកិច្ចសន្យាដោយអលទ្ធភាពក្នុងការផ្តល់នូវតាវកាលិកចម្បង

យោងតាមមាត្រា៤០៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់នូវតាវកាលិកចម្បងរបស់ខ្លួនបានទេ ។ ក្នុងករណីនេះ គឺថាខ្លឹមសារនៃតាវកាលិក ដែលកើតចេញពីកិច្ចសន្យានោះមិនបានអនុវត្តដោយមានបញ្ហាកើតឡើងនានា។ តាវកាលិកចម្បងគឺជាសកម្មភាពដែលភាគីមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ប្រសិនបើតាវកាលិកនោះមិនត្រូវបានផ្តល់ឲ្យលើសពីនេះទៅទៀតតាវកាលិកចម្បង ត្រូវសម្រេចដោយផ្អែកលើលក្ខណៈ ឬ ខ្លឹមសារនៃកិច្ចសន្យា និងឆន្ទៈរបស់គូភាគី។

**ឧទាហរណ៍ ៖** លោក ក ជាអ្នកទិញ និង លោក ខ ជាអ្នកលក់ កម្មវត្ថុនៃការលក់ទិញនោះគឺ អគារ ប៉ុន្តែអគារនោះជាប់សិទ្ធិជួលរបស់លោក គ ក្នុងរយៈពេល ១០(ដប់)ឆ្នាំ។ ក្នុងករណីនេះកាតព្វកិច្ចចម្បងរបស់អ្នកលក់ គឺផ្ទេរកម្មសិទ្ធិ និង ផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះ។ ហេតុការណ៍នេះគឺច្បាស់លាស់ហើយថា អ្នកលក់មិនអាចផ្ទេរការកាន់កាប់ទៅឲ្យអ្នកទិញបានទេ ដូចនេះវាជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ហើយអ្នកទិញអាចរំលាយកិច្ចសន្យានោះបាន។

## ៤.ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់ជំនឿចិត្តរវាងគូភាគី

យោងតាមមាត្រា៤០៨ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឲ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាពេលអនាគតបាន។

**ឧទាហរណ៍ ៖** នៅក្នុងកិច្ចសន្យាជួលផ្ទះមួយកន្លែង លោក ក ដែលជាអ្នកជួលផ្ទះ (ភតិកៈ) និងលោក ខ ដែលជាម្ចាស់ផ្ទះ (ភតិបតី)។ លោក ក បានសន្យានឹងលោក ខ ថានឹងបង់ថ្លៃប្រាក់ឈ្នួលផ្ទះនោះក្នុងរយៈពេល ៣(បី) ថ្ងៃ ប៉ុន្តែបីថ្ងៃបានកន្លងផុតទៅ លោក ក មិនបានប្រគល់ប្រាក់ឈ្នួលនោះទៅឲ្យលោក ខ ឡើយ គឺទាល់តែរហូតដល់ ២ (ពីរ) ខែក្រោយបន្ទាប់ ទើបលោក ក បានប្រគល់ ប្រាក់ឈ្នួលនោះទៅឲ្យលោក ខ។ ក្នុងន័យនេះ អាចចាត់ទុកថាជាការបំពានកិច្ចសន្យាដែលមានលក្ខណៈហួសហេតុ ធ្វើឲ្យលោក ខ ដែលជាម្ចាស់ផ្ទះបាត់បង់នូវទំនុកចិត្ត។ ដូចនេះលោក ខ អាចរំលាយកិច្ចសន្យាជួលនោះបានដោយមូលហេតុខាងលើ។

## ផ្នែកទី៣ ៖ វិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា

ការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យានឹងត្រូវកើតមានឡើង ប្រសិនបើលក្ខខណ្ឌសម្រាប់ការរំលាយកិច្ចសន្យាដែលបានចែងនៅក្នុងមាត្រា ៤០៧ និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ត្រូវបានបំពេញគ្រប់គ្រាន់ ហើយសិទ្ធិនៃការរំលាយកិច្ចសន្យានេះនឹងត្រូវចាប់ផ្តើមទៅដោយភាគីម្ខាងនៃកិច្ចសន្យា ហើយនឹងត្រូវចាប់ផ្តើមមានអានុភាពនៅពេលដែលភាគីនេះបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទៅដល់ភាគីម្ខាងទៀត។ សិទ្ធិរំលាយនៃការរំលាយកិច្ចសន្យា គឺជាសកម្មភាពឯកតោភាគីដែលត្រូវយកមកអនុវត្តផងដែរ ដោយភាគីម្ខាងនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យាដោយខ្លួនឯកឯងបានក្នុងការបង្ហាញឆន្ទៈមួយយ៉ាងពិតប្រាកដ ប៉ុន្តែការបង្ហាញឆន្ទៈក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា ចាប់ផ្តើមមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈរំលាយបានទៅដល់ភាគីម្ខាងទៀត ហើយភាគីនោះបានទទួលអំពីការជូនដំណឹងនៃការរំលាយកិច្ចសន្យានោះនាំអោយការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យានឹងត្រូវចាប់ផ្តើមមានអានុភាព។ ក្នុងករណីដែលភាគីនៃកិច្ចសន្យាពុំបានទទួលអំពីការជូនដំណឹងពីភាគីដែលមានបំណងរំលាយកិច្ចសន្យាទេ នោះកិច្ចសន្យាក៏មិនមានអានុភាពក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាបានដែរ ដូច្នេះគូភាគីនៅតែអនុវត្តកាតព្វកិច្ចរបស់ខ្លួន ទៅតាមខលក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចសន្យាដូចដើម។

វិធីក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាគឺ ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យាតាមរយៈការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន ដោយការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅប្រព័ន្ធតុលាការ និង តាមប្រព័ន្ធតុលាការបានហើយមានលក្ខខណ្ឌពិសេសមួយចំនួនទៀតដែលភាគីម្ខាងមានសិទ្ធអនុវត្តរំលាយកិច្ចសន្យាទៅចំពោះភាគីម្ខាងទៀត ដោយការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអាចដកវិញបាន ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់លក្ខខណ្ឌបង្អង់ និងការរំលាយកិច្ចសន្យាដោយភាគីម្ខាងដែលមានគ្នាច្រើននាក់។[41]

### កថាភាគទី ១ ៖ ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចធ្វើនៅក្រៅតុលាការបាន ពីព្រោះតែការរំលាយកិច្ចសន្យាគឺជាសកម្មភាពសំខាន់មួយ ដែលមានប្រទេសខ្លះអនុម័តយកទស្សនៈដែលការសំដែងឆន្ទៈរំលាយអាចធ្វើបានតែក្នុងតុលាការដូចជាតាមច្បាប់បារាំងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាតម្រូវអោយមានសេចក្តីសម្រេចរបស់តុលាការ។ ដោយឡែកក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានអនុញ្ញាតអោយមានការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានៅក្រៅតុលាការបាន ដោយពិចារណាលើភាពងាយស្រួលនៃការរំលាយដែលជាមធ្យោបាយសង្គ្រោះ

[41] មាត្រា ៤០៩ និង ៤១០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

មួយចំពោះការបំពានកិច្ចសន្យា ហើយម្យ៉ាងវិញទៀតដោយហេតុថាវាជាការលំបាកក្នុងការសុំអោយតុលាការចេញសេចក្តីសម្រេចនៅគ្រប់ពេលដែលភាគីម្ខាងមានបំណងរំលាយកិច្ចសន្យា ទោះបីជាភាគីពុំមានវិវាទធ្ងន់ធ្ងរជាមួយភាគីម្ខាងទៀតក៏ដោយ។

ភាគីអាចអនុវត្តសិទ្ធិរំលាយកិច្ចសន្យានៅក្រៅប្រព័ន្ធតុលាការដោយរួមមាន៖ ការរំលាយតាមកិច្ចសន្យា ការរំលាយតាមការព្រមព្រៀងគូភាគី ការរំលាយតាមសន្ធានកម្ម និង ការរំលាយតាមមជ្ឈត្តការ ។ គូភាគីនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យានៅក្រៅប្រព័ន្ធតុលាការតាមផ្នែកខាងលើណាមួយក៏បាន ដោយមិនអោយភាគីណាមួយនៃកិច្ចសន្យាទទួលរងនូវផលខូចខាតប្រយោជន៍ផ្ទាល់ខ្លួនជាដាច់ខាត ។

### ១.ការរំលាយតាមកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយដែលត្រូវបានផ្តល់អោយទៅភាគីនៃកិច្ចសន្យាក្នុងការរំលាយកិច្ចសន្យា ក្នុងករណីដែលបានកំណត់មួយចំនួនទោះបីជាមិនមានការអនុវត្តកាតព្វកិច្ចក៏ដោយ ។ សិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យានេះ ត្រូវបានអនុវត្តតាមការបង្ហាញឆន្ទៈឯកតោភាគីរបស់អ្នកដែលមានសិទ្ធិរំលាយ។ ការរំលាយតាមកិច្ចសន្យានេះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចដែរ ដែលវាគឺជាការរំលាយតាមច្បាប់បានកំណត់ ។[42] ដូចនេះសិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាវិធីមួយក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ដែលត្រូវបានផ្តល់អោយទៅភាគីម្ខាង ឬ ភាគីសងខាងតាមកិច្ចសន្យា ពីព្រោះសិទ្ធិនេះផ្តល់ដោយកិច្ចសន្យា។[43]

**ឧទាហរណ៍៖** លោក ក បានចុះកិច្ចសន្យាជួលផ្ទះពីលោក ខ ក្នុងរយៈពេល ២ឆ្នាំ ដោយនៅក្នុងកិច្ចសន្យាជួលផ្ទះនោះ មានខសន្យាដែលចែងថា " ក្នុងស្ថានការណ៍ដែលផ្នែកសេដ្ឋកិច្ចមានការផ្លាស់ប្តូរ ឬក៏ស្ថានការណ៍មួយដែលកើតឡើងមិនអាចទាយទុកមុនបាន នោះភាគីទាំងសងខាងអាចរំលាយកិច្ចសន្យាបានដោយត្រូវធ្វើសេចក្តីជូនដំណឹងជាមុនរយៈពេល ៣ ខែ " ។ នៅក្នុងករណីនេះភាគីដែលពាក់ព័ន្ធទាំងអស់នៅក្នុងកិច្ចសន្យាអាច

[42] គណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤ មាត្រា ៤១៤ ។*

[43] មាត្រា ៤១៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

បង្ហាញឆន្ទៈក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការបាន តាមរយៈការប្រើប្រាស់សិទ្ធិរំលាយតាមកិច្ចសន្យា ។

### ២.ការរំលាយតាមការព្រមព្រៀងគូភាគី

សិទ្ធិនៃការរំលាយកិច្ចសន្យាតាមការព្រមព្រៀងគូភាគី គឺត្រូវអាស្រ័យទៅតាមខ្លឹមសារនៃការព្រមព្រៀងដែលភាគីមានគោលបំណងរំលាយកិច្ចសន្យា ហេតុដូច្នេះមិនចាំបាច់មានបញ្ញាត្តិពិសេស ឬ ក៏ខសន្យានៅក្នុងកិច្ចសន្យាណាមួយឡើយ[44] មានន័យថាភាគីពាក់ព័ន្ធព្រមព្រៀងគ្នារំលាយកិច្ចសន្យា គឺជាករណីដែលគ្មានការសន្យាជាមុនអំពីសិទ្ធិរំលាយកិច្ចសន្យាទេ ប៉ុន្តែការរំលាយកិច្ចសន្យាត្រូវបានធ្វើឡើងដោយកិច្ចសន្យា និង ភាគីអាចព្រមព្រៀងគ្នារំលាយកិច្ចសន្យាបាន។[45]

**ឧទាហរណ៍ ៖** លោក ក និង លោក ខ បានចុះកិច្ចសន្យាជួលឃ្លាំងមួយ ដោយលោក ក ជាភតិបតី និងលោក ខ ជាភតិកៈ ដោយនៅក្នុងកិច្ចសន្យាជួល គឺមានរយៈពេល ៥(ប្រាំ) ឆ្នាំ ប៉ុន្តែដោយជាអកុសលលោក ខ បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយរងរបួសធ្ងន់មិនអាចដើរ និង ធ្វើការបាន ហើយលោក ខ បានជួលឃ្លាំងនោះត្រឹមរយៈពេល ២(ពីរ) ឆ្នាំប៉ុណ្ណោះ បន្ទាប់មកទៀតលោក ខ បានស្នើសុំឈប់ជួល មុនកាលកំណត់ដូចបានចែងនៅក្នុងកិច្ចសន្យា ហើយលោក ក ក៏យល់ព្រម និង បានព្រមព្រៀងគ្នារំលាយកិច្ចសន្យាជួលឃ្លាំងនោះដែលមានរយៈពេល ៥(ប្រាំ)ឆ្នាំ។

ដោយយោងតាមស្ថានភាពនៃអង្គហេតុខាងលើនេះ ករណីនេះហើយដែលគេហៅថាការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាតាមការព្រមព្រៀងគូភាគី ។[46]

---

[44] គណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤ មាត្រា ៤១៤

[45] គណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤ មាត្រា ៤០៩

[46] មាត្រា ៤១៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ៣.ការរំលាយតាមសន្ធានកម្ម

វិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ គឺភាគីនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈក្នុងការរំលាយកិច្ចសន្យាតាមសន្ធានកម្មផងដែរ ក្នុងករណីដែលភាគីនៃកិច្ចសន្យាមិនអាចសម្របសម្រួលគ្នាបានក្នុងការអនុវត្តសិទ្ធិរំលាយតាមកិច្ចសន្យា និង ការរំលាយកិច្ចសន្យាតាមការព្រមព្រៀងគូភាគី ហេតុដូច្នេះភាគីនៃកិច្ចសន្យាអាចជ្រើសរើសវិធីម្យ៉ាងទៀត គឺ ការរំលាយកិច្ចសន្យាតាមសន្ធានកម្ម ដើម្បីការពារកុំអោយខាតផលប្រយោជន៍រៀងខ្លួន ។

សន្ធានកម្ម គឺជាការចរចាដែលមានជំនួយ ឬ ការជួយសម្របសម្រួល សន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬ ច្រើនដែលព្យាយាមចរចាលើដំណោះស្រាយ ដោយមានជំនួយពីភាគីទីបីដែលហៅថា សន្ធានការី ដែលត្រូវឈរលើអព្យាក្រឹត្យភាពចំពោះភាគីវិវាទ និង រកវិធីដំណោះស្រាយមួយដ៏សមស្របប្រកបដោយភាពយុត្តិធម៌ជូនទៅដល់ភាគីវិវាទ។ ការដោះស្រាយតាមសន្ធានកម្ម អាចដោះស្រាយបានគ្រប់វិវាទទាំងអស់ដែលកើតមានឡើងជូនទៅដល់ភាគីជម្លោះទាំងអស់ ដោយរកវិធីដំណោះស្រាយដ៏ល្អមួយជូនទៅដល់ភាគីដែលពួកគេមិនអាចព្រមព្រៀងក្នុងប្រការណាមួយបាន។ សន្ធានកម្មនឹងកើតមានឡើង ប្រសិនបើមានកាលៈទេសៈណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំងបីដែលកើតមានឡើងដូចជា[47]៖

១. ភាគីមាន ខសន្យាស្ដីពីដំណោះស្រាយវិវាទ នៅក្នុងកិច្ចសន្យាដែលមានស្រាប់របស់ពួកគេ ដែលបានជ្រើសរើសយកមធ្យោបាយសន្ធានកម្មមកប្រើ។

២. ភាគីសម្រេចចិត្តធ្វើសន្ធានកម្ម បន្ទាប់ពីការចរចា ឬក៏ការព្រមព្រៀងមិនត្រូវរូវគ្នានៅក្នុងវិវាទ។

៣. តុលាការបានបង្គាប់ ឬ ណែនាំអោយភាគីធ្វើសន្ធានកម្ម។

### ៤.ការរំលាយតាមមជ្ឈត្តការ

មជ្ឈត្តការ គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្មហើយអាចស្ថិតនៅក្នុងក្របខណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សារអចិន្ត្រៃយ៍ មានន័យថា មជ្ឈត្តការគឺជាស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដូចនេះគូភាគីបានព្រមព្រៀងគ្នាដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបី ដែលជាបុគ្គលអព្យាក្រឹត្យមួយ ដែលហៅថាមជ្ឈត្តករ ឬ ក្រុមមជ្ឈត្តករ ឬ វេទិការមជ្ឈត្តកម្ម ដោយភាគីទីបីនេះត្រូវមានកាតព្វកិច្ចពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និង ចេញសេចក្ដីសម្រេចហើយត្រូវបានហៅថា មជ្ឈត្តវិនិច្ឆ័យ។

[47] ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា , បោះពុម្ពលើកទី ២ (២០១០) ទំព័រ ៨៣ និង ១០៧

មុននឹងឈានដល់ការដោះស្រាយតាមមជ្ឈត្តកម្ម គឺភាគីជម្លោះតែងតែជ្រើសរើសយកការដោះស្រាយតាមកិច្ចសន្យាដែលមានខចែង តាមការព្រមព្រៀង ឬ ការចរចា ឬ តាមសន្ទានកម្ម យកមកធ្វើយន្តការដោះស្រាយវិវាទជាមុនសិនព្រោះ ការព្រមព្រៀង និងសន្ទានកម្ម មានលក្ខណៈងាយស្រួលចំណាយតិច និង ចំណេញពេលផលាព្រមទាំងអាចរក្សាទំនាក់ទំនងរបស់ភាគីទាំងពីរ។ ប្រសិនបើពួកគេបរាជ័យក្នុងការដោះស្រាយតាមកិច្ចសន្យាដែលមានខចែង តាមការព្រមព្រៀង ឬ ការចរចា ឬ តាមសន្ទានកម្ម ភាគីនឹងចាប់ផ្តើមធ្វើមជ្ឈត្តការ ដូចនេះមជ្ឈត្តកម្មនៅតែត្រូវការយកមកធ្វើជាយន្តការក្នុងការដោះស្រាយវិវាទ ព្រោះការចរចា ឬ សន្ទានកម្មមិនមានលក្ខណៈចាប់បង្ខំដល់ភាគីវិវាទទេ ទោះបីជាភាគីទាំងពីរបានព្រមព្រៀងគ្នាហើយក៏ដោយតែដោយឡែកយន្តការមជ្ឈត្តកម្ម គឺមានលក្ខណៈចាប់បង្ខំទៅដល់ភាគីដែលមិនព្រមគោរព និងអនុវត្តតាមមជ្ឈត្តវិនិច្ឆ័យ។

## កថាភាគទី ២ ៖ ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការ

ការរំលាយកិច្ចសន្យាមិនត្រូវការការអន្តរាគមន៍របស់តុលាការនោះទេ ប្រសិនបើភាគីមិនបានស្នើសុំឲ្យតុលាការចេញសាលក្រមរំលាយកិច្ចសន្យា ។ ការស្នើសុំឲ្យតុលាការចេញសាលក្រមរំលាយកិច្ចសន្យាគឺមានលក្ខណៈជារូបភាពនៃបណ្តឹង ។ បណ្តឹងអាចធ្វើទៅបានក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង ហើយវិវាទនោះអាចដោះស្រាយដោយសាលក្រម ប៉ុន្តែកាលណាបើបណ្តឹងនោះមានលក្ខណៈគ្មានផលប្រយោជន៍នៃបណ្តឹងទេ នោះតុលាការនឹងចេញសាលក្រមលើកចោលបណ្តឹងដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។ តែបើក្នុងករណីដែលភាគីបានបង្ហាញឆន្ទៈតាមផ្លូវតុលាការរួចហើយដូចជា មានកិច្ចព្រមព្រៀងក្នុងការដោះស្រាយតាមផ្លូវតុលាការ ឬ ក៏មានខចែងនៅក្នុងកិច្ចសន្យាអំពីការដោះស្រាយតាមផ្លូវតុលាការ នោះការអន្តរាគមន៍របស់តុលាការមានភាពចាំបាច់ដើម្បីសម្រេចគោលបំណងអោយមានលក្ខណៈជាសត្យានុម័ត ។ ការរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការនឹងមានការកើតឡើងតាមរយៈការធ្វើបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលខុសត្រូវតាមកិច្ចសន្យា រួចទទួលបានមកនូវការប្រកាសចេញសាលក្រម និងការជួសជុលការខូចខាត ។

## កថាភាគទី ៣ ៖ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអាចដកបាន

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអនុញ្ញាតឱ្យដកបានទេ ដោយហេតុថាអាចកើតមានឡើងនូវភាពច្របូកច្របល់ទៅដល់ឋានៈរបស់ភាគីម្ខាងទៀត ឬភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្លាយជាអស្ថិរភាព ប៉ុន្តែជនដែលមានសិទ្ធិរំលាយអាចដកនូវឆន្ទៈរំលាយកិច្ចសន្យបាន នៅពេលដែលការជូនដំណឹងពីការដកឆន្ទៈរំលាយបានទៅដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នា ឬ មុនពេលឆន្ទៈរំលាយបានទៅដល់ភាគីម្ខាងទៀត ពីព្រោះការរំលាយចាប់ផ្តើមមានអានុភាពនៅពេលដែលវាបានទៅដល់ភាគីម្ខាងទៀត។

**ឧទាហរណ៍ ៖** លោក ក បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាជួលផ្ទះមួយពីលោក ខ តែកិច្ចសន្យានេះត្រូវបានរំលាយវិញ ដោយមូលហេតុលោក ក មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយលោក ក បានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ហេតុនេះហើយលោក ខ បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាពី លោក ក ។ បន្ទាប់មកទៀត លោក ខ បានព្រមព្រៀងជួលផ្ទះនោះទៅអោយលោក គ ប៉ុន្តែក្រោយមកទៀត លោក ក និង លោក ខ បានស្រុះស្រួលគ្នាក្នុងការដកនូវការរំលាយកិច្ចសន្យានោះវិញ ដោយផ្អែកតាមការព្រមព្រៀងរវាងលោក ក និង លោក ខ ។ ក្នុងករណីនេះ ការដកនូវការរំលាយកិច្ចសន្យានេះមិនត្រូវបានទទួលស្គាល់ទេ ព្រោះវាត្រូវបានធ្វើអោយខូចខាតប៉ះពាល់ដល់ផលប្រយោជន៍របស់លោក គ ។

## កថាភាគទី ៤ ៖ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់លក្ខខណ្ឌបង្អង់

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់លក្ខខណ្ឌបង្អង់សំដៅទៅលើព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតហើយដែលមិនទៀងទាត់។ ទន្ទឹមនឹងនោះលក្ខខណ្ឌបង្អង់មានន័យថា កាតព្វកិច្ចឬសិទ្ធិនឹងមានអានុភាពនៅពេលដែលលក្ខខណ្ឌបានបំពេញ។

**ឧទាហរណ៍៖** លោក ក បានទិញម៉ូតូមួយគ្រឿងពី លោក ខ ហើយ លោក ក មិនបានបង់ប្រាក់គ្រប់គ្រាន់នៅកាលបរិច្ឆេទប្រគល់នោះទេ បន្ទាប់មក លោក ខ បានប្រាប់ លោក ក ថា គាត់នឹងរំលាយកិច្ចសន្យានៅពេលដែល លោក ក មិនបានបង់ប្រាក់គ្រប់គ្រាន់ក្នុងរយៈពេល១៥ថ្ងៃ ។ ដូច្នេះឆន្ទៈនៃការរំលាយកិច្ចសន្យានេះត្រូវបានដាក់លក្ខខណ្ឌបង្អង់ចំនួន ១៥ ថ្ងៃ ។

### កថាភាគទី ៥ ៖ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយភាគីម្ខាងមានគ្នាច្រើននាក់

យោងតាមមាត្រា ៤១០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ក្នុងករណីដែលភាគីម្ខាងទៀតមានច្រើននាក់ ការរំលាយកិច្ចសន្យាត្រូវធ្វើឡើងដោយបុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ។ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានរលត់ចំពោះបុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលនៃភាគីដែលមានច្រើននាក់ សិទ្ធិរំលាយនោះក៏ត្រូវរលត់ចំពោះបុគ្គលផ្សេងទៀតនៃភាគីនោះដែរ។

**ឧទាហរណ៍ ៖** ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០២០ ក បានលក់អគារមួយអោយទៅ ខ, គ, ឃ និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិអោយទៅអ្នកទាំង ៣។ អ្នកទាំង ៣ មិនបានប្រគល់ប្រាក់គ្រប់ចំនួនទេទោះបីជា ក បានដាស់តឿនយ៉ាងណាក៏ដោយ។ នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០២០ ក បានទូរស័ព្ទទៅប្រាប់ ខ ដើម្បីបង្ហាញឆន្ទៈរំលាយកិច្ចសន្យា។ ហើយថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០២០ ក បានទូរស័ព្ទទៅប្រាប់ គ បន្ទាប់ពីជូនដំណឹងទៅ ខ ដូចនេះ ក បានសំរេចចិត្តធ្វើលិខិតជូនដំណឹងចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០២០ ទៅអោយ ឃ ម្នាក់ទៀតអំពីការរំលាយកិច្ចសន្យាក្នុងប្រអប់សំបុត្រផ្ទះរបស់ ឃ ។ ដូចនេះចំពោះអានុភាពនៃការរំលាយត្រូវកំណត់យកកាលបរិច្ឆេទនៃការជូនដំណឹងចំពោះអ្នកចុងក្រោយ ដោយសារកំណត់យកគោលការណ៍បានទៅដល់។ នៅក្នុងឧទាហរណ៍ខាងលើការបង្ហាញឆន្ទៈរំលាយមានអានុភាពនៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០២០ ជាពេលចុងក្រោយដែលការបង្ហាញឆន្ទៈរំលាយបានដល់ចំពោះភាគីទាំងអស់។

## ផ្នែកទី ៤ ៖ ការរលត់នូវសិទ្ធិនៃការរំលាយកិច្ចសន្យា

### កថាភាគទី ១ ៖ ពេលកម្មវត្ថុនៃកិច្ចសន្យាខូចខាត

សិទ្ធិរំលាយកិច្ចសន្យាត្រូវរំលត់ នៅពេលដែលភាគីមានសិទ្ធិរំលាយធ្វើឲ្យមានការខូចខាត ឬ ធ្វើឲ្យមានការបាត់បង់នូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះបានដោយចេតនា ឬ ធ្វើអោយវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេងដោយការកែច្នៃ ឬ ការផ្លាស់ប្តូរទម្រង់ដោយចេតនា ។

**ឧទាហរណ៍ ៖** កិច្ចសន្យាទិញលក់អង្ករ តែអង្ករដែលបានទិញលក់បានកិនក្លាយទៅជាម្សៅរួចអស់ហើយ ថែមទាំងបានផលិតទៅជានំបុ័ងថែមទៀត។

សិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់ នៅក្នុងករណីវាផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ ប្រសិនបើភាគីដែលបានធ្វើឱ្យខូចខាត ឬមិនអាចសងវត្ថុនោះវិញដោយចេតនា ។

**ឧទាហរណ៍៖** អ្នកទិញរថយន្តរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុរថយន្តនោះមានវិការៈ ប្រសិនបើអ្នកទិញនោះធ្វើអោយខូចខាតដោយចេតនាដល់រថយន្តដែលខ្លួនត្រូវប្រគល់វិញ ហើយខ្លួនចង់រំលាយកិច្ចសន្យានោះ មានន័យថាអ្នកទិញត្រូវបាត់បង់សិទ្ធិរំលាយដោយសិទ្ធិរំលាយនោះត្រូវផុតរលត់ ។

- សិទ្ធិរំលាយកិច្ចសន្យាមិនត្រូវបានរលត់ទេ នៅក្នុងករណីដែលកម្មវត្ថុ គឺត្រូវបានធ្វើឱ្យខូចខាតឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនសងវត្ថុនោះវិញ ដោយអចេតនា ។នៅក្នុងករណីនេះ ភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យា ត្រូវសងជាប្រាក់នូវតំលៃដែលជាកម្មវត្ថុនោះ ត្រឹមកំរិតតំលៃដែលបានកំណត់ក្នុងកិច្ចសន្យា។

**ឧទាហរណ៍៖** ក បានទិញរថយន្តពី ខ ដែលជារថយន្តថ្មី ហើយភាគីទាំងពីរនាក់បានអនុវត្តកាតព្វកិច្ចរួចរាល់ ហើយដោយ ក បានទទួលរថយន្ត និង ខ បានទទួលប្រាក់ តែក្រោយមក ក បានដឹងថារថយន្តនោះមិនមែនជារថយន្តថ្មីទេ ហើយបានទាមទារឱ្យ ខ ប្រគល់រថយន្តថ្មី ដោយកំណត់អំឡុងពេលសមរម្យ តែ ខ នៅតែមិនព្រមប្រគល់ហេតុនេះហើយបានជា ក រំលាយកិច្ចសន្យា តែមុនពេលប្រគល់រថយន្តនោះ ក បានធ្វើឱ្យខូចខាតរថយន្តដោយអចេតនា ។ក អាចរំលាយកិច្ចសន្យាបាន តែត្រូវចេញថ្លៃជួសជុលរថយន្តដែលខ្លួនបានធ្វើឱ្យខូចខាត។

- ករណីប្រធានសក្តិមានន័យថា ជាកម្លាំងដ៏មានឧត្តមភាពជាការកកើតឡើងដោយមិនបានគ្រោងទុកជាគ្រោះថ្នាក់ដែលមិនអាចបញ្ចៀស ឬ តតាំងបាន។ ពាក្យនេះតែងត្រូវបានគេបញ្ចូលក្នុងខចែងរួមនៃកិច្ចសន្យាក្នុងបំណងឲ្យគូភាគីកិច្ចសន្យារួមពីការទទួលខុសត្រូវ ឬ កាតព្វកិច្ចពេលមានព្រឹត្តការណ៍ ឬ កាលៈទេសៈពិសេសកើតឡើងដោយគូភាគីនៃកិច្ចសន្យាមិនអាចត្រួតត្រាបានដូចជា ៖ ព្យុះ សង្គ្រាម ការបះបោរ ទឹកជំនន់ រញ្ជួយដី ភ្នំភ្លើងផ្ទុះជាដើម។

**ឧទាហរណ៍៖** ករណីផ្ទុះឡើងនិងឆ្លងជាសកលនៃវីរុសកូវីដ១៩(COVID19) អាចចាត់ទុកជាវាជាជម្ងឺវីរុសមួយដែលផ្ទុះពេញសាកលលោកធ្វើឲ្យអោយឈឺស្លាប់ ដំណើរការសេដ្ឋកិច្ចគាំងនិងធ្លាក់ចុះមនុស្សមិនអាចប្រកបរបរចិញ្ចឹមជីវិតដូចធម្មតា។

## កថាភាគទី ២ ៖ ការរលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារអាជ្ញាយុកាល

ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារអាជ្ញាយុកាល គឺជាការមិនអនុវត្តកាតព្វកិច្ច និង សិទ្ធិទាមទារបដិទានមានអំឡុងពេល ៥ឆ្នាំក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច ។[48] ការធ្វើបដិទានឡើងវិញនូវស្ថានភាពដើមដោយផ្អែកលើការរំលាយកិច្ចសន្យា មិនត្រូវធ្វើដាច់ពីការរំលាយកិច្ចសន្យាទេ ហើយភាគីដែលមានសិទ្ធិទាមទារឱ្យធ្វើបដិទានត្រូវអនុវត្តសិទ្ធិនេះ នៅមុនពេលសិទ្ធិរំលាយត្រូវរលត់ដោយអាជ្ញាយុកាល។ ការមិនអនុវត្តកាតព្វកិច្ចត្រូវបានគិតចាប់ពីពេលដែលមានការយឺតយ៉ាវ។ ការយឺតយ៉ាវត្រូវបានគិតចាប់ពីពេលដែលភាគីម្ខាងបានអនុវត្តកាតព្វកិច្ចរួចរាល់។

**ឧទាហរណ៍ ៖** ក បាន ទិញរថយន្តមួយពី ខ ដោយ ខ បានប្រគល់រថយន្តឱ្យ ក រួចរាល់ហើយ ក៏ប៉ុន្តែ ក មិនបានប្រគល់ប្រាក់ទេ។ ដូច្នេះ ក ត្រូវស្ថិតក្នុងភាពយឺតយ៉ាវ ចាប់តាំងពីពេលដែល ខ ប្រគល់រថយន្ត។ នៅក្នុងករណីនេះអាជ្ញាយុកាលនៃការរំលត់ត្រូវគិតចាប់ពីពេលដែល ក ស្ថិតនៅក្នុងភាពយឺតយ៉ាវ។ ដូច្នេះ ខ ត្រូវអនុវត្តសិទ្ធិរំលាយកិច្ចសន្យា និងសិទ្ធិទាមទារបដិទានក្នុងអំឡុងពេល ៥ឆ្នាំ ចាប់ពីពេលប្រគល់របស់ ខ។

ចំពោះសិទ្ធិនៃការទាមទារអោយធ្វើបដិទានដែលកើតឡើងដោយអនុវត្តសិទ្ធិរំលាយកិច្ចសន្យាគ្មានអាជ្ញាយុកាលដោយឡែកពិសេសទេ ហេតុដូច្នេះសិទ្ធិទាមទារអោយធ្វើបដិទាននេះនឹងត្រូវរលត់ ប្រសិនបើមិនទាមទារអោយធ្វើបដិទានមុនអាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាត្រូវបានសម្រេច។

## កថាភាគទី ៣ ៖ ការរលត់សិទ្ធិរំលាយកិច្ចសន្យាដោយការអនុវត្តកាតព្វកិច្ចគូភាគី

យោងតាមមាត្រា ៤០៨ កថាខណ្ឌទី១ វាក្យខណ្ឌ ក នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចមាន លក្ខខណ្ឌចំនួន៣ គឺ៖

- កូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេល
- ម្ចាស់បំណុលដាស់តឿនកូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តក្នុងអំឡុងពេលកំណត់សមរម្យ
- កូនបំណុល មិនអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលសមរម្យ

អានុភាពនៃការរំលាយកិច្ចសន្យា ដោយផ្អែកលើមូលហេតុថាការយឺតយ៉ាវនៅក្នុងអនុវត្តកាតព្វកិច្ចគឺភាគីម្ខាងទៀតមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយភាគីដែលចង់រំលាយកិច្ចសន្យាបានដាស់តឿនអោយអនុវត្តកាតព្វកិច្ចដោយកំណត់អំឡុងពេលសមរម្យ ប៉ុន្តែកូនបំណុលមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនក្នុង

[48] មាត្រា ៤១៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អំឡុងពេលនោះ ប៉ុន្តែប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលនោះ នោះកាតព្វកិច្ចត្រូវរលត់ដោយសារការអនុវត្តកាតព្វកិច្ចពីកូនបំណុល ដូចនេះសិទ្ធិរំលាយក៏ត្រូវរលត់ដែរ។

**ឧទាហរណ៍ ៖** ក បានទិញរថយន្តមួយគ្រឿងពី ខ ក្នុងតម្លៃ ២០ ០០០ដុល្លារអាមេរិក។ ក ក៏បានបង្កើតកិច្ចសន្យាទិញលក់ ដែលចុះនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៣ ។ បន្ទាប់មក ខ បានប្រគល់រថយន្តនោះទៅអោយ ក តាមកិច្ចសន្យា តែ ក មិនបានបង់ប្រាក់គ្រប់ចំនួននោះទេដោយនៅខ្វះទឹកប្រាក់ចំនួន ៥ ០០០ ដុល្លារអាមេរិកទៀត ដោយ ក បានធ្វើការសន្យាថានឹងប្រគល់អោយនៅ ថ្ងៃទី ៣១ មករា ឆ្នាំ ២០២៣។ លុះមកដល់ថ្ងៃកំណត់ ក នៅតែមិនទាន់បង់ប្រាក់ដែលខ្វះនៅឡើយទៅឱ្យ ខ ទៀត ។ បន្ទាប់មកទៀត ខ ក៏បានចេញលិខិតដាស់តឿន ទៅដល់ ក ក្នុងការសងប្រាក់ដែលមានអំឡុងពេល ១ខែ សំរាប់ការសងបើ ក មិនសងទេនោះ ខ នឹងធ្វើការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា។ លុះដល់ពេលវេលាជិត ១ខែ ក ក៏បានប្រគល់ប្រាក់ដែលនៅខ្វះចំនួន ៥ ០០០ដុល្លារអាមេរិកទៅឱ្យ ខ។ ដូចនេះសិទ្ធិរំលាយកិច្ចសន្យារបស់ ខ គឺត្រូវបានរលត់ដោយសារការអនុវត្តកាតព្វកិច្ចរបស់ ក ដែលជាភាគីនៃកិច្ចសន្យា ។

ដូច្នេះនៅក្នុងករណីនេះគេអាចទទួលស្គាល់ថា សិទ្ធិរំលាយរបស់ម្ចាស់បំណុលត្រូវរលត់ដោយសារការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល។

## ផ្នែកទី ៥ ៖ អានុភាពនៃការរំលាយកិច្ចសន្យា

ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នឹងធ្វើអោយកិច្ចសន្យានោះត្រូវបានរំលាយ ។ ការរំលាយកិច្ចសន្យានាំអោយគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។ ភាគីម្ខាងនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ដោយធ្វើលិខិតដាស់តឿនក្នុងការអនុវត្តកាតព្វកិច្ច តែបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទៀត នោះសិទ្ធិនៃការរំលាយកិច្ចសន្យានឹងត្រូវមានអានុភាព ដោយភាគីនៃកិច្ចសន្យាមិនចាំបាច់អនុវត្តកាតព្វកិច្ចទៀតទេ ។ ថ្វីត្បិតតែការរំលាយកិច្ចសន្យាបានកន្លងផុតទៅមែន តែការសងសំណងការខូចខាតនៅតែកើតមានឡើងគឺ ដើម្បីសងនូវការរងផលប៉ះពាល់ខូចខាត និង ផលប្រយោជន៍ដែលភាគីបានបាត់បង់នៅក្នុងកិច្ចសន្យា ។ ចំពោះអាជ្ញាយុកាលនៃការរលត់សិទ្ធិទាមទារអោយសងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច មានអំឡុងពេល ៥(ប្រាំ)ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះបានកើតឡើង។[49] អំឡុងពេលនៃអាជ្ញាយុកាល អាចត្រូវបានគិតចាប់ពីពេលដែលមិនអនុវត្តកាតព្វកិច្ចរបស់ភាគីណាមួយនៃកិច្ចសន្យា ប៉ុន្តែវាគួរតែគិតបន្ទាប់ពីការចាប់ផ្ដើមកើតមានការខូចខាតដោយហេតុថាភាគីណាម្នាក់អាច

[49] មាត្រា ៤០៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ទាមទារសំណងបានលុះត្រាតែការខូចខាតណាមួយកើតឡើង។ ដូច្នេះហើយអំឡុងពេលនៃអាជ្ញាយុកាលត្រូវបានគណនាចាប់ពីពេលដែលការខូចខាតកើតឡើង។

**ឧទាហរណ៍ ៖** អ្នកទទួលបញ្ញើដែលថែរក្សាកែវដែលជាកម្មសិទ្ធិរបស់អ្នកផ្ញើ ដោយផ្អែកលើកិច្ចសន្យាបញ្ញើ បានធ្វើអោយបែកកែវនោះដោយកំហុសក្នុងការគ្រប់គ្រង នោះអ្នកទទួលបញ្ញើត្រូវសងសំណងការខូចខាតជាទឹកប្រាក់ស្មើនឹងតម្លៃនៃកែវនោះ ដូច្នេះកម្មសិទ្ធិលើកែវនោះនឹងត្រូវផ្ទេរទៅឲ្យអ្នកទទួលបញ្ញើដែលសងសំណងការខូចខាត ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងត្រូវគិតចាប់ពីពេលដែលកែវនោះបានបែក។

នៅពេលដែលអានុភាពកើតចេញពីការរំលាយកិច្ចសន្យានោះនឹងអោយមានលក្ខណវិនិច្ឆ័យថ្មីមួយទៀតនៃអានុភាពនោះគឺ អានុភាពប្រតិសកម្ម ដែលទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា និង អានុភាពមិនប្រតិសកម្ម ដែលមិនទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា។

- អានុភាពប្រតិសកម្ម គឺត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ដូច្នេះយោងតាមគំនិតនេះតាវកាលិកដែលភាគីម្ខាងបានទទួល ត្រូវប្រគល់ទៅឱ្យភាគីម្ខាងទៀតវិញ ដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ នៅពេលកិច្ចសន្យាត្រូវបានរំលាយ ។[50]

**ឧទាហរណ៍ ៖** ក្នុងកិច្ចសន្យា លោក ក បានទិញអង្ករពី លោក ខ ចំនួន ១០ គីឡូក្រាម ដែលមួយគីឡូមានតំលៃ ១ម៉ឺនរៀល ដោយលោក ក បានទទួលអង្ករហើយបានអោយលុយទៅលោកខ ចំនួន៦ម៉ឺនរៀល ប៉ុន្តែ ក មិនទាន់បានបង់ប្រាក់៤ម៉ឺន រៀលទៀតទេទោះបីជាលោក ខ បានដាស់តឿនហើយបានដាក់ពេលកំណត់សមរម្យដើម្បីអោយលោក ក បង់ប្រាក់ក៏ដោយ។ លោក ក បានប្រើប្រាស់អង្ករអស់ ៣ គីឡូទៅហើយ ក្នុងករណីនេះលោក ខ អាចរំលាយកិច្ចសន្យា ដូច្នេះភាគីទាំងសងខាងត្រូវធ្វើបដិទានឡើងវិញនូវស្ថានភាពដើមដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ។ លោក ខ ត្រូវប្រគល់ប្រាក់ ៦ម៉ឺនរៀលអោយទៅ ក ហើយ ក ត្រូវប្រគល់អង្ករ ១០គីឡូក្រាមអោយលោក ខ វិញ ក៏ប៉ុន្តែលោក ក ប្រើប្រាស់អង្ករអស់ ៣ គីឡូក្រាមរួចទៅហើយ ដូច្នេះលោក ក ត្រូវសងមកវិញនូវអង្ករ ៣ គីឡូក្រាមដែលបានប្រើអស់ ឬ ត្រូវសងជាប្រាក់ ៣ម៉ឺនរៀលដែល មានតម្លៃស្មើនឹងអង្ករដែលលោក ក បានប្រើអស់នោះ។

---

[50] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២ ទំព័រ១៨៤ ( រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣ )

- យោងតាមមាត្រា៤១១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានចែងថាភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាមួយភាគ ឬ ទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបានបដិទានឡើងវិញដោយសារការរំលាយ ក្នុងករណីដែលភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។ផ្អែកតាមគំនិតនេះ ការរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថាគ្មានអានុភាពប្រតិសកម្ម ដូច្នេះសិទ្ធិលើបំណុល និង កាតព្វកិច្ចដើមត្រូវផ្លាស់ប្តូរទៅជាសិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់គូភាគីនេះគឺ ព្រោះតែ មាត្រា ៤១១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ខាងលើបានចែងបញ្ជាក់ច្បាស់ពីចំណុចបដិទាននូវតាវកាលិកដែលភាគីបានទទួល ។

**ឧទាហរណ៍ ៖** ក្នុងកិច្ចសន្យាលក់ទិញ ក បានទិញកុំព្យូទ័រមួយគ្រឿងពី ខ ។ខ បានប្រគល់កុំព្យូទ័រឱ្យ ក រួចហើយ ប៉ុន្តែ ក មិនបានបង់ប្រាក់ឱ្យ ខ ទេ ទោះបីជា ខ បានដាស់តឿនហើយបានដាក់ពេលកំណត់សមរម្យដើម្បីអោយ ក បង់ប្រាក់ក៏ដោយ ដែលនេះជាហេតុធ្វើឱ្យ ខ រំលាយកិច្ចសន្យា ។ ដោយផ្អែកលើអានុភាពមិនប្រតិសកម្មមានអានុភាពហូតដល់មានការរំលាយកិច្ចសន្យា តាវកាលិកដែលភាគី ក បានទទួលបានត្រូវតែ បង្វិលឱ្យភាគី ខ វិញ ។ ការផ្ទេរកុំព្យូទ័រទៅវិញនេះខុសពីករណីនៃអានុភាពប្រតិសកម្ម ព្រោះការសងតាវកាលិកត្រឡប់ទៅវិញនេះ គឺជាកាតព្វកិច្ចថ្មី មិនមែនផ្អែកលើសេចក្តីចម្រើនឥតហេតុដូចករណីដែលផ្អែកលើទ្រឹស្តីអានុភាពប្រតិសកម្មនោះទេ។

សរុបមកលក្ខណៈនៃអានុភាពនៃការរំលាយកិច្ចសន្យាទាំង ២ ខាងលើ សុទ្ធតែចងកាតព្វកិច្ចដល់ភាគីត្រូវតែប្រគល់តាវកាលិកត្រលប់ទៅវិញទាំងអស់ឱ្យទៅម្ចាស់ដើមវិញ ហើយក៏មិនមានគំនិតណាមួយប្រឆាំងនឹងការត្រលប់ទៅវិញដែរ លើកលែងតែប្រភេទកិច្ចសន្យានោះមិនអាចប្រគល់ត្រលប់បានដូចការបកស្រាយខាងលើ។

អានុភាពនៃការរំលាយកិច្ចសន្យា គឺមានអានុភាពទៅលើភាគីក្នុងការរំលត់ករណីយកិច្ចនៅក្នុងកិច្ចសន្យាដោយបង្កើតកាតព្វកិច្ចថ្មីក្នុងការសងតាវការលិក និង សំណងការខូចខាតដែលកើតឡើងទៅម្ចាស់ដើមវិញក្នុងពេលអនាគតណាមួយ ហើយអានុភាពនៃការរំលាយកិច្ចសន្យា ក៏មានអានុភាពទៅលើតតិយជនដែរ ក្នុងការការពារផលប្រយោជន៍មិនអោយរងនូវការខូចខាតពីការរំលាយកិច្ចសន្យាពីភាគីកិច្ចសន្យាមុន។ ការការពារផលប្រយោជន៍ទៅលើតតិយជន លុះត្រាតែកិច្ចសន្យានោះត្រូវបានបង្កើតអោយមានលក្ខណៈគតិយុត្តតាមផ្លូវច្បាប់ និង មិនមានវិការៈនៅក្នុងកិច្ចសន្យា ហើយតតិយជនមានគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ។

## កថាភាគទី ១ ៖ អានុភាពនៃការរំលាយកិច្ចសន្យាចំពោះគូភាគី

អានុភាពនៃការរំលាយកិច្ចសន្យានាំអោយគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាលើកលែងតែករណីយកិច្ចសងការខូចខាត[51] មានន័យថាទំនាក់ទំនងភាគីនៅក្នុងកិច្ចសន្យានឹងមានការកែប្រែប្រួលនូវកាតព្វកិច្ច ។

### ១. ភាគីនៃកិច្ចសន្យារួចផុតពីកាតព្វកិច្ច និង អញ្ញត្រកម្ម

អានុភាពនៃការរំលាយកិច្ចសន្យាធ្វើអោយចំណង និង ទំនាក់ទំនងនៃកិច្ចសន្យានឹងត្រូវរលត់ ។ ការរំលាយកិច្ចសន្យានឹងរលត់រាល់កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និង នាំអោយគូភាគីនៃកិច្ចសន្យារួចផុតកាតព្វកិច្ចពីកិច្ចសន្យានោះ ប៉ុន្តែក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច នោះករណីយកិច្ចសងសំណងការខូចខាតរបស់កូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចនៅតែមានអានុភាព ដែលវាជាអញ្ញត្រកម្មនៅក្នុងកិច្ចសន្យាសំរាប់ភាគីដែលបានបាត់បង់ផលប្រយោជន៍ ដោយភាគីម្ខាងទៀតដែលទទួលបានតាវកាលិកតាមកិច្ចសន្យា ត្រូវមានកាតព្វកិច្ចផ្ទេរតាវកាលិកនោះមកអោយវិញ។ ចំពោះកាតព្វកិច្ចដែលភាគីនៅមិនទាន់បានបំពេញរវាងគ្នានៅក្នុងកិច្ចសន្យានឹងគ្នាត្រូវរលត់ឆ្ពោះទៅអនាគត ដោយសារការរំលាយកិច្ចសន្យា ដូចនេះនាំអោយកាតព្វកិច្ចភាគីត្រូវបញ្ចប់ លើកលែងតែសំណងខូចខាតដែលវាជាការទទួលខុសត្រូវក្រៅកិច្ចសន្យា។

### ២. ការធ្វើបដិទាន

បដិទាន គឺជាការស្តារឡើងវិញនូវស្ថានភាពដើម ឬ ការប្រគល់ត្រឡប់វិញ។[52] អានុភាពនៃការរំលាយកិច្ចសន្យានឹងនាំអោយមានការកើតឡើងនូវអានុភាពប្រតិសកម្ម និង មិនប្រតិសកម្មដោយភាគីនៃកិច្ចសន្យាត្រូវធ្វើបដិទានគ្នាទៅវិញទៅមកនូវរាល់កម្មវត្ថុ ឬ ក៏តាវកាលិកទាំងឡាយដែលបានចុះក្នុងកិច្ចសន្យា ដោយត្រូវផ្ទេរកម្មសិទ្ធិទៅម្ចាស់ដើមវិញ។ ការផ្ទេរកម្មសិទ្ធិ ត្រូវបានចាត់ទុកថាភាគីនៃកិច្ចសន្យានោះមិនមែនជាកម្មសិទ្ធិករតាំងពីដំបូង ដូច្នេះកម្មសិទ្ធិករដែលជាម្ចាស់នៃកម្មវត្ថុនោះ អាចទាមទារនូវសិទ្ធិក្នុងការគ្រប់គ្រងលើវត្ថុរបស់ខ្លួនវិញបាន ។

[51] មាត្រា ៤១១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[52] តាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.១ ការធ្វើបដិទានទៅស្ថានភាពដើម

ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀតដើម្បីអោយភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយកិច្ចសន្យា។ ក្នុងករណីដែលភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។[53]

**ឧទាហរណ៍ ៖** លោក ក បានទិញគោ (ដើម) ពីលោក ខ ដោយកាតព្វកិច្ចមិនអនុវត្តព្រមគ្នាទេ គឺ លោក ក គាត់យកគោទៅផ្ទះមើលសិន ទើបគាត់បង់ប្រាក់តាមក្រោយ។ លុះមួយសប្តាហ៍ក្រោយមកលោក ខ បានទៅដាស់តឿនឱ្យលោក ក អនុវត្តកាតព្វកិច្ច តែលោក ក គេចវេស ។ ហេតុផលនេះហើយធ្វើឱ្យលោក ខ សម្រេចចិត្តរំលាយកិច្ចសន្យាចោល ហើយទាមទារឱ្យលោក ក ប្រគល់គោមកវិញ។ លោក ក គាត់ យល់ព្រមប្រគល់គោនោះមកវិញ ប៉ុន្តែគោនោះបានកើតកូនហើយគាត់ទាមទារកូនគោថាជារបស់គាត់ ដោយមូលហេតុថា កូនគោនោះកើតនៅពេលដែលស្ថិតនៅក្រោមការកាន់កាប់របស់គាត់។ នៅក្នុងករណីនេះលោក ខ មានសិទ្ធិទាមទារកូនគោ នោះមកវិញផងដែរ ដោយហេតុថាកូនគោនោះគឺជាផលដែលកើតចេញកម្មវត្ថុនៃកិច្ចសន្យា ដូច្នេះវាមិនត្រឹមត្រូវទេដែលឱ្យបុគ្គលដែលបានបំពានកិច្ចសន្យាធ្វើឱ្យខូចខាតផលប្រយោជន៍របស់ភាគីម្ខាងទៀត មានសិទ្ធិទទួលបានផលពីកម្មវត្ថុនៃកិច្ចសន្យា។ ក្រៅពីតាវកាលិកជាប្រាក់ដែលខ្លួនបានទទួល ភាគីត្រូវសងទៅវិញទៅមកផងដែរ នូវការប្រាក់នៃប្រាក់ដែលបានទទួល និង ផលប្រយោជន៍ទាំងឡាយបានមកពីការប្រើប្រាស់តាវកាលិកដែលទទួលបាន។[54] ក្នុងន័យនេះកាតព្វកិច្ចធ្វើបដិទាន មានន័យថា មិនត្រឹមតែទៅស្ថានភាពពេលបង្កើតកិច្ចសន្យាទេ ប៉ុន្តែជាការធ្វើបដិទានទៅដល់ស្ថានភាពដែលអាចមាន ។

### ២.២ ការធ្វើបដិទានមិនអាចទៅតាមស្ថានភាពដើម

ក្នុងករណីដែលភាគីនៃកិច្ចសន្យាមិនអាចសងត្រឡប់ទៅវិញនូវកម្មវត្ថុ មានន័យថាការធ្វើបដិទានមិនអាចទៅតាមស្ថានភាពដើមនូវកម្មវត្ថុដែលបានចែងនៅក្នុងកិច្ចសន្យាទេ ដូចនេះនៅពេលកម្មវត្ថុក្នុងកិច្ចសន្យារងការខូចខាត ឬ មានការផ្លាស់ប្តូរតាមទម្រង់ដើម នោះសិទ្ធិរំលាយត្រូវរលត់ចំពោះភាគីមានសិទ្ធិរំលាយ។

[53] មាត្រា ៤១១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[54] មាត្រា ៤១១ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

សិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់ក្នុងករណីដែលភាគីមានសិទ្ធិរំលាយ ៖

1. បានធ្វើឱ្យមានការខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះទៅវិញដោយចេតនា។
2. ធ្វើឱ្យវត្ថុនោះ ក្លាយជាវត្ថុផ្សេងដោយសារការកែច្នៃ ឬការផ្លាស់ប្តូរទ្រង់ទ្រាយ ឬ និយាយម្យ៉ាងទៀតថា នៅក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើឱ្យខូចខាត ឬបាត់បង់ ឬមិនអាចសងត្រឡប់មកវិញបានដោយចេតនា នោះសិទ្ធិរំលាយមិនត្រូវបានរំលត់ទេ មានន័យថាអ្នកមានសិទ្ធិរំលាយនៅតែអាចរំលាយបាន ប៉ុន្តែត្រូវសងជាប្រាក់នូវតម្លៃដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់នៅក្នុងកិច្ចសន្យា។

**ឧទាហរណ៍ ៖** នៅក្នុងកិច្ចសន្យាទិញលក់លោក ក បានទិញពិរថយន្តពីលោក ខ ដែលជារថយន្តថ្មី ហើយភាគីទាំងពីរនាក់បានអនុវត្តកាតព្វកិច្ចរួចរាល់ហើយ ដោយលោក ក បានទទួលរថយន្ត និង លោក ខ បានទទួលប្រាក់ទាំងអស់នោះផងដែរ។ ប៉ុន្តែក្រោយមកលោក កបានដឹងថារថយន្តនោះមិនមែនជារថយន្តថ្មីទេ ហើយបានទាមទារអោយលោក ខ ប្រគល់រថយន្តថ្មីដោយកំណត់អំឡុងពេលសមរម្យ តែលោក ខ នៅតែមិនព្រមប្រគល់ ហេតុនេះហើយបានជា លោក ក រំលាយកិច្ចសន្យា តែមុនពេលប្រគល់រថយន្តនោះលោក ក បានធ្វើអោយខូចខាតរថយន្តដោយអចេតនាក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ។ ដូចនេះ លោក ក អាចរំលាយកិច្ចសន្យាបាន តែត្រូវចេញថ្លៃជួសជុលរថយន្តនោះ ដែលខ្លួនបានធ្វើអោយខូចខាតដោយអចេតនាក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ ហើយលោក ខ ត្រូវប្រគល់ប្រាក់អោយគ្រប់ចំនួនដែលទទួលបានពីលោក ក ជាមួយនឹងការប្រាក់។ ជាទូទៅ នៅក្នុងករណីបែបនេះ លោក ក អាចរំលត់កាតព្វកិច្ចរបស់ខ្លួនត្រឹមកម្រិតនៃចំនួនប្រាក់ដែលស្មើគ្នាដោយបង្ហាញឆន្ទៈទូទាត់។[55]

### **កថាភាគទី ២ ៖ អានុភាពចំពោះតតិយជន**

ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ ។ នេះគឺជាគោលបំណងក្នុងការការពារស្ថិរភាពជំនួញរបស់តតិយជនដែលត្រឹមត្រូវមិនឱ្យស្ថិតនៅក្នុងស្ថានភាពមួយដែលមាននូវការព្រួយបារម្ភ មិនមែនគ្រប់តតិយជនសុទ្ធតែត្រូវបានការពារទាំងអស់នោះទេ លុះត្រាតែតតិយជននោះមានភាពត្រឹមត្រូវតាមច្បាប់។ ចំពោះការការពារតតិយជនគឺអាស្រ័យទៅលើថា តើអានុភាពប្រតិសកម្មត្រូវបានទទួលស្គាល់ ឬមិនទទួលស្គាល់។ ការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអានុភាពប្រតិសកម្ម គឺជាបញ្ហាដែល

[55] មាត្រា ៤៦៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

មានលក្ខណៈទ្រឹស្តីស្មុគស្មាញ ដែលត្រូវទុកដោះស្រាយតាមយុត្តិសាស្ត្រនាពេលអនាគតដោយមិនចែងក្នុងក្រមរដ្ឋប្បវេណីទេ។

**ឧទាហរណ៍ ៖** ក បានលក់ដីទៅ ឱ្យ ខ ហើយ ខ បានលក់ដីនេះបន្តទៅឱ្យ គ ។ ក៏ប៉ុន្តែ ខ បានខកខាន ក្នុងការបង់ថ្លៃទិញដីដែលធ្វើឱ្យ ក រំលាយកិច្ចសន្យា ។ នៅក្នុងករណីនេះបញ្ហាកើតឡើងត្រង់ថា អ្នកទិញ ខ បានលក់ដីនេះបន្តឱ្យតតិយជន គ មុនពេលដែលអ្នកលក់ ក បង្ហាញឆន្ទៈរំលាយកិច្ចសន្យា ។

ទស្សនៈឱ្យមានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យាគឺអ្នកទិញ ខ មិនមែនជាកម្មសិទ្ធិករនៃដីតាំងពីដំបូងដោយសារការរំលាយ។ ហេតុនេះហើយតតិយជន គ ត្រូវចាត់ទុកថាបានទិញដីពីអ្នកទិញ ខ ដែលមិនមានកម្មសិទ្ធិលើដីនេះ ដូច្នេះតតិយជន គ មិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដីនេះបានទេ។ ប៉ុន្តែក្នុងករណីដែលតតិយជន គ បានចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិរួចហើយ ប្រសិនបើតតិយជន គ មិនអាចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើដីនេះ ដោយសារការរំលាយកិច្ចសន្យាដោយអ្នកលក់ ក នោះតតិយជន គ នឹងទទួលការខូចខាតដែលខ្លួនមិនអាចព្យាករទុកជាមុនបានហើយធ្វើឱ្យបាត់បង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់តតិយជន គ ដោយធ្វើប្រតិបត្តិការដោយជឿទុកចិត្តលើការចុះបញ្ជីកម្មសិទ្ធិរបស់ ខ ។ ទស្សនៈមិនឱ្យមានអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យាទោះបីជាអ្នកលក់ ក រំលាយកិច្ចសន្យា លក់ទិញក៏ដោយ អ្នកទិញ ខ មិនត្រូវចាត់ទុកថាគ្មានកម្មសិទ្ធិលើដីតាំងពីដំបូងទេ ប៉ុន្តែនៅពេលអ្នកលក់ ក បង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ កម្មសិទ្ធិនឹងត្រូវបង្វិលពីតតិយជន គ មកឱ្យអ្នកលក់ ក វិញ។ ចំពោះការផ្ទេរ បង្វិលកម្មសិទ្ធិក្នុងករណីនេះ ការចុះបញ្ជីគឺជាលក្ខខណ្ឌតតាំងចំពោះអចលនវត្ថុ ( មាត្រា ១៣៤ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ )។ ហេតុដូច្នេះទោះបីជាអ្នកលក់បានទទួលកម្មសិទ្ធិដីពីអ្នកទិញដោយសារការរំលាយកិច្ចសន្យាក៏ដោយ ប្រសិនបើតតិយជន គ បានចុះបញ្ជីអំពីការផ្ទេរមុនអ្នកលក់ ក ចុះបញ្ជីអំពីការផ្ទេរបង្វិល នោះតតិយជន គ នឹងមានអាទិភាព ហើយអ្នកលក់ ក មិនអាចទាមទារឱ្យលុបចោលការចុះបញ្ជីរបស់តតិយជន គ បានឡើយ។

សរុបមកទោះបីជាការពន្យល់ខាងលើមានភាពស្មុគស្មាញ ... ហើយទោះបីជាយកទស្សនៈណាមួយក៏ដោយ វាជាការសមស្របក្នុងការការពារតតិយជនដែលបានចុះបញ្ជី ដែលជាជនសុចរិត និង គ្មានកំហុស។

### ១. តតិយជននៃគោលការណ៍ប្រតិសកម្ម

ចំពោះតតិយជនមុនការរំលាយកិច្ចសន្យាវិញ គេអាចចាត់ទុកថា តតិយជនត្រូវទទួលបានការកាន់កាប់ ឬ ចុះបញ្ជី ដើម្បីទទួលបាននូវការការពារមាត្រា ៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ព្រោះតតិយជនត្រូវបានគេចាត់ទុកថាបានខិតខំប្រឹងប្រែងជាអតិបរមា ដើម្បីការពារសិទ្ធិរបស់ខ្លួន

ដោយផ្អែកលើគំនិតនេះ ការកាន់កាប់ ឬ ការចុះបញ្ជី មានតួនាទីបង្កើតបាននូវ " លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃសិទ្ធិរក្សាការពារ " ។ ផ្ទុយទៅវិញគេអាចគិតថា លក្ខខណ្ឌតតាំងមិនមានលក្ខណៈចាំបាច់សម្រាប់តតិយជនក្នុងការទទួលបានការការពារទេ ព្រោះមាត្រា៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មិនបានតម្រូវឱ្យមានលក្ខខណ្ឌតតាំងសម្រាប់តតិយជនទេ។

ផ្អែកលើភាពប្រតិសកម្មតតិយជនដែលបានចុះកិច្ចសន្យានៅក្រោយការរំលាយកិច្ចសន្យា មិនអាចទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ទេ ព្រោះអានុភាពប្រតិសកម្មបានកើតឡើងរួចហើយ ។ តតិយជននៅ ក្រោយការរំលាយកិច្ចសន្យាត្រូវបានចាត់ថាបានទទួលកម្មសិទ្ធិពីជនដែលមិនមានកម្មសិទ្ធិ ដូច្នេះតតិយជនមិនអាចធ្វើលទ្ធកម្មសិទ្ធិទេ។ ជាការពិតនៅក្នុងករណីដែលកម្មសិទ្ធិគឺជាចលនវត្ថុ អនុប្បទានិកអាចធ្វើលទ្ធកម្មលើកម្មសិទ្ធិបាន បើសិនអនុប្បទានិកជាជនសុចរិត និង គ្មានកំហុស ដោយបំពេញលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា ក៏ប៉ុន្តែនៅក្នុងករណីកម្មវត្ថុ គឺជាអចលនវត្ថុតតិយជនមិនអាចទទួលបានកម្មសិទ្ធិ តាមរយៈលទ្ធកម្មដោយសុចរិតនោះទេ ។ ជាលទ្ធផលគឺមានគំនិតមួយដែលការពារតតិយជនប្រភេទនេះ តាមរយៈការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា៣៥៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ។ ព្រោះអាចនិយាយបានថា ក បាន បន្សល់ទុកនូវការចុះបញ្ជី ហើយបានបង្កើតនូវទិដ្ឋភាពមួយដែលបង្ហាញថា ខ គឺជាកម្មសិទ្ធិករលើអចលនវត្ថុនោះ ហើយ គ បានជឿជាក់ថា ខ គឺជាម្ចាស់សិទ្ធិពិតប្រាកដមែន។ មូលហេតុដែលក្រមរដ្ឋប្បវេណីធ្វើការការពារតតិយជនដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ព្រោះជនដែលបង្កើតនូវទិដ្ឋភាពមិនពិត មិនមានសិទ្ធិក្នុងការអះអាងនូវមោឃភាពនៃកិច្ចសន្យាចំពោះតតិយជនដែលបានជឿជាក់ទៅលើទិដ្ឋភាពនោះដោយមានហេតុផលឡើយ។ គោលការណ៍នេះទាញចេញពី " លទ្ធិដែលមានលក្ខណៈជារូបភាព "។[56]

[56] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២ ទំព័រ១៩៣ ( រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣ )

## ២. តតិយជននៃគោលការណ៍មិនមានអានុភាពប្រតិសកម្ម

ដោយផ្អែកលើភាពមិនប្រតិសកម្ម ការរំលាយកិច្ចសន្យាមិនមានអានុភាពប្រតិសកម្មទេ ។ ទោះបីជាមានការរំលាយកិច្ចសន្យាក៏ដោយ ។ ប៉ុន្តែទោះបីជាការរំលាយមិនមានអានុភាពប្រតិសកម្មតែពេលមានការរំលាយកិច្ចសន្យាម្ចាស់កម្មសិទ្ធិអាចទាមទារឱ្យធ្វើការផ្ទេរកម្មវត្ថុត្រឡប់មកវិញបានទោះបីជាវត្ថុនោះត្រូវបាន ផ្ទេរឱ្យតតិយជនហើយក៏ដោយ។

ផ្អែកលើគំនិតនេះវាមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្ទេរពីរដងជាន់គ្នា ដោយមិនគិតថាតតិយជនបានទិញកម្មវត្ថុនៅមុន ឬ នៅក្រោយការរំលាយកិច្ចសន្យាទេ ដូច្នេះបុគ្គលណាដែលបានទទួលនូវលក្ខខណ្ឌតតាំងមុនបុគ្គលផ្សេងទៀត អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន។ វាមានន័យថាទោះបីជាមិនមានបញ្ញត្តិដូចមាត្រា៤១១ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ក៏លទ្ធផលដូចគ្នានឹងការផ្ទេរពីរដងជាន់គ្នា ដូច្នេះមាត្រា៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ គឺមិនមែនជាបញ្ញត្តិពិសេស ដើម្បីការពារតតិយជនដែលមានផលប្រយោជន៍ស្របច្បាប់ គឺគ្រាន់តែជាបញ្ញត្តិបញ្ជាក់បន្ថែមតែប៉ុណ្ណោះ។[57]

### កថាភាគទី ៣ ៖ករណីយកិច្ចសងសំណងនៃការខូចខាត

សំណងការខូចខាត គឺជាការសងនូវសំណងពីសំណាក់កូនបំណុល ចំពោះការខូចខាតដែលកើតមានចំពោះម្ចាស់បំណុល ។ សំណងការខូចខាតកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច និង សកម្មភាពអំពើអនីត្យានុកូល ។ សំណងការខូចខាតនឹងផ្តល់អោយម្ចាស់បំណុល ប៉ុន្តែការទទួលសំណងនេះគឺលុះត្រាតែគោរពនូវលក្ខខណ្ឌដើម្បីទទួលបានសំណង ។[58] ការរមិនអនុវត្តកាតព្វកិច្ច និង សកម្មភាពអំពើអនីត្យានុកូលគឺតម្រូវអោយកូនបំណុលមានការទទួលខុសត្រូវក្នុងការសងសំណងខូចខាតដែលកើតមានឡើងតាមកិច្ចសន្យា ។ ករណីពិសេសមួយចំនួនដែលកូនបំណុលអាចជៀសផុតក្នុងការទទួលខុសត្រូវកិច្ចសន្យាបានផងដែរ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថាខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត។

---

[57] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ២ ទំព័រ១៩៣ (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣)

[58] មាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

**១.ការទទួលខុសត្រូវកិច្ចសន្យា**

អំពើនៃការទទួលខុសត្រូវដែលកើតចេញពីការមិនប្រត្តិបត្តិកិច្ចសន្យា ឬ ក៏អនុវត្តតាមកិច្ចសន្យា នោះបណ្តាលអោយមានការខូចខាតដល់ជនរងគ្រោះភាគីនៃកិច្ចសន្យា។ ដូច្នេះប្រសិនបើភាគីនៃកិច្ចសន្យាមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទៅតាមកិច្ចសន្យាទេ នោះភាគីនៃកិច្ចសន្យាត្រូវមានការទទួលខុសត្រូវលើកិច្ចសន្យាទៅតាមទំហំនៃសំណងការខូចខាត[59] ដែលពិចារណា និង គណនាទៅលើការខូចខាតជាធម្មតា ឬ ជាការខូចខាតដោយកាលៈទេសៈពិសេស ឬ ជាឆន្ទៈព្យាបាទ និង អំពើមិនស្មោះត្រង់។

**ក. ការខូចខាតជាធម្មតា ៖** ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលអនុញ្ញាតអោយម្ចាស់បំណុលទទួលបាននូវសំណងការខូចខាតត្រឹមតែតម្លៃនៃកម្មវត្ថុដែលខូចខាតនោះ។

**ឧទាហរណ៍ ៖** ក្រុមហ៊ុនលក់អំបិល បានលក់អំបិលចំនួន ១ តោន ដែលមានតម្លៃស្មើនឹង ១០០០ដុល្លារអាមេរិក អោយលោក ក ប៉ុន្តែអំបិលនោះដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាតមុនពេលប្រគល់។ តើលោក ក ត្រូវទទួលបានសំណងការខូចខាតប៉ុន្មាន? ដូច្នេះនៅក្នុងករណីនេះ ក្រុមហ៊ុនលក់អំបិលត្រូវបានចាត់ទុកថាអលទ្ធភាពនៅក្នុងការអនុវត្តដែលតម្លៃថ្លូនោះគឺជាការខូចខាតធម្មតា មានន័យថាក្រុមហ៊ុនលក់អំបិលត្រូវសងការខូចខាត ដែលបានកើតឡើងទៅតាមតម្លៃនៃកម្មវត្ថុនៃកិច្ចសន្យាជូនដល់លោក ក ។

**ខ. ការខូចខាតដោយកាលៈទេសៈពិសេស ៖** កើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈទេសៈពិសេសត្រូវបានសង ប្រសិនបើការកើតឡើងនៃការខូចខាតពិសេសនេះត្រូវបានគូភាគីអាចព្យាករណ៍បាន។

**ឧទាហរណ៍ ៖** ក្នុងករណីដែលលោក ខ បានទិញរថយន្តមួយពីលោក ក នៅក្នុងតម្លៃ ២០.០០០ដុល្លារអាមេរិក ប៉ុន្តែលោក ក មិនបានប្រគល់រថយន្តទេនៅកាលបរិច្ឆេទកំណត់។ ទន្ទឹមនឹងនេះលោក ខ បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តនេះជាមួយនឹងលោក គ នៅក្នុងតម្លៃ ២០.៥០០ដុល្លារអាមេរិក) ។ បន្ទាប់មកលោក គ បានរំលាយកិច្ចសន្យាជាមួយនឹងលោក ខ ដោយសារការយឺតយ៉ាវនៅក្នុងការអនុវត្តកាតព្វកិច្ចរបស់លោក ខ ។ នៅក្នុងករណីនេះការខូចខាតពិសេសគឺ ៥០០ដុល្លារអាមេរិក ដែលជាផលប្រយោជន៍ពីការលក់បន្តទៀត។ នៅក្នុងករណីការខូចខាតពិសេស ម្ចាស់បំណុលត្រូវបង្ហាញថាការកើតឡើងនៃការខូចខាតពិសេសត្រូវបានព្យាករណ៍ជាមុនដោយគូភាគីនៅពេលបង្កើតកិច្ចសន្យា។នៅក្នុងករណីខាងលើការខូចខាតពិសេស គឺផលប្រយោជន៍នៃការលក់ឡានបន្តទៀតចំនួន ៥០០ដុល្លារអាមេរិក ហើយកាលៈទេសៈពិសេសគឺជាអង្គហេតុដែលលោក ខ បានធ្វើ

[59] មាត្រា ៤០១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

កិច្ចសន្យាលក់បន្តជាមួយ នឹងបុគ្គលដទៃទៀត។ នៅក្នុងករណីនេះប្រសិនបើលោក ក បានដឹងថាលោក ខ បានចុះកិច្ចសន្យាលក់ទិញជាមួយនឹងលោក គ នៅក្នុងតម្លៃ ២០.៥០០ដុល្លារដុល្លារអាមេរិក នោះគាត់ត្រូវសង ៥០០ដុល្លារអាមេរិក ដែលជាការខូចខាតពិសេស ប៉ុន្តែប្រសិនបើលោក ក បានដឹងថាលោក ខ បានចុះកិច្ចសន្យាលក់ទិញជាមួយនឹង លោក គ ប៉ុន្តែលោក ក មិនបានដឹងពីតម្លៃទេ នោះការខូចខាតដែលលោក ក ត្រូវសង គឺជាភាពខុសគ្នារវាង ២០.០០០ដុល្លារ និង តម្លៃថយន្តនៅលើទីផ្សារ។

ករណីលើកលែង ប្រសិនបើគូភាគីមិនបានគិតគូរពិចារណាអំពីការខូចខាតពិសេសនោះនៅពេលបង្កើតកិច្ចសន្យាទេ នោះកូនបំណុលមិនចាំបាច់សងសំណងនៃការខូចខាតពិសេសឡើយ។[60]

**គ. ការមិនអនុវត្តកាតព្វកិច្ចដោយឆន្ទៈព្យាបាទ ឬអំពើមិនស្មោះត្រង់ ៖** នៅក្នុងចំណោមការមិនអនុវត្តកាតព្វកិច្ច គឺមានករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយមានគោលបំណងបង្កនូវការខូចខាតទៅដល់ម្ចាស់បំណុល។ នៅក្នុងករណីនេះយើងអាចទាមទារអោយតុលាការបង្គាប់អោយកូនបំណុលសងផលប្រយោជន៍ទៅអោយម្ចាស់បំណុលដូចជា ការខូចខាតផលប្រយោជន៍ ឬ ផលប្រយោជន៍ដែលកូនបំណុលទទួលបាន ប្រសិនបើមានការខូចខាតកើតឡើង។

**ឧទាហរណ៍ ៖** លោក ក គឺជាម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូក បានលក់ជ្រូកមួយចំនួនអោយ ទៅលោក ខ ដែលជាម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូកដែរ ប៉ុន្តែ ជ្រូកដែលលោក ក បានលក់អោយទៅលោក ខ នោះមានជម្ងឺ ហើយលោក ក បានដឹងពីហេតុនេះរួចមកហើយនៅមុនពេលប្រគល់ ប៉ុន្តែមិនបានប្រាប់ទៅលោក ខ ទេ ។ បន្ទាប់មកជ្រូករបស់លោក ខ ទាំងអស់បានឆ្លងជម្ងឺ និងស្លាប់ទាំងអស់ ការខូចខាតប្រភេទនេះត្រូវបានចាត់ទុកថាជាឆន្ទៈព្យាបាទ និងត្រូវសងសំណងនៃការខូចខាត ទោះបីជាការខូចខាតនោះមិនអាចព្យាករណ៍បានមុនក៏ដោយ ។ ឆន្ទៈព្យាបាទមិនចាំបាច់តែទាក់ទងទៅនឹងអំពើមិនស្មោះត្រង់ហួសហេតុទេ ប៉ុន្តែគោលគំនិតនៃអំពើមិនស្មោះត្រង់ហួសហេតុគឺត្រូវបានរាប់បញ្ចូលទាំងគូភាគីដែលមានឆន្ទៈព្យាបាទនៅពេលធ្វើការកំណត់ពីទំហំនៃការខូចខាត។

អាជ្ញាយុកាលនៃការទាមទារសំណងការខូចខាត ត្រូវធ្វើក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ ក្រោយពេលការខូចខាតកើតឡើងមិនមែនក្រោយការមិនអនុវត្តកាតព្វកិច្ចនោះទេ។ ដូចនេះសំណងការខូចខាត គឺជាផ្នែកនៃការទទួលខុសត្រូវ នៅពេលដែលបុគ្គលណាម្នាក់មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

[60] មាត្រា ៤០១ ចំណុច ខ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ២.ការរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា

កូនបំណុលដែលធ្វើអោយមានការខូចខាត ត្រូវរួចផុតពីកាតព្វកិច្ចដែលដាក់បន្ទុកមកលើខ្លួន ដែលតម្រូវអោយមានការជួសជុលការខូចខាតដែលជនរងគ្រោះបានទទួលទាំងស្រុង ឬ មិនទាំងស្រុង ក្នុងករណីដែលកូនបំណុល ឬ ជនទទួលខុសត្រូវ បានបង្ហាញភស្តុតាងថាការខូចខាតនោះបណ្តាលមកពីករណីពុំគាប់ជួនដូចជា ៖

- ប្រធានសក្តិ
- កំហុសជនរងគ្រោះ
- អំពើរបស់តតិយជន

### ២.១. ករណីប្រធានសក្តិ

ប្រធានសក្តិ គឺជាព្រឹត្តិការណ៍ទាំងឡាយដែលមិនអាចប៉ាន់ស្មានដឹងបានជាមុន និង មិនអាចជំនះបានហើយដែលវារារាំងមិនអោយកូនបំណុលបំពេញកាតព្វកិច្ចរបស់ខ្លួនបាន ដូចជា៖ សង្គ្រាម ការបះបោរ ជំងឺរាតត្បាតចង្រៃ ( COVID-19…) គ្រោះធម្មជាតិ ។ល។

**ឧទាហរណ៍ ៖** លោក ក បានចុះកិច្ចសន្យាទិញលក់រូបគំនូរពីលោក ខ នៅថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០១០ ហើយលោក ក បានសន្យាថានឹងប្រគល់ប្រាក់អោយគ្រប់ចំនួននៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ។ លុះដល់ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១០ ផ្ទះរបស់លោក ខ ត្រូវបានឆ្លងចរន្តអគ្គិសនីនឹងត្រូវបានឆាបឆេះយ៉ាងសន្ធោសន្ធៅដែលធ្វើអោយផ្ទះរបស់លោក ខ ខូចខាតយ៉ាងដំណំរួមជាមួយនឹងរូបគំនូរ និង ក្រដាសផ្ទាំងដែលផ្ទុកសំរាប់គូររូបគំនូរផ្សេងៗ និង ផ្ទាំងរូបគំនូដែលជាកម្មវត្ថុនៃកិច្ចសន្យារវាងលោក ក និង លោក ខ នោះផងដែរ។ ដូចនេះ លោក ខ អាចរួចផុតពីការទទួលខុសត្រូវលើកិច្ចសន្យា ព្រោះថានេះជាករណីប្រធានសក្តិមួយដែលយើងមិនអាចជំនះបាន និង ប៉ាន់ស្មានដឹងជាមុន។

### ២.២. កំហុសជនរងគ្រោះ

បើសិនកំហុសជនរងគ្រោះជាមូលហេតុតែមួយនៃការខូចខាត នោះវាគ្មានចំណងហេតុផលរវាងការខូចខាតហើយនឹងអំពើរបស់ចុងចំលើយទេ នោះចុងចំលើយត្រូវរួចផុតពីការទទួលខុសត្រូវទាំងស្រុង ។ ប៉ុន្តែបើនៅក្នុងករណីដែល ជនរងគ្រោះមានកំហុស ហើយចុងចំលើយក៏មានកំហុសដែរនោះ ការទទួលខុសត្រូវត្រូវចែកគ្នាទទួលខុសត្រូវ។ ការបែងចែកការទទួលខុសត្រូវ ត្រូវធ្វើទៅតាមភាពធ្ងន់ស្រាលនៃកំហុសរបស់ម្នាក់ៗ។

**ឧទាហរណ៍ ៖** លោក ក បានផ្ញើពែងបុរាណដែលមានតម្លៃមួយទៅតាមលោក ខ ដែលជាអ្នកបើកបរនៅក្រុមហ៊ុនដឹកជញ្ជូនមួយយកទៅអោយមិត្តភក្តិរបស់គាត់។ បន្ទាប់មកទៀត លោក ខ បានរៀបចំដឹកជញ្ជូនពែងបុរាណដែលមានតម្លៃនោះដោយមានសុវត្ថិភាព ជូនទៅមិត្តភក្តិរបស់លោក ក ។ នៅក្នុងកំឡុងពេលធ្វើដំណើរមានបុរសម្នាក់ដើរឆ្លងផ្លូវដោយបំពានភ្លើងសញ្ញាអ្នកថ្មើរជើង បុរសនោះបានដើរឆ្លងផ្លូវទាំងប្រញាប់ប្រញាល់នៅចំពីមុខឡានរបស់ លោក ខ ដែលកំពុងដឹកជញ្ជូនឥវ៉ាន់ជូនទៅអតិថិជន ។ ហេតុការណ៍នេះបានធ្វើឱ្យ លោក ខ ព្យាយាមចាប់ហ្វ្រាំងឡានពេញមួយទំហឹង រួចធ្វើអោយឡានរបស់លោក ខ ត្រូវធ្លាក់ផ្លូវទៅម្ខាងទៀត ហើយឥវ៉ាន់នៅក្នុងឡានរបស់លោក ខ ក៏បានប៉ះទង្គិចជាមួយនឹងឥវ៉ាន់ផ្សេងទៀត ហើយក៏បានធ្វើអោយប៉ះពែងបុរាណដែលមានតម្លៃរបស់លោក ក ផងដែរ ។ ចំណែកឯបុរសដែលដើរឆ្លងផ្លូវដោយបំពានភ្លើងសញ្ញាអ្នកថ្មើរជើងទាំងប្រញាប់ប្រញាល់នោះក៏រងរបួស និង មានសភាពធ្ងន់ផងដែរ។

ដូចនេះ នៅក្នុងករណីនេះលោក ខ អាចរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា ដែលវាជាកំហុសជនរងគ្រោះដែលបុរសនោះបានដើរឆ្លងផ្លូវដោយបំពានភ្លើងសញ្ញាអ្នកថ្មើរជើងទាំងប្រញាប់ប្រញាល់ ដូចនេះរាល់ការខូចខាតគឺកំហុសជនរងគ្រោះជាអ្នកទទួលខុសត្រូវ ក៏ប៉ុន្តែប្រសិនបើក្នុងករណីវាជាកំហុសជនរងគ្រោះផង និងលោក ខ ផង នោះរាល់ការខូចខាតត្រូវបែងចែកទៅតាមភាពធ្ងន់ស្រាលនៃកំហុសរបស់ម្នាក់ៗ។

### ២.៣. អំពើតតិយជន

អំពើតតិយជនជាអំពើរបស់បុគ្គលណាក្រៅពីជនរងគ្រោះនិងចុងចំលើយ បង្កើតបានជាព្រឹត្តិការណ៍មិនអាចទប់ទល់ឈ្នះបាន ហើយមិនអាចប៉ាន់ស្មានដឹងជាមុនបាន ដែលជាហេតុធ្វើអោយចុងចម្លើយរួចផុតពីការទទួលខុសត្រូវ។

**ឧទាហរណ៍ ៖** លោក ក បានចុះកិច្ចសន្យាទិញទូរទស្សន៍ពីហាងរបស់លោក ខ នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៦។ ដោយលោក ខ បានសន្យានឹងប្រគល់ទូរទស្សន៍ទៅអោយលោក ក នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ២០១៦ នៅពេលទូរទស្សន៍នោះបានដឹកមកដល់ហាងរបស់គាត់។ នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៦ ទូរទស្សន៍នោះបានដឹកមកដល់ហាងរបស់គាត់ ។ បន្ទាប់ពីទូរទស្សន៍នោះបានដឹកមកដល់ហាងរបស់លោក ខ មានបុគ្គលិកផ្នែកសំអាតនៅក្នុងហាងរបស់លោក ខ បានធ្វើអោយធ្លាក់ទូរទស្សន៍នោះដែលជាកម្មវត្ថុនៃកិច្ចសន្យារវាងលោក ក និង លោក ខ ក្នុងអំឡុងពេលបុគ្គលិកនោះបានសំអាតហាងនៅបរិវេនទីតាំងស្តុកទុកឥវ៉ាន់ដែលមានម្ចាស់ ដូចនេះ នៅក្នុងករណីនេះវាជាអំពើតតិយជនដែលជាបុគ្គលិកសំអាតនៅក្នុងហាងរបស់លោក ខ ដែល ជាព្រឹត្តិការណ៍មិនអាចប៉ាន់ស្មានដឹងជាមុន ហើយលោក ខ អាចរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការស្រាវជ្រាវនិងបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថានៅក្នុងទំនាក់ទំនងរដ្ឋប្បវេណីត្រូវបានកំណត់ដោយច្បាប់។ កិច្ចសន្យាមានច្រើនប្រភេទ និង ច្រើនទម្រង់ ក៏ប៉ុន្តែកិច្ចសន្យានីមួយៗវាផ្អែកទៅលើកម្មវត្ថុនៃកិច្ចសន្យានោះ កិច្ចសន្យានីមួយៗមានលក្ខណៈខុសប្លែកពីគ្នាជាច្រើនចំណុច ជាពិសេសនោះគឺលក្ខណៈគ្រឹះខ្លះ និងលក្ខណៈទម្រង់មួយចំនួន ។ ចំពោះលក្ខខណ្ឌគ្រឹះ ទោះបីជាកិច្ចសន្យាកើតចេញពីការព្រមព្រៀងក៏ពិតមែនក៏ដោយក៏កិច្ចសន្យាមិនអាចបង្កើតឡើងបានដែរ ប្រសិនបើបុគ្គល ឬ ភាគីដែលជាប្រធាននៃកិច្ចសន្យាជាជនដែលត្រូវបានកម្រិតសមត្ថភាពទទួលសិទ្ធិជាអាទិ៍ ដោយយោងទៅតាមរដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ ជនដែលត្រូវបានច្បាប់កម្រិតសមត្ថភាពមួយចំនួនទៀតគឺមានដូចជា អនីតិជន ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និង ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ ជនទាំងនេះអាចធ្វើសកម្មភាពក្នុងការបង្កើតកិច្ចសន្យាបានលុះត្រាតែមានការយល់ព្រមពីអាណាព្យាបាល ហិតូបត្ថម្ភកៈ និងអាណាព្យាបាលទូទៅ ទើបគាត់អាចធ្វើសកម្មភាពបានដោយស្របច្បាប់និងធ្វើឱ្យកិច្ចសន្យាមានសុពលភាព ។

ដើម្បីបង្កើតកិច្ចសន្យាបាន ហើយស្របទៅនឹងច្បាប់ កិច្ចសន្យានោះត្រូវមានការព្រមព្រៀងរវាង គូភាគីទាំងពីរដោយសុច្ចរិត និង ស្មោះត្រង់ ពោលគឺ សំណើ និង ស្វីការត្រូវគ្នា។ ក្រោយពីបង្កើតកិច្ចសន្យាឡើងហើយភាគីទាំងពីរបានជាប់នូវចំណងគតិយុត្តរវាងគ្នាគឺបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក ដែលភាគីម្ខាងទទួលបានសិទ្ធិ និង ផលប្រយោជន៍ពីកិច្ចសន្យា ហើយភាគីម្ខាងទៀតជាអ្នកទទួលបន្ទុកដើម្បីបំពេញកាតព្វកិច្ចទៅឱ្យភាគីម្ខាងទៀត ។ ការបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក រវាងគូភាគីទាំងពីរត្រូវបានកំណត់នៅក្នុងកិច្ចសន្យាដោយមានចែងអំពីខលក្ខខណ្ឌនៅក្នុងកិច្ចសន្យានោះ ហើយភាគីទាំងពីរចាប់ផ្តើមអនុវត្តកាតព្វកិច្ចចាប់តាំងពីពេលបង្កើតកិច្ចសន្យានោះឡើង និង មានការកំណត់អំពីថិរវេលាដើម្បីបញ្ចប់នូវកិច្ចសន្យានោះនៅកាលបរិច្ឆេទណាមួយ ។

ការរំលាយកិច្ចសន្យាអាចត្រូវបានរំលាយតាមមធ្យោបាយជាច្រើនដែលក្នុងនោះអាចមានជាការរំលាយតាមរយៈការកំណត់ដោយច្បាប់ ការរំលាយតាមកិច្ចសន្យា និង ដោយការព្រមព្រៀងរបស់គូភាគី។ ផ្ទុយទៅវិញប្រសិនបើភាគីមិនអាចរំលាយតាមកិច្ចសន្យាដោយមូលហេតុថាមិនបានកំណត់ជាមុន និង ការមិនយល់ព្រមពីភាគីម្ខាងទៀតទេ នោះភាគីដែលមានសិទ្ធិរំលាយអាចរំលាយកិច្ចសន្យាបានតាមរយៈច្បាប់កំណត់គឺធ្វើតាមបញ្ញត្តិច្បាប់សារធាតុក្រមរដ្ឋប្បវេណីដោយលើកឡើងអំពីលក្ខខណ្ឌដែលត្រូវបានបំពេញដូចជាប្រភេទកិច្ចសន្យា

អញ្ញមញ្ញ និង ភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ។

ការរំលាយកិច្ចសន្យាមិនត្រឹមតែមានអានុភាពចំពោះភាគីតែប៉ុណ្ណោះទេ ពោលគឺមានអានុភាពចំពោះតតិយជនផងដែរ ត្រង់ចំណុចនេះវាគឺជាគោលបំណងក្នុងការការពារស្ថិរភាពជំនួញរបស់តតិយជនដែលត្រឹមត្រូវមិនឱ្យស្ថិតក្នុងស្ថានភាពមួយដែលអស្ថិរភាព ដែលរំលត់នូវការព្រួយបារម្ភទាំងឡាយរបស់តតិយជនត្រឹមត្រូវផងដែរ មិនមែនគ្រប់តតិយជនសុទ្ធតែត្រូវបានការពារទាំងអស់នោះទេ លុះត្រាតែតតិយជននោះមានភាពត្រឹមត្រូវតាមច្បាប់តតិយជនដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់នឹងត្រូវទទួលបាននូវការការពារ ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវតាក់តែងអត្ថបទសារណាមួយនេះ ក្រោមប្រធានបទមួយដែលមានចំណងជើងថា " **របបគតិយុត្តនៃកិច្ចសន្យា** " រួចមកយើងខ្ញុំបានយល់ឃើញថា កិច្ចសន្យា គឺពិតជាមានសារៈសំខាន់ណាស់ចំពោះជីវភាពរស់នៅប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់យើងគ្រប់រូប ។ ប្រសិនបើយើងមិនបានធ្វើការសិក្សាស្វែងយល់កិច្ចសន្យាបានជាក់ច្បាស់នោះទេ ប្រាកដណាស់យើងនឹងជួបប្រទះនូវបញ្ហាប្រឈមជាច្រើននៅក្នុងការប្រកបរបររកស៊ីចិញ្ចឹមជីវិត ។ ទន្ទឹងនឹងនេះប្រសិនបើយើងបានសិក្សាស្វែងយល់លម្អិតអំពីកិច្ចសន្យាឱ្យបានច្បាស់លាស់ហើយនោះ យើងមុខតែនឹងអាចជៀសផុតអំពីហានិភ័យ និង បញ្ហាប្រឈមនានានៃការបង្កើតកិច្ចសន្យា និង ការរំលាយកិច្ចសន្យា ។

ស្របពេលដែលសង្គមជាតិកម្ពុជាយើងនាពេលបច្ចុប្បន្នមានសន្តិភាព ស្ថេរភាពសង្គម និង មានការអភិវឌ្ឍន៍យ៉ាងជឿនលឿនដើរទៅមុខគ្រប់វិស័យ រួមមាន វិស័យការងារ វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម និង វិស័យផ្សេងៗទៀត បានធ្វើឱ្យប្រទេសយើងមានការរីកចម្រើនលូតលាស់គ្រប់មុខគ្រប់ផ្នែកទាំងអស់ជាមួយនឹងការវិនិយោគទុនទាំងក្នុងប្រទេសនិងក្រៅប្រទេស ហេតុនេះក្នុងនាមយើងជាប្រជាពលរដ្ឋខ្មែរមួយរូប យើងគួរគប្បីត្រូវស្វះស្វែងសិក្សាស្វែងយល់ឱ្យបានលម្អិតជាក់ច្បាស់អំពីរបបគតិយុត្តនៃកិច្ចសន្យាដែលក្នុងនោះរួមមានការបង្កើតកិច្ចសន្យា ការរំលាយកិច្ចសន្យា និង លក្ខខណ្ឌផ្សេងៗទៀតនៃកិច្ចសន្យា -ល- ដើម្បីបង្កើនចំណេះដឹងផ្នែកគតិយុត្តបន្ថែមទៀតនៅក្នុងការការពារផលប្រយោជន៍របស់ខ្លួនពីបុគ្គលឆ្លៀតឱកាសនានា និង ដើម្បីបំពេញតម្រូវការផ្ទាល់ខ្លួនអោយកើតទៅជាប្រយោជន៍ក្នុងការដាក់ទុនវិនិយោគប្រកបមុខរបររកស៊ីចិញ្ចឹមជីវិតរបស់យើងផ្ទាល់ខ្លួនក៏ដូចជាក្រុមគ្រួសាររបស់យើងបន្ថែមទៀត ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រធានបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយនេះនឹងចូលរួមចំណែកលើកកម្ពស់ដ៏ប្រសើរលើការតាក់តែងចងក្រង ការវិភាគ និង ការសិក្សាស្រាវជ្រាវជុំវិញទិដ្ឋភាពគតិយុត្តនៃកិច្ចសន្យា និង ទិដ្ឋភាពគតិយុត្តដទៃផ្សេងៗទៀតនៅក្នុងសង្គមនីតិរដ្ឋកម្ពុជាយើង អោយកាន់តែមានភាពជឿនលឿន និង ការអភិវឌ្ឍន៍ឈានឆ្ពោះទៅមុខទៅរកវិវឌ្ឍនភាព និង និរន្តភាពបន្ថែមទៀតឥតឈប់ឥតឈរជាតរៀងទៅ ។

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត និង ច្បាប់

- អនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦៩ ស្តីពីច្បាប់សន្ធិសញ្ញា
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី ០៨ ធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី ០៦ កក្កដា ២០០៦
- ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា, ចុះថ្ងៃទី ២៨ តុលា ១៩៨៨

## សៀវភៅ

- ច្បាប់កិច្ចសន្យា រៀបរៀងដោយមេធាវី ជ្រាវ ឈុនឡេង ឆ្នាំ ២០១៩
- កិច្ចសន្យាពិសេស រៀបរៀងដោយមេធាវី ជ្រាវ ឈុនឡេង ឆ្នាំ ២០១៩
- នីតិកិច្ចសន្យា នីតិកាតព្វកិច្ច រៀបរៀងដោយសាស្ត្រាចារ្យ ជិន វណ្ណារ៉ា
- កិច្ចសន្យាពិសេស រៀបរៀងដោយសាស្ត្រាចារ្យ ឆាយ ហុង
- អត្ថបទស្តីពីលក្ខខណ្ឌសុពលភាព និង ការរំលាយកិច្ចសន្យា រៀបរៀងដោយលោក ជួប បិតបេរឫទ្ធិ
- ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ភ្នំពេញ ៖ ខែ មីនា ឆ្នាំ ២០១៧, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១ ដល់ ភាគ ៣
- គណៈកម្មការទទួលបន្ទុកធ្វើសេចក្តីព្រាងរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១ ដល់ ភាគ៦
- ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មេធាវី ស៊្វីន អ៊ែម អូស្មែរមីឡឺរ៍(បោះពុម្ពលើកទី២)៖ខែ មករា ឆ្នាំ ២០១០

# ឧបសម្ព័ន្ធ

# គំរូកិច្ចសន្យាព្រមព្រៀងជួលដី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យាព្រមព្រៀងជួលដី

**កិច្ចព្រមព្រៀងជួលនេះ ត្រូវបានធ្វើឡើងរវាង:**

១- លោក……………………កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ……………………និងភរិយាឈ្មោះ……………………កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ……………………មានអាស័យដ្ឋានលេខ…………ផ្លូវលេខ…………សង្កាត់……………………ខណ្ឌ……………………ខេត្ត……………………

ជាម្ចាស់ដី ដែលមានទីតាំង ស្ថិតនៅ…………………………………………………………………………………………………………(ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី"ក"**) ។

**និង**

២- លោក……………………ភេទ…………

កើតនៅថ្ងៃទី………ខែ………ឆ្នាំ………កាន់លិខិតឆ្លងដែនលេខ……………………មានអាស័យដ្ឋានលេខ…………ផ្លូវ…………សង្កាត់……………………ខណ្ឌ……………………ខេត្ត……………………

ជាអ្នកជួលដី (ចាប់ពីពេលនេះតទៅ ហៅកាត់ថា **ភាគី"ខ"**) ។

**ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងគ្នាតាមប្រការ និងលក្ខខណ្ឌដូចតទៅ:**

**ប្រការ១:** **កិច្ចព្រមព្រៀងជួល**

**ភាគី"ក"** យល់ព្រមជួលដី អោយ **ភាគី"ខ"** ក្នុងរយៈពេល……………ឆ្នាំ គិតចាប់ពីថ្ងៃទី…………ខែ…………ឆ្នាំ…………រហូតដល់ថ្ងៃទី…………ខែ…………ឆ្នាំ…………(តទៅនេះហៅកាត់ថា **"រយៈពេលជួល"**) ។

**ប្រការ២:** **ថ្លៃឈ្នួលប្រចាំខែ**

ថ្លៃឈ្នួលប្រចាំខែគឺ……………USD (……………………ដុល្លារអាមេរិកក្នុងមួយខែ) ក្នុងរយៈពេលជួល ហៅថា ប្រាក់ឈ្នួល **ភាគី"ខ"** ត្រូវបង់ប្រាក់ឈ្នួលទៅអោយ **ភាគី"ក"** នៃដើមខែនីមួយៗនៅរៀងរាល់ខែដោយចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៧ នៃដើមខែនីមួយៗ ។ ប្រសិនបើ **ភាគី"ខ"** ខកខានមិនបានបង់ប្រាក់ឈ្នួលទៅតាមកិច្ចសន្យានេះទេ ប្រាក់កក់ នឹងត្រូវទុកជាអសារបង់ ហើយចំពោះកិច្ចសន្យាជួលដី ត្រូវទុកជាមោឃៈដោយស្វ័យប្រវត្តិ ។

**ប្រការ៣:** **ប្រាក់កក់**

**ភាគី "ខ"** បានយល់ព្រមបង់ប្រាក់កក់ជូនទៅ **ភាគី "ក"** ចំនួន ________USD (________________ដុល្លារអាមេរិក) ស្មើនឹងប្រាក់ឈ្នួលប្រចាំខែ ____ខែ ចាប់ពីពេលនេះតទៅហៅកាត់ថា ប្រាក់កក់ ប្រសិនបើ **ភាគី "ខ"** បញ្ចប់កិច្ចសន្យាជួលមុនកាលកំណត់ជួលនេះ ប្រាក់កក់ត្រូវទុកជាអសារបង់របស់ **ភាគី "ក"** ។ ប៉ុន្តែក្រោយពេលផុតកំណត់រយៈពេលជួល **ភាគី "ក"** ត្រូវបង្វិលប្រាក់កក់ជូន **ភាគី "ខ"** វិញគ្រប់ចំនួន ។

**ប្រការ៤:** **ការលក់ដី ឬផ្ទះ**

ប្រសិនបើ **ភាគី "ក"** ធ្វើការលក់ដីខាងលើនេះទៅអោយភាគីណា ឬ ក្រុមហ៊ុនណាមួយផ្សេងនោះ **ភាគី "ក"** និងម្ចាស់កម្មសិទ្ធិថ្មីត្រូវរក្សា និងគោរពតាមគ្រប់លក្ខខណ្ឌនៃកិច្ចសន្យាជួលនៅដដែល រហូតដល់ពេលផុតកំណត់នៃកិច្ចសន្យាជួល ។ **ភាគី "ខ"** មិនត្រូវបានអនុញ្ញាតិអោយធ្វើការផ្ទេរ ឬ ជួលបន្តដីនេះទៅអោយភាគីទី៣ បានឡើយ ។ ( អាចជួលបាន) ត្រូវតែជូនដំណឹង និងមានការឯកភាពយល់ព្រមពីសំណាក់ **ភាគី "ក"** ជាមុនសិន ។

**ប្រការ៥:** **លើប្រាក់ពន្ធ ទឹក ភ្លើង និងសេវាកម្មផ្សេងៗ**

**ភាគី "ខ"** ត្រូវទទួលខុសត្រូវថ្លៃប្រើប្រាស់ ទឹក ភ្លើងអគ្គិសនី សំរាម ទូរស័ព្ទ ទូរទស្សន៍ខ្សែកាប និងការបង់ពន្ធធ្វើអាជីវកម្មនៅលើដីនេះ ។ល។ តាមច្បាប់រដ្ឋដែលបានកំណត់អោយបង់ និងតាមវិក័យប័ត្រដែលក្រុមហ៊ុននីមួយៗបានផ្តល់អោយ ក្នុងកំឡុងពេលនៅកិច្ចសន្យាជួល ។ ប្រសិនបើវិក័យប័ត្រដែលមិនបានបង់ និងត្រូវកាត់យកពីប្រាក់កក់នៅពេលផុតកំណត់រយៈពេលជួល ។

**ប្រការ៦:** **សុវត្ថិភាពសង្គម និងការថែទាំ**

**ភាគី "ខ"** ត្រូវជួយថែទាំដីនេះក្នុងលក្ខណៈល្អត្រឹមត្រូវ និងមានអនាម័យក្នុងកំឡុងពេលជួល ហើយ **ភាគី "ខ"** មិនត្រូវប្រើប្រាស់ដីនេះ ដើម្បីធ្វើសកម្មភាពផ្ទុយ និងច្បាប់ ឬខុសច្បាប់ផ្សេងៗ ឡើយ ដូចជា: ជួញដូរគ្រឿងញៀន. បើកបន. ឬផ្ទុកអាវុធ ។ល។ ហើយត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសកម្មភាពរបស់ខ្លួនផ្ទាល់ ។ ករណីអគ្គិភ័យ និងការបង្កជំលោះជាមួយអ្នកជិតខាង និងការបាត់បង់ដែលបង្កឡើងដោយការធ្វេសប្រហែសរបស់ **ភាគី "ខ"** នោះ ជាបន្ទុករបស់ **ភាគី "ខ"** ក្នុងការសងការខូចខាត ។

**ប្រការ៧:** **ការយល់អំពីកិច្ចសន្យាជួល**

កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន ០៣ច្បាប់ ដែលមានខ្លឹមសារ និងសុពលភាពស្មើគ្នា ។ ភាគីទាំងពីរបាន អានគ្រប់ខ្លឹមសារ និងលក្ខខណ្ឌក្នុងកិច្ចសន្យានេះ ហើយភាគីនីមួយៗ ត្រូវគោរពគ្រប់ប្រការតាម លក្ខខណ្ឌនៃកិច្ចសន្យានេះ ។ ប្រសិនបើភាគីណាមួយប្រព្រឹត្តបទល្មើស និងកិច្ចសន្យានេះ ភាគីនោះត្រូវ ទទួលខុសត្រូវចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ហើយកិច្ចសន្យានេះ ភាគីនីមួយៗរក្សាទុក ម្នាក់មួយច្បាប់ និងសាក្សីមួយច្បាប់ និងយល់ព្រមផ្តិតមេដៃស្តាំទុកជាភស្តុតាង ។

ធ្វើនៅ. ថ្ងៃទី ______ ខែ______ ឆ្នាំ ________

**ស្នាមមេដៃភាគី "ខ"** **សាក្សី** **ស្នាមមេដៃភាគី "ក"**

# <u>គំរូកិច្ចសន្យាជួលផ្ទះ</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***

**<u>កិច្ចសន្យាជួលផ្ទះ</u>**

**<u>ភាគីម្ចាស់ផ្ទះ:</u>** យោងទៅលើកិច្ចសន្យានេះលោក......................ភេទ...........អាយុ..........ជនជាតិ...............

កាន់អត្តសញ្ញាណប័ណ្ណលេខ.................... ជាម្ចាស់ ផ្ទះលេខ........... ផ្លូវលេខ

..................................សង្កាត់..........................................

ខណ្ឌ...........................រាជធានីភ្នំពេញ (ដែលហៅថាភាគី "ក") បានព្រមព្រៀងជួលផ្ទះលេខ

........... ផ្លូវលេខ ........................................ សង្កាត់ ..................................

ខណ្ឌ.............................................រាជធានីភ្នំពេញ ដែលហៅថា "ផ្ទះជួល" ទៅអោយ :

**<u>ភាគីអ្នកជួល:</u>** ..................................... ភេទ .........សញ្ជាតិ ........ មុខរបរ ......................

កាន់អត្តសញ្ញាណប័ណ្ណលេខ.................... ......................ដែលហៅថាភាគី "ខ" ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការជួលផ្ទះខាងលើដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម:**

<u>ប្រការ១:</u> **រយៈពេលនៃកិច្ចសន្យាជួល**

រយៈពេលនៃកិច្ចសន្យាជួលផ្ទះនេះមានចំនួន...................ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ......... ខែ ......... ឆ្នាំ២០១៣ ដល់ ថ្ងៃទី .................... ខែ ............... ឆ្នាំ២០១៣ ក្នុងតំលៃឈ្នួលមួយខែចំនួន ..........................ដុល្លារ (.......................................................ដុល្លារសហរដ្ឋអាមេរិក) ដោយមិនបញ្ចូលថ្លៃ ប្រើប្រាស់ទឹក ភ្លើង ទូរសព្ទ ខ្សែកាប អ៊ិនធឺណែតរបស់ភាគី "ខ" ឡើយ ។

<u>ប្រការ២:</u> **ការបង់ប្រាក់**

-ភាគី "ខ" នឹងបង់ប្រាក់កក់ទៅអោយភាគី "ក" សំរាប់រយៈពេល០........ខែទុកតំកល់ចុងក្រោយ

នៃកិច្ចសន្យា នេះចំនួន..................ដុល្លារ (..........................................ដុល្លារសហរដ្ឋអាមេរិក)

ប្រាក់ដំកល់នេះភាគី "ក" នឹងប្រគល់ជូនវិញនៅចុងបញ្ចប់នៃកិច្ចសន្យា ។

-ប្រាក់បង់មុនចំនួន០......ខែសំរាប់ការស្នាក់នៅដំបូងដែលមានចំនួន................ដុល្លារ(........................

...............................................ដុល្លារសហរដ្ឋអាមេរិក) គឺគិតចាប់ពី ថ្ងៃទី ........ ខែ ........ ឆ្នាំ ២០១៣ ដល់ ថ្ងៃទី ............ខែ ......... ឆ្នាំ ២០១៣ គឺនៅពេលចុះហត្ថលេខាលើកិច្ចសន្យាជួលផ្ទះនេះ ។

-ការបង់ប្រាក់ឈ្នួលផ្ទះបន្ទាប់គឺនៅថ្ងៃទី ........... ខែ .........ឆ្នាំ ២០១៣ និង រៀងរាល់ ថ្ងៃទី ...................នៃខែនិមួយៗ មិនអោយហួសពីមួយសប្តាហ៍ឡើយ ។

ប្រការ៣: **ការបញ្ចប់កិច្ចសន្យាជួល**

ក) កិច្ចសន្យានេះនឹងបញ្ចប់ដោយស្វ័យប្រវត្តិនៅថ្ងៃ ទី ........ ខែ ..........ឆ្នាំ ២០១៣ ។

ខ) កិច្ចសន្យានេះនឹងពិភាក្សាឡើងវិញដោយភាគីទាំងពីរគឺភាគី "ក" និង ភាគី "ខ" ថាត្រូវជួលបន្តឬក៏បញ្ចប់កិច្ចសន្យា ។

គ) ក្នុងរយៈពេលនៃកិច្ចសន្យានេះភាគីទាំងពីរមិនមានសិទ្ធិបញ្ចប់កិច្ចសន្យានេះមុនពេលកំណត់បានទេ

ក្នុងករណីភាគី "ខ" បញ្ចប់កិច្ចសន្យានេះមុនពេលកំណត់នោះប្រាក់កក់ដំកល់មួយខែនឹងមិនប្រគល់ជូន

ភាគី "ខ" វិញឡើយប៉ុន្តែប្រសិនបើភាគី "ក" មានបំណងចង់បញ្ចប់កិច្ចសន្យានេះមុនពេលកំណត់វិញ

ភាគី "ក" ត្រូវប្រគល់ប្រាក់កក់ដំកល់..........................ខែទៅអោយភាគី "ខ" វិញហើយត្រូវបង់ថ្លៃសងជំងឺចិត្តចំនួន០.....................ខែបន្ថែមទៀតទៅអោយភាគី "ខ" ។

ឃ) ក្នុងរយៈពេលនៃកិច្ចសន្យានេះភាគី "ខ" អាចមានសិទ្ធិបញ្ឈប់ការជួលផ្ទះនេះមុនពេលកំណត់ដោយជូនដំណឹង ជាលាយល័ក្ខអក្សរចំនួន៣០ថ្ងៃជាមុន ប៉ុន្តែប្រាក់កក់ជាកល់ចំនួន...........ខែនឹងមិនប្រគល់ជូនភាគី "ខ" វិញទេ ។

<u>ប្រការ៤:</u> ភាគី "ក" ត្រូវធានាប្រព័ន្ធអគ្គិសនី និងបណ្តាញទឹកគ្រប់គ្រាន់ ប្រព័ន្ធអគ្គិសនី ត្រូវតែមានលក្ខណៈល្អ សំរាប់ការប្រើប្រាស់នៅក្នុងផ្ទះជូនដល់ភាគី "ខ" ប្រើប្រាស់ប៉ុន្តែរាល់ការប្រើប្រាស់ (អគ្គិសនី, ទឹក និង អនាម័យ) គឺភាគី "ខ" ជាអ្នកទទួលខុសត្រូវ ដោយចាប់ ពីថ្ងៃទី ........ខែ ..........ឆ្នាំ ........... នេះតទៅ ។

ចំណាំ:

-ភ្លើងថ្លៃ ..............រៀល ក្នុង១គីឡូវ៉ាត់ម៉ោង

-ទឹកថ្លៃ ..............

-ខ្សែកាបថ្លៃ .........ដុល្លារ ក្នុងមួយខែ

<u>ប្រការ៥:</u> រាល់ការរុះរើកែលំអរផ្ទះ ដោយ ប្រការណាមួយដែលធ្វើឡើងដោយភាគី "ខ" ត្រូវសុំការអនុញ្ញាតពីភាគី "ក" និងមានការឯកភាពជាមុនសិន ។

<u>ប្រការ៦:</u> ភាគី "ខ" មិនអាចប្រើប្រាស់ផ្ទះនេះជាឃ្លាំងជំនួញឬការិយាល័យខុសច្បាប់ឬជាគណៈបក្សនយោបាយ

ឡើយ ។

<u>ប្រការ៧:</u> ភាគី "ខ" ពុំមានសិទ្ធិជួលផ្ទះនេះទៅអោយភាគីទី ៣ ដោយគ្មានការអនុញ្ញាតិពីភាគី "ក" បានឡើយ ។

<u>ប្រការ៨:</u> **ការតុបតែងនិងការថែរក្សា**

ក) ផ្ទះនេះបានតុបតែងដោយម្ចាស់ផ្ទះយោងទៅតាមបញ្ជីសំភារៈ ។

ខ) ភាគី "ខ" ធានាក្នុងការថែរក្សាដោយខ្លួនឯងក្នុងរយៈពេលជួលនេះ និងត្រូវធ្វើការត្រួតពិនិត្យ ថែរក្សា និងជួសជុលសំភារៈបរិក្ខារផ្សេងៗដែលបានផ្តល់ជូន ។

គ) នៅថ្ងៃចប់កិច្ចសន្យាភាគី "ខ" ត្រូវប្រគល់ជូនវិញនូវសំភារៈដែលបានផ្តល់ទៅតាមបញ្ជីសំភារៈក្នុងលក្ខណៈល្អ ។

ឃ) ភាគី "ខ" ត្រូវធ្វើការជួសជុលឡើងវិញ នូវរាល់ការខូចខាតចំពោះបរិក្ខារទាំងឡាយណាដែលបានផ្តល់ជូនដោយភាគី "ក" ដោយការខូចខាតបាក់បែកនោះមិនបណ្តាលមកពីការសឹករិចរឹល, ខូចខាតដោយគ្រោះ ធម្មជាតិ ។

ប្រការ៩: ភាគី "ក" ត្រូវទទួលខុសត្រូវលើការបង់ពន្ធទាំងឡាយដែលទាក់ទងទៅការជួលផ្ទះនេះចំណែកពន្ធលើអាជីវកម្មផ្សេងៗវិញ ជាបន្ទុករបស់ភាគី "ខ" ។

ប្រការ១០: ភាគី "ខ" មិនត្រូវបង្កអោយមានភាពរំខានដល់អ្នកជិតខាង ។

ប្រការ១១: ភាគីទាំងពីរត្រូវគោរពទៅតាមលក្ខខ័ណ្ឌនិងរាល់ប្រការនៃកិច្ចសន្យាខាងលើ ។

ប្រសិនបើភាគីណាមួយអនុវត្តខុសពីកិច្ចសន្យាខាងលើនេះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។ កិច្ចសន្យានេះធ្វើឡើងជាបួនច្បាប់ ពីរច្បាប់ជាភាសាខ្មែរ និង ពីរច្បាប់ទៀតជាភាសា អង់គ្លេស ដែលមានតំលៃស្មើគ្នាចំពោះមុខច្បាប់ ។

ភ្នំពេញ, ថ្ងៃទី......ខែ......ឆ្នាំ ២០១៣

ហត្ថលេខា (ឬស្នាមមេដៃ) ភាគី "ក" ហត្ថលេខា (ឬស្នាមមេដៃ) ភាគី "ខ"

សាក្សី សាក្សី

# គំរូកិច្ចសន្យាលក់-ទិញដី-ផ្ទះ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាលក់_ទិញដី_ផ្ទះ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ក" ជាអ្នកទិញ** ............................................... ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................ខេត្ត/ក្រុង...................... ហៅកាត់ថា **ភាគី"ខ" ជាអ្នកលក់** ...............................................។

***ភាគី"ក" និងភាគី"ខ" បានព្រមព្រៀងចុះកិច្ចសន្យាលក់-ទិញ តាមប្រការដូចខាងក្រោម:***

**<u>ប្រការ១:</u> អចលនទ្រព្យ ដី ឬផ្ទះ**

បណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យលេខ..................................ចុះថ្ងៃទី.........ខែ.........ឆ្នាំ........... ចេញ ដោយស្ថាប័នមានសមត្ថកិច្ច............................................................................................ ។

**<u>ប្រការ២:</u> អំពីតម្លៃអចលនទ្រព្យ និងការទូទាត់**

ភាគីទាំងពីរបានឯកភាពលើតម្លៃអចលនទ្រព្យ គឺ.....................ដុល្លារ (...........................................) ដែលត្រូវទូទាត់តាមរយ: តាមសាច់ប្រាក់សុទ្ធ នៅពេលដែល ភាគី"ខ" រៀបចំឯកសាររួចរាល់ផ្តល់ឱ្យភាគី"ក" ចុះថ្ងៃទី.........ខែ.............ឆ្នាំ.............. ។

**<u>ប្រការ៣:</u> ការទទួលខុសត្រូវរបស់ភាគី"ខ"**

ត្រូវបំពេញបែបបទលើឯកសារ (កាត់ឈ្មោះ) នៃអចលនទ្រព្យនេះប្រគល់ឱ្យភាគី"ក" ដោយថ្លៃចំណាយ នៃសេវា ក្នុងកាត់ឈ្មោះនេះជាការទទួលខុសត្រូវរបស់ភាគី"ខ" ។

**<u>ប្រការ៤:</u> ការទទួលខុសត្រូវរបស់ភាគី"ក"**

ភាគី"ក" មានសិទ្ធិកាន់កាប់ឯកសារទៅដើរបញ្ជីលក់-ទិញ នៅគ្រប់ស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៤ច្បាប់ សម្រាប់ភាគី "ក" និងភាគី "ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ និងតំកល់ទុកនៅឃុំ/សង្កាត់ចំនួន ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី "ក" និងភាគី "ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ................. ថ្ងៃទី..........ខែ...........ឆ្នាំ.............

| **ភាគី "ខ"** | **សាក្សីភាគី "ខ"** | **សាក្សីភាគី "ក"** | **ភាគី "ក"** |
| --- | --- | --- | --- |
| ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... |

លេខ:...................

បានឃើញ និង បញ្ជាក់ថា ស្នាមមេដៃស្តាំទាំងអស់តាមឈ្មោះរៀងគ្នាខាងលើ ពិតជាបានផ្តិតនៅចំពោះមុខយើងជាមេឃុំ/ចៅសង្កាត់ តាមខ្លឹមសារនៃកិច្ចសន្យាប្រាកដមែន ។

ធ្វើនៅ...............ថ្ងៃទី............ខែ............ឆ្នាំ..........

**មេឃុំ/ចៅសង្កាត់** ....................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវីប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី..........ខែ...........ឆ្នាំ..........

**មេធាវី**

# <u>គំរូលិខិតរំលឹកដាស់តឿន</u>

លិខិតរំលឹកដាស់តឿន　　　　　　　　　　　　រៀបរៀងដោយ លោក ស៊ុនហៀង ម៉េងឈីម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>លិខិតរំលឹកដាស់តឿន</u>**

ខ្ញុំ ............................... ជាប្រធានក្រុមហ៊ុន.............................. មានទីតាំងអាគារលេខ:.........ផ្លូវលេខ:............សង្កាត់.....................ខណ្ឌ.....................រាជធានីភ្នំពេញ ។ លេខទូរស័ព្ទ.......................

**<u>គោរពជូន</u>**

**លោក** ..................... **និងភរិយា** ......................

*<u>មេត្តាជ្រាប</u> ។*

**<u>កម្មវត្ថុ</u>**: សុំរំលឹកអំពីការបង់ការប្រាក់ ។

**<u>យោង</u>**: - កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី...... ខែ......... ឆ្នាំ............ ។

- កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី......... ខែ......... ឆ្នាំ............ ។

- លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី......... ខែ......... ឆ្នាំ............ ។

តមតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តយសសូមជម្រាបជូនលោក .............. និងភរិយា ........... ជ្រាបថា: កាលពីថ្ងៃទី...... ខែ...... ឆ្នាំ......... **លោក និងភរិយា**បានចុះកិច្ចសន្យាខ្ចីបរិភោគ ជាមួយនឹងខ្ញុំនូវចំនួនទឹកប្រាក់សរុប.................USD(............**ដុល្លារអាមេរិក**) ដោយសន្យាបង់ការប្រាក់ក្នុង១(មួយ)ខែ............USD(.................**ដុល្លារអាមេរិក**) អោយបានទៀងទាត់ជូនខ្ញុំ គឺនៅចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី០៣នៃខែនីមួយៗ ។ នៅថ្ងៃទី...... ខែ... ឆ្នាំ២០១៦ **លោក និងភរិយា**បានបំពេញកាតព្វកិច្ចតាមការកំណត់នៅក្នុងកិច្ចសន្យា ប៉ុន្តែខែបន្តបន្ទាប់រហូតមកដល់ថ្ងៃទី......ខែ......... ឆ្នាំ២០១៦នេះ **លោក និងភរិយា**មិនទាន់បានបំពេញកាតព្វកិច្ចដូចមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគនូវឡើយទេ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក និងភរិយា មេត្តាជ្រាបជាពត៌មាន និងមកទូទាត់ប្រាក់តាមកាតព្វកិច្ចដូចមានចែងនៅក្នុងកិច្ចសន្យាតាមការកំណត់ នៅក្រុមហ៊ុន...........ដែលមានអាស័យដ្ឋានអាគារលេខ:...... ផ្លូវ...... សង្កាត់.............. ខណ្ឌ........... រាជធានីភ្នំពេញ ក្នុងរយ:ពេល........... ចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងនេះ ។

ខ្ញុំសង្ឃឹមថា ក្រោយពីបានទទួលនូវលិខិតនេះហើយ លោក និងភរិយា ពិតជាចូលរួមសហការបំពេញកាតព្វកិច្ចយ៉ាងល្អប្រសើរជាមួយយើងខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ......ខែ ...... ឆ្នាំ ២០១៦

**ហត្ថលេខា និងត្រា**

# <u>គំរូលិខិតប្រគល់និងទទួលប្រាក់</u>

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>លិខិតប្រគល់និងទទួលប្រាក់</u>**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ...........................អាយុ.........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................. ចុះថ្ងៃទី........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

**បានទទួលប្រាក់ចំនួន**......................ដុល្លារ (...................................................) នៅថ្ងៃទី............ ខែ............ឆ្នាំ............. ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..............................អាយុ...........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............. ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ...................ខេត្ត/ក្រុង...................... ។

ក្រែងពុំពិតប្រាកដយើងខ្ញុំទាំងពីរនាក់ សូមផ្ដិតមេដៃស្ដាំទុកជាភស្តុតាងតាមផ្លូវច្បាប់ ។

**ធ្វើនៅ..............ថ្ងៃទី.........ខែ..........ឆ្នាំ២០.......**

**ស្នាមមេដៃស្ដាំអ្នកទទួលប្រាក់ សាក្សីអ្នកទទួលប្រាក់ សាក្សីអ្នកប្រគល់ប្រាក់ ស្នាមមេដៃស្ដាំអ្នកប្រគល់ប្រាក់**

ឈ្មោះ.......................... ឈ្មោះ.......................... ឈ្មោះ.......................... ឈ្មោះ..........................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្ដិតមេដៃស្ដាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**